# ធម្មសមុហកថា

## ធម្មទេសនា ១២ គ្រែ

រៀបរៀង

ដោយក្រុមបណ្ឌិតពុទ្ធសាសនា



ព.ស ២.៤០០

ចំលងសារជាថ្មី ព.ស ២៥៤៦

# សន្ទឹកាចង្អុលមាតិកាធម៌


បុព្វកថា ........................................................ ក

អារម្ភបទ សម្តេចព្រះមហាសុមេធាធិបតី ជ.ណា ជោតញ្ញាណោ ........

ឧបក្កិលេស១៦ ព្រះពោធិវ័ង្ស ហ.ត វជរប្បញ្ញោ ..........................១

ធម្មចក្កប្បវត្តនសូត្រ ព្រះឃោសធម្ម ម.ស ចន្ទធម្មោ...................១០

គោលព្រះពុទ្ធសាសនា៣យ៉ាង ព្រះឧបាលិវង្ស ស.ហ សុវណ្ណសរោ....២២

ទុក្ខធម្មកថា ព្រះទេពសត្ថា ក.ត ចន្ទមង្គលោ.............................៣៦

បារមី៣០, ទសជាតក៍សង្ខេប ព្រះឥន្ទមុនី ក.វ សុវណ្ណត្ថេរោ ......៥០

ពហុការធម៌ ព្រះទេពមុនី ប្រ.ប៉ សុវណ្ណប្បញ្ញោ.........................៧៣

សង្គហវត្ថុ៤យ៉ាង ព្រះគ្រូញាណសត្ថា ប៉.ស ញាណសារោ...........៨៧

បដិច្ចសមុប្បាទសង្ខេប ព្រះគ្រូសង្ឃសត្ថា ប៉.ស. ធម្មារាមោ ......១០១

អនាមតធម៌៥យ៉ាង ព្រះគ្រូមុនីសោភ័ណ ស.ន. សារញ្ញាណោ ...១១៣

សតិប្បដ្ឋាន៤ ព្រះគ្រូសង្ឃសុមេធ ធ.វ. ធម្មប្បញ្ញោ ...................១១៦

ធុរៈព្រះពុទ្ធសាសនា២យ៉ាង ព្រះគ្រូធម្មបណ្ឌិត គ.ស៊ិ. ធម្មត្ថេរោ ....១២៣

# បុព្វកថា

សៀវភៅ ធម្មសមុហកថា ដែលលោកអ្នក កំពុងអាននេះ ត្រូវបានចម្លងសាជាថ្មីចេញពីច្បាប់ដើម ដែលត្រូវបានបោះពុម្ព ក្នុង ព.ស. ២៥០០។

ដោយសៀវភៅដែលជាច្បាប់ដើមនោះចាស់ពេក ជាហេតុ បណ្ដាលឲ្យដាច់ទំព័រដំបូង ដែលនិយាយពីអារម្ភកថា របស់សម្ដេច ព្រះមហាសុមេធាធិបតី ជួន ណាត ហើយខ្ញុំក៏មិនអាចមានលទ្ធភាព រកបាន ទើបទុកទំព័រនេះចំហសិន។

កម្មជាកុសល ដែលបានពីធម្មទាននេះ ខ្ញុំសូមលើកជូន អ្នកមានគុណទាំងពីរ និងប្រគេន, ឧទ្ទិស ជូនម្ចាស់អត្ថបទ ដែលខំប្រឹងប្រែងក្នុងការស្រាវជ្រាវ បង្កើតជាអត្ថបទដ៏មានខ្លឹមសារទាំងនេះឡើង ដើម្បីប្រយោជន៍ដល់ជនទូទៅ។ សូមឧទ្ទិសចំពោះញាតិទាំងឡាយ ក្នុងសង្សារវដ្ត ។ សូមអ្នកអានទាំងឡាយ អនុមោទនានូវបុណ្យ ជារបស់ខ្ញុំ ហើយសូមអោយរួចផុតចាកទុក្ខទាំងពួង។

ឈ្យូក ក្រហម

# ១. ឧបក្កិលេស

### វត្ថូបមសូត្រ គម្ពីរមជ្ឈិមនិកាយ មូលបណ្ណាសកៈ

"**ចិត្តេ សង្កិលិដ្ឋេ ទុគ្គតិ បាដិកង្ខា, ចិត្តេ អសង្កិលិដ្ឋេ សុគតិ បាដិកង្ខា** ចិត្តរបស់បុគ្គលណាមួយ សៅហ្មងហើយ ទុគ្គតិនឹងមានប្រាកដ ដល់បុគ្គលនោះ ចិត្តរបស់បុគ្គលណាមួយ មិនសៅហ្មង គឺបរិសុទ្ធស្អាត សុគតិនឹងមានប្រាកដ ដល់បុគ្គលនោះ "នេះជាភាសិតរបស់ព្រះសក្យមុនីគោត្តមបរមគ្រូរបស់យើង។

ត្រង់ពាក្យថា ចិត្តសៅហ្មង គឺចិត្តល្អក់ខ្វល់ មិនភ្លឺថ្លា ដោយមានឧបក្កិលេសធម៌ ចូលទៅលាយឡំ ចិត្តដែលមិនសៅហ្មង គឺចិត្តបរិសុទ្ធស្អាត ឥតមានឧបក្កិលេសចូលទៅលាយឡំ។

អកុសលធម៌ ដែលចូលទៅលាយឡំ ជាមួយនឹងចិត្ត ហើយធ្វើចិត្តឲ្យសៅហ្មង មិនឲ្យចិត្តមានពន្លឺភ្លឺស្វាង ហៅថា "ឧបក្កិលេស"។ ឧបក្កិលេសនោះ មាន១៦យ៉ាងគឺៈ

១. **អភិជ្ឈាវិសមលោភៈ** ល្មោភជាអភិជ្ឈា ជាវិសមៈ។

២. **ព្យាបាទៈ** គំនុំ គឺចងគំនុំបម្រុងនឹងធ្វើគេឲ្យវិនាស។

៣. **កោធៈ** សេចក្ដីក្រេវក្រោធ។

៤. **ឧបនាហៈ** ការចងកំហឹងទុក។

៥. **មក្ខៈ** ការលុបគុណអ្នកដ៏មានគុណ។

៦. **បឡាសៈ** ការវៃប្ញកប្រៀបផ្ទឹម ឬប្រណាំងវាសនា។

៧. **ឥស្សា** សេចក្ដីច្រណែនឈ្នានីស។

៨. **មច្ឆរិយៈ** សេចក្ដីកំណាញ់។

៩. **មាយា** ការប្រព្រឹត្តលាក់ពុត បិទបាំងទោស។

១០. **សាឋេយ្យៈ** ការអួតអាង ឬការអែបអប។

១១. **ថម្ភៈ** សេចក្តីរឹងត្អឹង។

១២. **សារម្ភៈ** ការប្រណាំងប្រជែង។

១៣. **មានៈ** សេចក្តីប្រកាន់ខ្លួន។

១៤. **អតិមានៈ** សេចក្តីប្រកាន់ខ្លួនហួសពេក គឺមើលងាយគេ។

១៥. **មទៈ** សេចក្តីស្រវឹង។

១៦. **បមាទៈ** ការធ្វេសប្រហែស ឬការបណ្តោតបណ្តោយ។

## សេចក្តីអធិប្បាយ

ឧបក្កិលេសទី១ ឈ្មោះអភិជ្ឈាវិសមលោភៈ។ ក្នុងអដ្ឋកថានៃវត្ថូបមសូត្រ មានសេចក្តីពន្យល់ថា សេចក្តីត្រេកត្រអាលក្នុងទ្រព្យរបស់ខ្លួនហៅថា អភិជ្ឈា សេចក្តីត្រេកត្រអាលក្នុងទ្រព្យរបស់អ្នកដទៃហៅថា វិសមលោភៈ។ ន័យមួយទៀតថា សេចក្តីត្រេកអរក្នុងទ្រព្យរបស់ខ្លួនក្តី របស់អ្នកដទៃក្តី ក្នុងទីដ៏សមគួរ ហៅថាអភិជ្ឈា ក្នុងទីមិនសមគួរ ហៅថា វិសមលោភៈ។ ប៉ុន្តែដល់រួមសេចក្តីទៅ សម្រេចថា លោភចិត្តដែលជាប់ជំពាក់ក្នុងទ្រព្យរបស់ខ្លួនក្តី របស់អ្នកដទៃក្តី ហៅថាអភិជ្ឈា ព្រោះចិត្តនោះ ចេះតែសម្លឹងរំពៃ ហៅថាវិសមៈ ព្រោះចិត្តនោះជាប់ជំពាក់ ក្នុងវត្ថុជាវិសមភាព គឺតាមតែវត្ថុនោះដូចម្តេចក៏ដោយ។ បទថាអភិជ្ឈាក្តី វិសមៈក្តី បានសេចក្តីដូចគ្នា ផ្សេងគ្នាតែព្យញ្ជនៈប៉ុណ្ណោះ។ ឧបក្កិលេសទី១នេះ បើនឹងហៅត្រឹមតែ អភិជ្ឈា ឬត្រឹមតែវិសមៈ ឬត្រឹមតែលោភៈប៉ុណ្ណោះ ក៏បាន។ សេចក្តីលោភនេះ

ជាអកុសលមូល បើកើតក្នុងសន្តានចិត្តបុគ្គលណាហើយ រមែងដឹកនាំបុគ្គលនោះ ឲ្យធ្វើនូវអំពើសុទ្ធតែ ជាអកុសល មិនដែលនាំឲ្យធ្វើកុសលមានទានជាដើមឡើយ។

ឧបក្កិលេសទី២ ឈ្មោះព្យាបាទៈ ប្រែថាការចងគំនុំបម្រុងនឹងធ្វើគេអោយវិនាស។ ក្នុងអដ្ឋកថា វត្ថូបមសូត្រ មានសេចក្ដីពន្យល់ ថាព្យាបាទៈនេះ កើតឡើងអំពីអាឃាតវត្ថុ គឺវត្ថុដែលបណ្ដាលឲ្យចងគំនុំមាន៩យ៉ាងគឺៈ

១. ចងគំនុំដោយគិតថា " អ្នកនេះបានប្រព្រឹត្តហើយ នូវអំពើមិនជាប្រយោជន៍ដល់អញ"។

២. ចងគំនុំដោយគិតថា "អ្នកនេះកំពុងប្រព្រឹត្ត នូវអំពើមិនជាប្រយោជន៍ដល់អញ"។

៣. ចងគំនុំដោយគិតថា "អ្នកនេះ នឹងប្រព្រឹត្ត នូវអំពើ មិនជាប្រយោជន៍ដល់អញ"។

៤. ចងគំនុំដោយគិតថា "អ្នកនេះ បានប្រព្រឹត្តហើយ នូវអំពើមិនជាប្រយោជន៍ដល់បុគ្គលជាទីស្រឡាញ់ ជាទីគាប់ចិត្តរបស់អញ"។

៥. ចងគំនុំដោយគិតថា "អ្នកនេះកំពុងប្រព្រឹត្ត នូវអំពើមិនជាប្រយោជន៍ដល់បុគ្គលជាទីស្រឡាញ់ ជាទីគាប់ចិត្តរបស់អញ"។

៦. ចងគំនុំដោយគិតថា "អ្នកនេះ នឹងប្រព្រឹត្ត នូវអំពើ មិនជាប្រយោជន៍ដល់បុគ្គលជាទីស្រឡាញ់ ជាទីគាប់ចិត្តរបស់អញ"។

៧. ចងគំនុំដោយគិតថា "អ្នកនេះបានប្រព្រឹត្តហើយ នូវអំពើជាប្រយោជន៍ដល់បុគ្គលមិនជាទីស្រឡាញ់មិនជាទីគាប់ចិត្តរបស់អញ"។

៨. ចងគំនុំ ដោយគិតថា " អ្នកនេះ កំពុងប្រព្រឹត្ត នូវអំពើ ជា

ប្រយោជន៍ដល់បុគ្គលមិនជាទីស្រឡាញ់មិនជាទីគាប់ចិត្តរបស់អញ"។

៩. ចងគំនុំដោយគិតថា "អ្នកនេះនឹងប្រព្រឹត្ត នូវអំពើជាប្រយោជន៍ដល់បុគ្គលមិនជាទីស្រឡាញ់មិនជាទីគាប់ចិត្តរបស់អញ"។

ឧបក្កិលេសទី៣ ឈ្មោះ កោធៈ ប្រែថា "កំហឹង សេចក្តីក្រេវក្រោធពិរោធ ក្នុងអដ្ឋកថា មានសេចក្តីពន្យល់ថា កោធៈនេះ កើតឡើងអំពីអាឃាតវត្ថុ១០យ៉ាងណាមួយ។ អាឃាតវត្ថុ១០យ៉ាងនោះ ៩ខាងដើម គឺតាំងពីទី១ ដល់ទី៩ ដូចគ្នានឹងអាឃាតវត្ថុ៩យ៉ាងដែលសម្រាប់ឲ្យកើតព្យាបាទនោះដែរ ប្លែកតែត្រង់ទី១០ថា "ក្រេវក្រោធក្នុងហេតុមិនគួរក្រេវក្រោធ គឺមិនគួរខឹង ក៏ខឹងដែរ"។

សេចក្តីក្រោធនេះ កាលកើតឡើង ក្នុងសន្តានចិត្ត អ្នកណាហើយ រមែងញ៉ាំងចិត្តអ្នកនោះ អោយញាប់ញ័រ ឲ្យក្តៅអន្ទះអន្ទែង ឥតមានស្ងប់។ អ្នកក្រេវក្រោធនោះ កាលបើធ្វើអ្វីដោយកាយ ក៏ច្រើនតែជ្រុលជ្រួស ពានទៅលើខុស និយាយក៏ខុស គិតក៏មិនត្រូវ ព្រោះចិត្តអ្នកនោះ សៅហ្មងដោយសេចក្តីក្រោធ។

ឧបក្កិលេសទី៤ ឈ្មោះឧបនាហៈ ប្រែថា "ចងកំហឹងទុកក្នុងចិត្ត" បានសេចក្តីថា កំហឹង ដែលកើតឡើងហើយ មិនរសាយ មិនរលាយ រលត់បាត់ទៅវិញ ដោយសារ ឧបនាហៈ កើតឡើងក្នុងចិត្ត ឧបនាហៈនោះដូចជាខ្សែសម្រាប់ចងកំហឹងនេះទុកក្នុងចិត្ត កាលបើឧបនាហៈ មិនរលាយបាត់ទៅវិញ ហើយចេះតែមាន យូរៗទៅនឹងអាចនាំឲ្យគិតចងពៀរថែមទៀត ព្រោះឧបនាហៈនេះ រមែងធ្វើចិត្តឲ្យចងជាប់ក្នុងកំហឹង។

ឧបក្កិលេសទី៥ ឈ្មោះមក្ខៈ ប្រែថា "ការលុបគុណគេ"។ ក្នុង

អដ្ឋកថា មានសេចក្តីពន្យល់ថា មក្ខៈនេះ ជាបាបធម៌ សម្រាប់ញាំង
ឧបការគុណរបស់គ្រហស្ថ ឬបព្វជិតឲ្យវិនាស។

មែនពិត គ្រហស្ថដែលទីទាល់ក្រ បើមានអ្នកណាមួយ គេ
ជួយអនុគ្រោះ ជួយឧបត្ថម្ភអោយបានឋិតនៅក្នុងឋានៈដ៏ខ្ពង់ខ្ពស់ ក៏
ត្រឡប់បំបាត់ឧបការគុណគេចោល ដោយបញ្ចេញសំដី មានដើម
ថា "អ្នកឯងជួយធ្វើអ្វីឲ្យអញ"។ ចំណែកខាងបព្វជិតក៏ដែរ បើមាន
លោកអង្គណាមួយ ជាអាចារ្យ ឬជាឧបជ្ឈាយ៍ ជួយសង្គ្រោះ ដោយ
បច្ច័យ៤ មានស្បង់ចីពរជាដើម ឬសង្គ្រោះដោយការបង្ហាត់បង្រៀន
ឬក៏ជួយឲ្យបានសិក្សាបានចេះដឹង តាំងពីបព្វជិតនោះនៅជាសាម-
ណេររហូតមក លុះដល់មកខាងក្រោយមានពួកឥស្សរជន មានព្រះ
រាជា ជាដើមគោរពរាប់អាន ក៏ត្រឡប់ លែងធ្វើសេចក្តីគោរពកោត
ក្រែង ចំពោះអាចារ្យ និងឧបជ្ឈាយ៍ទាំងនោះ ហើយបញ្ចេញសំដី
មានដើមថា "លោកមានធ្វើអ្វីឲ្យខ្ញុំ"។ មក្ខៈនេះ រមែងធ្វើចិត្តឲ្យសៅ
ហ្មង មិនឲ្យស្គាល់គុណអ្នកដែលមានគុណលើខ្លួន។

ឧបក្កិលេសទី៦ ឈ្មោះបឡាសៈ ប្រែថា "វ៉ៃប្ញកប្រៀបផ្ទឹម"។
ក្នុងអដ្ឋកថាមានសេចក្តីពន្យល់ថា បឡាសៈនេះ កើតឡើងក្នុងសន្តាន
ចិត្តបុគ្គលណា តែងនាំបុគ្គលនោះ ឲ្យភ្លេចភ្លាំងភ័ន្តភាំងគំនិត គិតតែ
វ៉ៃប្ញក ប្រណាំងប្រជែង សំដែងគុណវិសេសរបស់ខ្លួន ឲ្យឃើញថា
មិនអន់ថយជាងអ្នកណា ព្រោះបឡាសៈនេះ រមែងធ្វើចិត្តឲ្យគិតតែ
ក្នុងការប្រណាំងប្រជែង។

ឧបក្កិលេសទី៧ ឈ្មោះឥស្សា ប្រែថា "សេចក្តីច្រណែនឈ្នា
នីស"។ ក្នុងអដ្ឋកថាមានសេចក្តីពន្យល់ថា ឥស្សានេះ កើតឡើងក្នុង

សន្តានចិត្តបុគ្គលណា តែងនាំបុគ្គលនោះ ឲ្យតិះដៀលនិន្ទា ចំពោះគុណសម្បត្តិរបស់អ្នកដទៃជាដរាប បើទុកជាដឹងថា គេចេះជាងខ្លួន គេមានទ្រព្យសម្បត្តិច្រើនជាងខ្លួន គេប្រព្រឹត្តល្អជាងខ្លួន ក៏មិនព្រមសរសើរ គិតតែពីពោលបន្តុះបង្អាប់ ធ្វើឲ្យគេអាប់អន់ មិនព្រមបណ្ដោយឲ្យគេបានប្រសើរថ្លៃថ្លាផងឡើយ។

ឧបក្កិលេសទី៨ ឈ្មោះមច្ឆរិយៈ ប្រែថា "សេចក្ដីកំណាញ់"។ ក្នុងអដ្ឋកថាមានសេចក្ដីពន្យល់ថា មច្ឆរិយៈនេះកើតឡើងក្នុងសន្តានចិត្តបុគ្គលណា តែងនាំបុគ្គលនោះ ឲ្យហួងហែងទ្រព្យសម្បត្តិរបស់ខ្លួនទុក មិនឲ្យសាយភាយដល់ជនដទៃឡើយ។ សេចក្ដីកំណាញ់នេះ ជាបាបធម៌មួយដ៏អាក្រក់ អាចបំផ្លាញកុសលទាំងឡាយ មានទានជាដើមឲ្យវិនាស។ មនុស្សដែលមានសេចក្ដីកំណាញ់ គេហៅថា មនុស្សចិត្តអាក្រក់ មនុស្សនេះនៅក្នុងទីណា ទីនោះដូចជាព្រៃផ្សៃ ឥតមានអ្នកដទៃទៅមករាប់រកជាគ្នីគ្នាឡើយ។

ឧបក្កិលេសទី៩ ឈ្មោះមាយា ប្រែថា "ការប្រព្រឹត្តលាក់ពុតបិទបាំងទោស"។ មាយានេះកើតឡើងក្នុងសន្តានបុគ្គលណា នាំឲ្យបុគ្គលនោះលាក់បិទបាំងទោសកំហុសរបស់ខ្លួន មិនឲ្យអ្នកដទៃដឹងឡើយ។ ការបិទបាំង លាក់ពុតអាក្រក់នេះ បើចេះតែមាននៅដរាបណា ដរាបនោះ ទោសកំហុសក៏ចេះតែចំរើនឡើង ឥតមានអន់ថយទៅ ព្រោះអ្នកមានមាយាអាងថា ឥតមានអ្នកណាដឹង ក៏ចេះតែហ៊ានប្រព្រឹត្តបំពានទៅលើផ្លូវខុសតទៅទៀត។

ឧបក្កិលេសទី១០ ឈ្មោះសាថេយ្យៈ ប្រែថា "ការអួតអាង ឬការអែបអប"។ សាថេយ្យៈនេះ កាលបើកើតឡើង ក្នុងសន្តានចិត្ត

បុគ្គលណា តែងនាំបុគ្គលនោះ ឲ្យចេះអែបអប ឡែបឡប អួតគុណសម្បត្តិដែលមិនមានក្នុងខ្លួន ហើយធ្វើអាការមិនឲ្យខុសនឹងអ្នកណាមួយឡើយ។ សូម្បីឥស្សរជន ក៏គង់ភ្លាត់គំនិត យល់ខុស ដោយការអែបអប ផ្គាប់ផ្គុន របស់អ្នកដែលមាន សាថេយ្យៈនោះដែរ ព្រោះមនុស្ស សាថេយ្យៈនោះ ប៉ិនប្រសប់ ខាងការអែបអបណាស់ ចេះចាក់បណ្តោយ ចេះលើកជើងមិនឲ្យទាស់ចិត្ត។

ឧបក្កិលេសទី១១ ឈ្មោះថម្ភៈ ប្រែថា "ការរឹងត្អឹង"។ ថម្ភៈនេះកើតឡើង ក្នុងសន្តានចិត្តបុគ្គលណា តែងនាំបុគ្គលនោះ ឲ្យទៅជាមនុស្សរឹងត្អឹង មិនមានសភាពរាបទាប។ មនុស្សដែលមានថម្ភៈនេះតែងបញ្ចេញអាការព្រហើនឈ្លានពាន ច្រឡោងខាម ក្រអឺតក្រឱងទោះបីឃើញវត្ថុឬបុគ្គលដែលគួរគោរព ក៏មិនសំដែងសេចក្តីគោរពព្រោះចិត្តនៃមនុស្សនោះសៅហ្មងដោយថម្ភៈ។

ឧបក្កិលេស ទី១២ ឈ្មោះ សារម្ភៈ ប្រែថា "ការប្រណាំងប្រជែង" សារម្ភៈនេះ កើតឡើងក្នុងសន្តានចិត្តបុគ្គលណា តែងនាំបុគ្គលនោះ ឲ្យប្រណាំងប្រជែង យកឈ្នះ មិនឲ្យអន់ថយជាងអ្នកឯទៀតចង់តែឲ្យបានលើសលប់ជាងគេ។ សារម្ភៈ ជាអកុសលក៏មាន ជាកុសលក៏មាន ប៉ុន្តែក្នុងទីនេះសំដៅយកសារម្ភៈជាអកុសលគឺប្រណាំងប្រជែងដោយអកុសលចិត្ត។

ឧបក្កិលេសទី១៣ឈ្មោះមានៈ ប្រែថា "សេចក្តីប្រកាន់ខ្លួន"។ មានៈនេះ កើតឡើងក្នុងសន្តានចិត្តបុគ្គលណា រមែងនាំបុគ្គលនោះឲ្យអាង ដល់គុណសម្បត្តិផ្សេងៗ គឺអាងថា ជាតិរបស់ខ្លួនខ្ពង់ខ្ពស់ជាងគេ ថាត្រកូលរបស់ខ្លួនប្រសើរជាងគេ ថាទ្រព្យសម្បត្តិរបស់ខ្លួន

មានច្រើនជាងគេ ថាចំណេះវិជ្ជារបស់ខ្លួនប្រសើរជាងគេ ថាបុណ្យស័ក្តិរបស់ខ្លួន ធំជាងគេដូច្នេះ ជាដើម ទើបចិត្តរបស់បុគ្គលនោះ ក៏ប៉ោងឡើង សំគាល់ថា ឥតមានអ្នកណាស្មើនឹងខ្លួន ហើយប្រកាន់ខ្លួនថា លើសលប់ជាងគេ។ អ្នកដែលមានមានៈ ច្រើនតែប្រកាន់ខ្លួន ធ្វើអាការឆ្មើងឆ្មៃ សំដែងឫកក្រអឺតក្រឱង ដរាបដល់ទាល់តែគេស្អប់ជុំវិញខ្លួន ដល់ទីបំផុត ច្រើនធ្លាក់ខ្លួនទៅក្នុងការហិនហោច ព្រោះតែអាស្រ័យមានៈនេះឯង។

ឧបក្កិលេស ទី១៤ ឈ្មោះ អតិមានៈ ប្រែថា "សេចក្តីប្រកាន់ខ្លួនហួសពេក"។ អតិមានៈនេះ កើតឡើងក្នុងសន្តានចិត្តរបស់បុគ្គលណានាំបុគ្គលនោះឲ្យប្រកាន់ខ្លួនលើសលប់ខ្លាំងជាងមានៈទៅទៀត អាចមើលងាយជនទាំងឡាយយ៉ាងខ្លាំងក្រៃលែង។

ឧបក្កិលេសទី១៥ ឈ្មោះមទៈ ប្រែថា "សេចក្តីស្រវឹង"។ មទៈនេះ កើតឡើងក្នុងសន្តានចិត្តរបស់បុគ្គលណា នាំបុគ្គលនោះអោយស្រវឹងវង្វេងងេងងោងភ័ន្តច្រឡំក្នុងចិត្តគិតមិនត្រូវតាមការណ៍ពិត។ គឺស្រវឹងក្នុងវ័យ សំគាល់ថាខ្លួននៅក្មេងជាដរាបឥតដឹងថា ខ្លួនចាស់ជរាគ្រាំគ្រាឡើយ ស្រវឹងក្នុងរូបកាយរបស់ខ្លួន សំគាល់ថា រូបកាយរបស់ខ្លួន ឥតមានជម្ងឺ ឈឺចាប់អ្វី ឥតដឹងថា រូបកាយរបស់ខ្លួន ត្រូវមានជម្ងឺ ឈឺចាប់ជានិច្ច ស្រវឹងក្នុងជីវិត សំគាល់ថា ខ្លួនចេះតែរស់នៅជាដរាបតទៅឥតដឹងថាខ្លួននឹងត្រូវស្លាប់ក្នុងថ្ងៃណាមួយឡើយ។

ឧបក្កិលេសទី១៦ឈ្មោះបមាទៈ ប្រែថា ការធ្វេសប្រហែស។ បមាទៈនេះ កើតឡើងក្នុងសន្តានចិត្តបុគ្គលណា តែងនាំបុគ្គលនោះឲ្យធ្វេសប្រហែស ភ្លេចស្មារតី។ បុគ្គល ដែលមានចិត្ត ប្រកបដោយ

បមាទៈនោះ រមែងមិនសម្បូណ៌ ដោយសតិ និងសម្បជញ្ញៈ ច្រើនភ្លេចខ្លួន មិនសូវនឹករឭកឃើញ ដល់កិច្ចការទាំងឡាយ ដែលមានប្រយោជន៍ និងឥតប្រយោជន៍ឡើយ។

បមាទៈនេះជាមេអកុសលមួយដ៏ធំសម្បើម សម្រាប់បំផ្លាញសត្វលោកឲ្យវិនាសចាកផលប្រយោជន៍គ្រប់យ៉ាង ទាំងក្នុងបច្ចុប្បន្នទាំងក្នុងបរលោក។ បើបមាទៈនេះមាននៅក្នុងសន្តានចិត្តដរាបណាដរាបនោះ បុគ្គលអ្នកប្រមាទត្រូវទទួលការខូចខាតចាកគុណសម្បត្តិជាដរាបដល់ទីបំផុតនឹងត្រូវខូចខាតចាកអត្តភាពជាមនុស្សផងទៀត បមាទៈនេះ រមែងធ្វើចិត្តឲ្យសៅហ្មង ឲ្យអាប់អួរ ឲ្យល្អក់ខ្វល់ជានិច្ច។

ឧបក្កិលេសទាំង ១៦យ៉ាង ដែលសំដែងដោយសង្ខេប ខាងលើនេះ សុទ្ធតែជាអកុសលធម៌ទាំងអស់ សម្រាប់ធ្វើចិត្តសត្វលោកឲ្យសៅហ្មង អោយងាកទៅរកបាប រកអកុសល ហើយនាំឲ្យសត្វទាំងឡាយ បានដល់នូវសេចក្ដីទុក្ខគ្រប់យ៉ាង ទាំងក្នុងបច្ចុប្បន្ន និងក្នុងអនាគត។

ដូច្នេះ ក្នុងឱកាសបុណ្យ រំលឹកព្រះពុទ្ធសាសនា គំរប់ ២៥សតវត្សនេះ សូមពួកពុទ្ធបរិស័ទ ពិនិត្យពិចារណាមើលក្នុងចិត្តរបស់ខ្លួន បើឃើញមាន ឧបក្កិលេសណាមួយ នៅជ្រកជ្រៀតក្នុងសន្តានចិត្តរបស់ខ្លួន គួរខំប្រឹង កំចាត់ចេញឲ្យបាន ដើម្បីនឹងធ្វើចិត្តឲ្យបានបរិសុទ្ធស្អាត ដែលជាហេតុ នឹងនាំឲ្យអស់លោកទាំងឡាយ បានទទួលផល គឺសេចក្ដីសុខគ្រប់យ៉ាងតទៅ។

ព្រះពោធិវង្ស ហួត តាត

# ២. ធម្មចក្កប្បវត្តនសុត្ត

## នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស។

វេលានេះ សូមសំដែង នូវធម្មចក្កប្បវត្តនសូត្រ តាមសមគួរដល់សតិ បញ្ញា ។ សូត្រនេះ ព្រះសម្មាសម្ពុទ្ធ ទ្រង់សំដែងជាដំបូងប្រោសបញ្ចវគ្គិយភិក្ខុ ព្រះសង្គីតិកាចារ្យ សង្គាយនារៀបរៀងទុកមកក្នុងគម្ពីរ សំយុត្តនិកាយ មហាវារវគ្គ ក្នុងសុត្តន្តបិដក មានពាក្យខាងដើមថា **ឯវម្មេ សុតំ ឯកំ សមយំ ភគវា ពារាណសិយំ វិហរតិ ឥសិបតនេ មិគទាយេ។** សូត្រនេះ ខ្ញុំបានស្តាប់មកហើយ យ៉ាងនេះ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងឥសិបតនមិគទាយវ័នទៀបក្រុងពារាណសី។ **តត្រ ខោ ភគវា បញ្ចវគ្គិយេ ភិក្ខូ អាមន្តេសិ** ក្នុងទីនោះឯង ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅពួក បញ្ចវគ្គិយភិក្ខុមក ទ្រង់ត្រាស់ថា **ទ្វេ មេ ភិក្ខវេ អន្តា បព្វជិតេន ន សេវិតព្វា** ម្នាលភិក្ខុទាំងឡាយ ធម៌ជ្រោកជ្រាកទាំងពីរយ៉ាងនេះ[១] អ្នកបួស មិនត្រូវសេព (គឺថាមិនត្រូវប្រើប្រាស់ឡើយ)។ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ប្រកាសបទនេះ ឮផ្សាយជ្រួតជ្រាប ទៅខាងក្រោម តាំងអំពី អវចីនរកឡើង ទៅលើរហូតដល់ភវគ្គព្រហ្ម ផ្សាយទៅគ្រប់លោកធាតុមួយម៉ឺន។

ក្នុងសម័យនោះ ព្រហ្មមានចំនួន ១៨កោដិ បានមកប្រជុំគ្នាហើយពេលនោះ ជាពេលព្រះអាទិត្យលិចទៅ ក្នុងទិសខាងលិច ព្រះចន្ទ្រពេញវង់រះឡើងក្នុងទិសខាងកើត ក្នុងថ្ងៃ១៥កើត ខែអាសាឍ

---

[១] សេចក្តីប្រតិបត្តិធូរពេកនិងតឹងពេក

ឆ្នាំរកា។ ព្រះសម្មាសម្ពុទ្ធ ទ្រង់សំដែងធម៌ជ្រោកជ្រាក ទាំងពីរយ៉ាង នេះតទៅថា **យោ ចាយំ កាមេសុ កាមសុខល្លិកានុយោគោ ហីនោ គម្មោ ចោថុជ្ជនិកោ អនរិយោ អនត្ថសញ្ហិតោ** ការប្រកប រឿយៗនូវកាមសុខ ក្នុងវត្ថុកាមនិងកិលេសកាម[១] ជារបស់ថោកទាប ជារបស់អ្នកស្រុក ជារបស់បុថុជ្ជន មិនមែនជារបស់អរិយបុគ្គល មិន ប្រកបដោយប្រយោជន៍ (គឺថាមិនអាស្រ័យនូវហេតុ ដែលនាំមកនូវ ប្រយោជន៍និងសេចក្ដីសុខ) ១ **យោ ចាយំ អត្តកិលមថានុយោគោ ទុក្ខោ អនរិយោ អនត្ថសញ្ហិតោ** ការប្រកបរឿយៗនូវសេចក្ដីលំបាក ដល់ខ្លួន (គឺថា ធ្វើខ្លួនឲ្យបានសេចក្ដីលំបាកក្រៃពេក ជារបស់នាំមក នូវសេចក្ដីទុក្ខ ដោយអំពើ ញុំាងខ្លួនឲ្យស្លាប់មានការផ្អែក ការដេក លើបន្លា ជាដើម) មិនមែនជារបស់ អរិយបុគ្គល មិនប្រកបដោយ ប្រយោជន៍១។

ព្រះអង្គសំដែងតទៅទៀតថា ម្នាលភិក្ខុទាំងឡាយ មជ្ឈិមា-បដិបទា (គឺសេចក្ដីប្រតិបត្តិជាកណ្ដាល មិនធូរពេកមិនតឹងពេក មិន ប៉ះពាល់ នូវធម៌ជ្រោកជ្រាក ទាំងពីរប្រការនោះ គឺថា ឃ្លាងអំពីធម៌ ជ្រោកជ្រាក ទាំងពីរយ៉ាងនោះ) ជាសេចក្ដីប្រតិបត្តិ ដែលតថាគត ត្រាស់ដឹងហើយ តែងធ្វើអោយកើតបញ្ញាចក្ខុ ធ្វើអោយកើតញាណ

---

[១] រូបសំឡេង ក្លិន រស និងផោដ្ឋព្វារម្មណ៍ ដែលជាទីប្រាថ្នា ជាទីស្រឡាញ់ ជាទីគាប់ចិត្ត ហៅថា វត្ថុកាម។ ឆន្ទរាគ សេចក្ដីពេញចិត្ត សេចក្ដីត្រេកអរ ក្នុងវត្ថុកាមនោះ ហៅថា កិលេសកាម។

គឺសេចក្តីដឹង[១] តែងប្រព្រឹត្តទៅដើម្បីរម្ងាប់នូវកិលេស ដើម្បីស្គាល់ច្បាស់នូវសច្ចៈ៤ ដើម្បីត្រាស់ដឹងនូវសច្ចៈ៤ ដើម្បីព្រះនិព្វាន។ ម្នាលភិក្ខុទាំងឡាយ មជ្ឈិមាបដិបទានោះតើដូចម្តេចដែលតថាគតត្រាស់ដឹងហើយ តែងធ្វើអោយកើតបញ្ញាចក្ខុ ធ្វើឲ្យកើតញាណ ប្រព្រឹត្តទៅដើម្បីរម្ងាប់នូវកិលេស ដើម្បីស្គាល់ច្បាស់នូវសច្ចៈ៤ ដើម្បីត្រាស់ដឹងនូវសច្ចៈ៤ ដើម្បីព្រះនិព្វាន? ព្រះអង្គសំដែងថា មជ្ឈិមាបដិបទានោះសំដៅយក មគ្គដ៏ប្រសើរ មានអង្គ៨គឺ **សម្មាទិដ្ឋិ** សេចក្តីយល់ត្រូវ១ **សម្មាសង្កប្បោ** សេចក្តីត្រិះរិះត្រូវ១ **សម្មាវាចា** ពាក្យសំដីត្រូវ១ **សម្មាកម្មន្តោ** ការងារត្រូវ១ **សម្មាអាជីវោ** ការចិញ្ចឹមជីវិតត្រូវ១ **សម្មាវាយាមោ** សេចក្តីព្យាយាមត្រូវ១ **សម្មាសតិ** សេចក្តីនឹករលឹកត្រូវ១ **សម្មាសមាធិ** ការតំកល់ចិត្តត្រូវ១។ ម្នាលភិក្ខុទាំងឡាយ មជ្ឈិមាបដិបទានេះឯង ដែលតថាគតត្រាស់ដឹងហើយ តែងធ្វើឲ្យកើតបញ្ញាចក្ខុ ធ្វើឲ្យកើតញាណ តែងប្រព្រឹត្តទៅដើម្បីរម្ងាប់នូវកិលេស ដើម្បីស្គាល់ច្បាស់ នូវសច្ចៈ៤ ដើម្បីត្រាស់ដឹងនូវសច្ចៈ៤ ដើម្បីព្រះនិព្វាន។ បន្ទាប់ពី មជ្ឈិមាបដិបទានេះ ព្រះអង្គ ទ្រង់សំដែងអរិយសច្ចៈ៤ប្រការថា ម្នាលភិក្ខុទាំងឡាយ សេចក្តីទុក្ខនេះឯង ហៅថា អរិយសច្ចៈ គឺការកើត ការចាប់កំណើត ការកើតប្រាកដនៃខន្ធទាំងឡាយ ជាទុក្ខមួយដែរហៅថា ជាតិទុក្ខ សេចក្តីគ្រាំគ្រានៃខន្ធជាទុក្ខមួយដែរ ហៅថា ជរាទុក្ខ សេចក្តីស្លាប់ ជាទុក្ខមួយដែរ ហៅថា មរណទុក្ខ សេចក្តីស្តាយស្រណោះក្តៅរំជួលខាងក្នុង ព្រោះសេចក្តី

---

[១] បញ្ញាចក្ខុ និងញាណទាំងពីរនេះ ជាពាក្យផ្លាស់ប្តូរគ្នា មានសេចក្តីតែ១។

វិនាស នៃញាតិសន្តាន ទ្រព្យធន ប្រពន្ធ កូន ជាដើម ជាទុក្ខមួយដែរ ហៅថា សោកទុក្ខ សេចក្តីខ្សឹកខ្សួលយំសង្រេងសង្រៃអាល័យញាតិសន្តាន ទ្រព្យធន ប្រពន្ធ កូន ជាដើម ដែលវិនាស ស្លាប់បាត់បង់ទៅ ជាទុក្ខមួយដែរ ហៅថា បរិទេវទុក្ខ ជម្ងឺដម្កាត់ កើតមានក្នុងកាយ ធ្វើអោយលំបាកកាយ ជាទុក្ខមួយដែរ ហៅថា ទុក្ខទុក្ខ សេចក្តីតូចចិត្ត លំបាកចិត្ត ជម្ងឺចិត្ត សេចក្តីឈឺក្នុងចិត្ត ជាទុក្ខមួយដែរហៅថា ទោមនស្សទុក្ខ ទោសៈ គឺសេចក្តីខឹងខ្លាំង កើតអំពី សេចក្តីលំបាកចិត្តខ្លាំងពេក ដោយហេតុវិនាសនៃញាតិសន្តានទ្រព្យធនប្រពន្ធកូនជាដើម រួមសេចក្តីថា តានតឹងក្នុងចិត្ត ចង្អៀតចង្អល់ចិត្តជាទុក្ខមួយដែរ ហៅថាឧបាយាសទុក្ខ ការជួបប្រសព្វ ឬជួបជុំដោយសត្វ និងសង្ខារមិនជាទីស្រឡាញ់ជាទុក្ខមួយដែរ ហៅថាអប្បិយសម្បយោគទុក្ខ ការព្រាត់ប្រាសនិរាសចាកសត្វ[១] និងសង្ខារ[២] ជាទីស្រឡាញ់ជាទុក្ខមួយដែរ ហៅថា បិយវិប្បយោគទុក្ខ បុគ្គលប្រាថ្នា នូវវត្ថុណាហើយមិនបាននូវវត្ថុនោះ អំពើនោះជាទុក្ខមួយដែរហៅថា ឥច្ឆិតាលាភទុក្ខ[៣] បើនិយាយដោយសង្ខេប ឧបាទានក្ខន្ធទាំងប្រាំជាទុក្ខ ហៅថា ឧបាទានក្ខន្ធទុក្ខ[៤]។ ចប់ ទុក្ខសច្ច

---

[១] សត្វសំដៅយកមនុស្សនិងតិរច្ឆានជាដើម ដែលជាសត្រូវប្រាថ្នាបំផ្លាញឲ្យវិនាស មិនប្រាថ្នានូវប្រយោជន៍និងសេចក្តីសុខជាដើម។

[២]សង្ខារបានដល់រូបសម្លេងក្លិនរសនិងផោដ្ឋព្វារម្មណ៍ដែលមិនជាទីគាប់ចិត្ត។

[៣] ទុក្ខព្រោះមិនបានដូចសេចក្តីប្រាថ្នា។

[៤] ខន្ធដែលប្រកបដោយអាសវឧបាទាន បើហៅថាខន្ធទទេ ជាសាធារណៈទូទៅដល់ខន្ធបុថុជ្ជន សេក្ខបុគ្គល អសេក្ខបុគ្គល។

មួយទៀត ម្នាលភិក្ខុទាំងឡាយ ទុក្ខសមុទយោ ហេតុដែលនាំឲ្យកើតសេចក្តីទុក្ខនេះ ហៅថា អរិយសច្ច បានខាងតណ្ហា ជាធម្មជាតិ ធ្វើនូវភពថ្មីជាប្រក្រតី ប្រកបដោយសេចក្តី ត្រេកត្រអាលត្រេកអរក្នុងភពនោះៗ ឬក្នុងអារម្មណ៍នោះៗ គឺកាមតណ្ហា១ ភវ-តណ្ហា១ វិភវតណ្ហា១[១] ។ ពាក្យថាកាមតណ្ហាគឺ សេចក្តីត្រេកអរប្រព្រឹត្តទៅក្នុងកាមគុណទាំង៥។ ពាក្យថា ភវតណ្ហា បានខាងសេចក្តីត្រេកអរ ក្នុងរូបភព និងអរូបភព ប្រកបដោយ សេចក្តីអាល័យក្នុងឈាន និងសស្សតទិដ្ឋិ[២]។ វិភវតណ្ហា បានដល់សេចក្តីត្រេកអរប្រកបដោយឧច្ឆេទទិដ្ឋិ[៣]។

**ចប់ សមុទយសច្ច**

---

[១] តណ្ហា៣ប្រការគឺ កាមតណ្ហា១ ភវតណ្ហា១ វិភវតណ្ហា១ បណ្តាតណ្ហាទាំង៣ប្រការនោះ ក្នុងតណ្ហាមួយៗមានអារម្មណ៍ប្រាំមួយៗ ស្មើគ្នាគឺរូបារម្មណ៍១ សទ្ទារម្មណ៍១ គន្ធារម្មណ៍១ រសារម្មណ៍១ ផោដ្ឋព្វារម្មណ៍១ ធម្មារម្មណ៍១ រាប់តាមអារម្មណ៍ (យក៣គុណ៦) បាន១៨ហៅថាតណ្ហា១៨។ តណ្ហាទាំង១៨នោះចាត់ជាអតីត១៨ អនាគត១៨ បច្ចុប្បន្ន១៨ បូករួមជា(យក៣គុណ១៨)ជា៥៤ ហៅថា តណ្ហា៥៤។ តណ្ហា៥៤នោះ ចាត់ជាខាងក្នុង៥៤ ខាងក្រៅ៥៤បូករួមជា (យក២គុណ៥៤)ជា១០៨ ហៅថាតណ្ហា១០៨ដោយពិស្តារ។ អភិធម្មត្ថវិភាវិនី)។

[២] ការយល់ឃើញថា សត្វស្លាប់ទៅកើតទៀត តែទៀងទាត់មិនប្រែប្រួល គឺថា សត្វណាធ្លាប់មានអាយុវែង ក៏ចេះតែវែងជាដរាប សត្វណាធ្លាប់មានអាយុខ្លី ក៏ចេះតែខ្លីដរាបដូច្នេះជាដើម។

[៣] ការយល់ឃើញថា សត្វស្លាប់ទៅហើយសូន្យមិនកើតទៀត។

មួយទៀត ម្នាលភិក្ខុទាំងឡាយ ទុក្ខនិរោធោ សេចក្តីរលត់នៃទុក្ខនេះឯងហៅថាអរិយសច្ច គឺថា សេចក្តីសាបរលាបទៅនិងសេចក្តីរលត់ទៅដោយមិនសល់នៃតណ្ហានោះឯង ឬថាការលះចោល គ្រវែងចោល ជំរុះចោល នូវតណ្ហានោះឯង ឬថា សេចក្តីមិនអាល័យ ក្នុងតណ្ហានោះឯង។

ចប់ និរោធសច្ច

មួយវិញទៀត ម្នាលភិក្ខុទាំងឡាយ ទុក្ខនិរោធគាមិនីបដិបទា សេចក្តីប្រតិបត្តិ ញ៉ាំងសត្វអោយដល់នូវសេចក្តីរលត់នៃទុក្ខនេះឯងហៅថា អរិយសច្ច បានខាងមគ្គដ៏ប្រសើរ មានអង្គ៨ គឺ សម្មាទិដ្ឋិ សេចក្តីយល់ត្រូវ១ សម្មាសង្កប្បោ សេចក្តីត្រិះរិះត្រូវ១ សម្មាវាចា ពាក្យសំដីត្រូវ១ សម្មាកម្មន្តោ ការងារត្រូវ១ សម្មាអាជីវោ ការចិញ្ចឹមជីវិតត្រូវ១ សម្មាវាយាមោ សេចក្តីព្យាយាមត្រូវ១ សម្មាសតិ ការនឹករលឹកត្រូវ១ សម្មាសមាធិ ការដំកល់ចិត្តត្រូវ១។

បន្ទាប់ពីនេះ ទ្រង់សំដែងពីការត្រាស់ដឹង ក្នុងអរិយសច្ច ជាធម៌កំបាំង ដែលព្រះអង្គមិនដែលបានស្តាប់ បានឮគេនិយាយដល់ម្តងសោះឡើយ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺកើតឡើងហើយ ដល់តថាគត ក្នុងធម៌ទាំងឡាយដែលតថាគតមិនដែលស្តាប់ មិនដែលឮថា "សេចក្តីទុក្ខនេះហៅថាអរិយសច្ច"។ ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺកើតឡើងហើយ ដល់តថាគតក្នុងធម៌ទាំងឡាយដែលតថាគតមិនដែល

បានស្តាប់ មិនដែលឮថា "សេចក្តីទុក្ខនោះឯង ហៅថា អរិយសច្ច ដែលបុគ្គលគប្បីកំណត់ដឹង"។ ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើង ហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើត ឡើងហើយ ពន្លឺកើតឡើងហើយ ដល់តថាគត ក្នុងធម៌ទាំងឡាយ ដែលតថាគត មិនដែលស្តាប់ មិនដែលឮថា "សេចក្តីទុក្ខនោះឯង ហៅថា អរិយសច្ចដែលបុគ្គលកំណត់ដឹងហើយ"។

ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើង ហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺកើតឡើង ហើយ ដល់តថាគត ក្នុងធម៌ទាំងឡាយដែលតថាគតមិនដែលស្តាប់ មិនដែលឮថា "ហេតុនាំឲ្យកើតសេចក្តីទុក្ខនេះ ហៅថាអរិយសច្ច"។ ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺកើតឡើងហើយ ដល់តថាគត ក្នុងធម៌ទាំងឡាយដែលតថាគតមិនដែលស្តាប់ មិន ដែលឮថា "ហេតុនាំឲ្យកើតសេចក្តីទុក្ខនោះឯង ហៅថា អរិយសច្ច ដែលបុគ្គលគប្បីលះបង់"។

ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើង ហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺកើតឡើង ហើយ ដល់តថាគតក្នុងធម៌ទាំងឡាយដែលតថាគតមិនដែលស្តាប់ មិនដែលឮថា ហេតុនាំឲ្យកើតសេចក្តីទុក្ខនោះឯង ហៅថាអរិយសច្ច ដែលបុគ្គលលះបង់ហើយ"។

ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើង ហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺកើតឡើង

ហើយ ដល់តថាគតក្នុងធម៌ទាំងឡាយដែលតថាគតមិនដែលស្តាប់ មិនដែលឮថា "សេចក្តីរលត់នៃទុក្ខនេះ ហៅថាអរិយសច្ច"។ ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺកើតឡើងហើយ ដល់តថាគត ក្នុងធម៌ទាំងឡាយដែលតថាគតមិនដែលស្តាប់ មិនដែលឮថា "សេចក្តីរលត់ នៃទុក្ខនេះឯង ហៅថាអរិយសច្ច ដែលបុគ្គលគប្បីធ្វើឲ្យជាក់ច្បាស់"។

ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺកើតឡើងហើយ ដល់តថាគតក្នុងធម៌ទាំងឡាយដែលតថាគតមិនដែលស្តាប់ មិនដែលឮថា "សេចក្តីរលត់នៃទុក្ខនោះឯងហៅថា អរិយសច្ច ដែលបុគ្គលធ្វើអោយជាក់ច្បាស់ហើយ"។

ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺកើតឡើងហើយ ដល់តថាគត ក្នុងធម៌ទាំងឡាយដែលតថាគតមិនដែលស្តាប់ មិនដែលឮថា "នេះ ជាសេចក្តីប្រតិបត្តិ ញុំាងសត្វ ឲ្យដល់នូវសេចក្តីរលត់ នៃទុក្ខ ហៅថា អរិយសច្ច[១]"។ ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺកើតឡើងហើយ ដល់តថាគតក្នុងធម៌ទាំងឡាយដែលតថាគតមិនដែលស្តាប់ មិនដែលឮថា "សេចក្តីប្រតិបត្តិ ញុំាងសត្វអោយដល់នូវសេចក្តីរលត់ទុក្ខនោះឯងហៅថាអរិយសច្ច ដែល

[១] នេះជាបរិវដ្តទី១ ក្នុងមគ្គសច្ច។

បុគ្គលគប្បីចំរើន[១]”។

ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺកើតឡើងហើយ ដល់តថាគតក្នុងធម៌ទាំងឡាយដែលតថាគតមិនដែលស្ដាប់មិនដែលឮថា "សេចក្ដីប្រតិបត្តិ ញុំាំងសត្វ ឲ្យដល់នូវសេចក្ដីរលត់ទុក្ខនោះឯង ហៅថាអរិយសច្ចដែលបុគ្គលចំរើនហើយ[២]”។ ម្នាលភិក្ខុទាំងឡាយ ការឃើញគឺការដឹងតាមពិត មានបរិវដ្ដ៣ មានអាការ ១២ ប្រការយ៉ាងនេះ[៣] ក្នុងអរិយសច្ចទាំង៤ នៅមិនទាន់បរិសុទ្ធច្បាស់លាស់ដល់តថាគតដរាបណា ម្នាលភិក្ខុទាំងឡាយ តថាគតមិនទាន់បានឈ្មោះថា បានត្រាស់ដឹង យល់ច្បាស់នូវអនុត្តរសម្មាសម្ពោធិញ្ញាណក្នុងលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោកក្នុងពពួកសត្វ ព្រមទាំងសមណៈនិងព្រាហ្មណ៍ ព្រមទាំងទេវតា និងមនុស្សដ៏សេសដរាបនោះ។ ម្នាលភិក្ខុទាំងឡាយ សេចក្ដីឃើញ គឺសេចក្ដីដឹងតាមពិត មានបរិវដ្ដ៣ មានអាការ ១២ប្រការ នេះ ក្នុងអរិយសច្ចទាំង៤នេះ បរិសុទ្ធច្បាស់លាស់ដល់តថាគតក្នុងកាលណា ម្នាលភិក្ខុទាំងឡាយ តថាគត ទើបបានឈ្មោះថា ត្រាស់ដឹងយល់

---

[១] នេះជាបរិវដ្ដទី២ ក្នុងមគ្គសច្ច។

[២] នេះជាបរិវដ្ដទី៣ក្នុងមគ្គសច្ច។ សច្ចទាំង៣ខាងដើម ក៏មានទំនងដូចគ្នានឹងមគ្គសច្ចនេះដែរ។

[៣]បរិវដ្ដ៣គឺទី១ឈ្មោះសច្ចញ្ញាណ សេចក្ដីដឹងថាសច្ចៈ ទី២ឈ្មោះកិច្ចញ្ញាណ សេចក្ដីដឹងថាគប្បីធ្វើ ទី៣ឈ្មោះកតញ្ញាណ សេចក្ដីដឹងថាធ្វើរួចហើយ។ ក្នុងសច្ចៈនីមួយៗមានបី បូករួមទាំងអស់ជាអាការ១២។

ច្បាស់ អនុត្តរសម្មាសម្ពោធិញ្ញាណ ក្នុងលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណៈ និងព្រាហ្មណ៍ ព្រមទាំងទេវតានិងមនុស្សដ៏សេសក្នុងកាលនោះ។

ម្យ៉ាងទៀត សេចក្ដីឃើញគឺសេចក្ដីដឹង កើតឡើងដល់តថាគតថា "វិមុត្តិ គឺអរហត្តផល របស់អាត្មាអញ ឥតមានកំរើកឡើយ ជាតិនេះជាទីបំផុតហើយ ឥឡូវនេះ ភពថ្មីឥតមានតទៅទៀតទេ"។

លុះព្រះមានព្រះភាគ ទ្រង់ត្រាស់ពាក្យនេះហើយ ពួកភិក្ខុបញ្ចវគ្គិយមានសេចក្ដីត្រេកអររីករាយខ្លាំង ចំពោះភាសិតនៃព្រះមានព្រះភាគ។ កាលដែលព្រះអង្គ កំពុងសំដែង វេយ្យាករណ៍[១] នេះ ធម្មចក្ខុ គឺសោតាបត្តិមគ្គ ប្រាសចាកធូលី គឺកិលេស មានរាគៈ ជាដើម ប្រាសចាកមន្ទិល គឺកិលេសមានរាគៈជាដើម ក៏កើតឡើងដល់ព្រះកោណ្ឌញ្ញដ៏មានអាយុថា "ធម្មជាតណាមួយ មានការកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះ ក៏មានសេចក្ដីរលត់ទៅ ជាធម្មតាដែរ"។ កាលដែលព្រះមានព្រះភាគ សំដែងធម្មចក្កចប់ហើយ ពួកទេវតានៅលើផែនដី ហៅថា ភុម្មទេវតា ក៏បន្លឺសំឡេងយ៉ាងខ្លាំងថា "ព្រះអនុត្តរធម្មចក្កនេះឯង ព្រះមានព្រះភាគឲ្យប្រព្រឹត្តទៅហើយ គឺថាបង្វិលឲ្យវិលទៅហើយ ក្នុងព្រៃឥសិបតនមិគទាយវ័ន ទៀបក្រុងពារាណសី ទោះបីសមណៈក្ដី ព្រាហ្មណ៍ក្ដី ទេវតាក្ដី មារក្ដី ព្រហ្មក្ដី បុគ្គលណាមួយក្ដីក្នុងលោក មិនអាចនឹងបដិវត្តបង្វិលឲ្យវិលទៅបាន

---

[១] ពុទ្ធវចនៈមានអង្គ៩ គឺ សុត្ត១ គេយ្យ១ វេយ្យាករណៈ១ គាថា១ ឧទាន១ ឥតិវុត្តកៈ១ ជាតកៈ១ អព្ភូតធម្ម១ វេទល្ល១ ចំណែក ធម្មចក្កប្បវត្តនសូត្រនេះរាប់ចូលជាវេយ្យាករណៈ ជាពាក្យរាយឥតមានគាថា។

ដូចព្រះអង្គឡើយ”។ ពួកទេវតានៅក្នុងឋានចាតុម្មហារាជិកា បានឮសំឡេងភុម្មទេវតាហើយ ក៏បន្លឺសំឡេងឡើងដូចគ្នា។ ពួកទេវតានៅក្នុងឋានតាវត្តឹង្ស បានឮសំឡេង ចាតុម្មហារាជិកាទេវតាហើយ ក៏បន្លឺសំឡេងឡើងដូចគ្នា។ពួកទេវតានៅក្នុងឋានយាមាបានឮសំឡេងតាវត្តឹង្សទេវតាហើយ ក៏បន្លឺសំឡេងឡើងដូចគ្នា។ ពួកទេវតានៅក្នុងឋានតុសិត បានឮសំឡេង យាមាទេវតាហើយ ក៏បន្លឺសំឡេងឡើងដូចគ្នា។ ពួកទេវតានៅក្នុងឋាននិម្មានរតី បានឮសំឡេងតុសិតទេវតាហើយ ក៏បន្លឺសំឡេងឡើងដូចគ្នា។ ពួកទេវតានៅក្នុងឋានបរនិម្មិត-វសវត្តី បានឮសំឡេងនិម្មានរតីទេវតាហើយ ក៏បន្លឺសំឡេងឡើងដូចគ្នា។ ទេវតាទាំងឡាយជាពួកនៃព្រហ្ម បានឮសំឡេងបរនិម្មិតវសវត្តីទេវតាហើយ ក៏បន្លឺសំឡេងឡើងដូចគ្នាថា “ព្រះអនុត្តរធម្មចក្កនេះឯង ព្រះមានព្រះភាគទ្រង់ឲ្យប្រព្រឹត្តទៅហើយ គឺថាបង្វិលឲ្យវិលទៅហើយ ក្នុងឥសិបតនមិគទាយវ័ន ទៀបក្រុងពារាណសី ទោះបីសមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី បុគ្គលណាមួយក្តីក្នុងលោក មិនអាចនឹងបដិវត្តបង្វិលឲ្យវិលទៅបានដូចព្រះអង្គឡើយ”។ សំឡេងកងរំពង ផ្សាយឡើងទៅរហូតដល់ ព្រហ្មលោកនាយ ក្នុងខណៈនោះភ្លាមៗដូច្នេះឯង។ លោកធាតុមានចំនួន១ម៉ឺន ក៏កក្រើកអំពើកញ្ជាប់ញ័រ។ ទាំងពន្លឺរស្មី[១]ដ៏លើសលប់ប្រមាណមិនបានក៏កើតប្រាកដក្នុងលោក កន្លងហួសទេវានុភាពនៃទេវតាទាំងឡាយ។

---

[១] ពន្លឺនៃសព្វញ្ញុតញ្ញាណ (អដ្ឋកថា)។

គ្រានោះព្រះមានព្រះភាគទ្រង់បន្លឺឡើងនូវឧទាន[១] ថា "ឱ! កោណ្ឌញ្ញបានដឹងច្បាស់ហើយ! ឱ! កោណ្ឌញ្ញ បានដឹងច្បាស់ហើយ! ពាក្យដូច្នេះ នេះជាប់បានជានាម នៃព្រះកោណ្ឌញ្ញ ដ៏មានអាយុ ថា "អញ្ញាកោណ្ឌញ្ញ[២]" ដូច្នេះជាប់តរៀងមកដល់សព្វថ្ងៃនេះឯង។

**ចប់ ធម្មចក្កប្បវត្តនសូត្រ។**

ព្រះឃោសធម្ម ម៉ឹង សែស



[១] កាលដែលព្រះអង្គបន្លឺនូវឧទាននេះសំឡេងឮផ្សាយទៅដល់លោកធាតុមានចំនួនមួយម៉ឺន។

[២] បាលីខ្លះថា អញ្ញាតកោណ្ឌញ្ញក៏មាន ព្រោះព្រះពុទ្ធដីកាថា អញ្ញាសិ ប្រែថា បានដឹងហើយ ជាកិរិយាអាខ្យាតអតីតកាល ដាក់មកជាបទ នាម ជា អញ្ញាតកោណ្ឌញ្ញ យកតបច្ច័យមកប្រើជានាមឲ្យជាអតីតកាលដូចគ្នា។

# ៣. គោលព្រះពុទ្ធសាសនា៣យ៉ាង

## នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស។

សព្វបាបស្ស អករណំ កុសលស្សូបសម្បទា
សចិត្តបរិយោទបនំ ឯតំ ពុទ្ធានសាសនំ។

វេលានេះ សូមសំដែងអំពីគោលព្រះពុទ្ធសាសនា ដែលមានមកក្នុងគម្ពីរ ធម្មបទ ខុទ្ទកនិកាយ ដូចសេចក្ដីប្រែ តាមពុទ្ធភាសិត ព្រមទាំងអធិប្បាយពង្រីកតទៅនេះ ៖

ការមិនធ្វើបាបទាំងពួង១ ការញុំាងកុសលឲ្យកើត១ ការញុំាងចិត្តរបស់ខ្លួនអោយផូរផង់១ គោលទាំងបីនេះជាសាសនានៃព្រះពុទ្ធទាំងឡាយ។

គោលព្រះពុទ្ធសាសនា៣យ៉ាងនេះហៅថាពុទ្ធឱវាទ៣យ៉ាងក៏បាន ថាអនុសាសនី៣យ៉ាងក៏បាន។

ព្រះសម្មាសម្ពុទ្ធទាំងឡាយ ដែលបរិនិព្វានកន្លងទៅហើយក្ដី ដែលនឹងត្រូវត្រាស់ដឹង ក្នុងកាលអនាគតក្ដី សុទ្ធតែទ្រទ្រង់ នូវមហាករុណាទិគុណ ប្រកបដោយអត្តសម្បត្តិ (គុណជាចំណែករបស់ព្រះអង្គ) និងបរហិតសម្បត្តិ (គុណជាចំណែកដល់សព្វសត្វដទៃ) ព្រះអង្គជាគរុដ្ឋានីយៈនៃទេវតានិងមនុស្សទាំងឡាយ ទ្រង់សំដែងធម៌បញ្ញត្តវិន័យ ដើម្បីទូន្មាន ប្រៀនប្រដៅសត្វលោក ដោយព្រះហឫទ័យ ដ៏បរិសុទ្ធ សំដែងប្រាប់ហេតុផល នៃសេចក្ដីសុខ ទុក្ខ ដើម្បីអ្នកស្ដាប់អ្នករៀន ពិចារណាឲ្យឃើញច្បាស់ជឿដោយខ្លួនឯង តាមលំអាននៃ

ពុទ្ធឱវាទដូចគ្នាគ្រប់ព្រះអង្គ ឥតមានដាក់អាជ្ញា បង្គាប់បញ្ជារឲ្យជឿឡើយ។

ព្រះពុទ្ធឱវាទគ្រប់ព្រះអង្គ ទោះបីចែកចេញជា គម្ពីរ ជាវគ្គ ជានិទាន ជាមាតិកាធម៌ច្រើនក៏ដោយ គង់សង្គ្រោះចូលក្នុងគោល៣យ៉ាង មានការមិនធ្វើបាបទាំងពួងជាដើម ដូចសេចក្តីអធិប្បាយចំពោះគោលនីមួយៗតទៅនេះ៖

១. ***សព្វបាបស្ស អករណំ*** ការមិនធ្វើបាបទាំងពួង។ គោលនៃពុទ្ធសាសនាជាដំបូងនេះ ជាវិធីប្រៀនប្រដៅសត្វលោកមិនឲ្យធ្វើបាប។ ពាក្យថា "បាប" នេះ ដោយទូទៅបានដល់ការប្រព្រឹត្តអាក្រក់ចំពោះជីវិតមនុស្សសត្វ ចំពោះទ្រព្យសម្បត្តិ និងទីកន្លែងរបស់អ្នកដទៃ ប៉ុន្តែការប្រព្រឹត្តអាក្រក់ទាំងនោះ កាលបើកំណត់តាមសមុដ្ឋាន (កំណើតជាទីកើត) ដែលជាភស្តុតាង មាន៣យ៉ាងគឺ ការប្រព្រឹត្តអាក្រក់កើតដោយកាយ ហៅថា កាយទុច្ចរិត១ ការប្រព្រឹត្តអាក្រក់ដោយវាចា ហៅថា វចីទុច្ចរិត១ ការប្រព្រឹត្តអាក្រក់ដោយចិត្ត ហៅថា មនោទុច្ចរិត១។

ពាក្យថា "បាប" នេះ ប្រែថា "អំពើអាក្រក់ ការដល់នូវសេចក្តីវិនាស ការរក្សាទុកនូវសេចក្តីវិនាស ជាគ្រឿងដល់នូវសេចក្តីមិនចំរើន គ្រឿងផ្តល់នូវទុគ្គតិ"។

ពាក្យថា "បាប" សំដៅយកហេតុក៏មាន សំដៅយកផលក៏មាន បាបគ្រោតគ្រាតក៏មាន បាបយ៉ាងកណ្តាលក៏មាន បាបយ៉ាងល្អិតក៏មាន។ ការប្រព្រឹត្តអាក្រក់ដោយកាយ វាចា ចិត្ត ចំពោះមនុស្សសត្វ

ឬទ្រព្យសម្បត្តិអ្នកដទៃ ឈ្មោះថា បាបជាហេតុ ផលជាទុក្ខដែលនាំឲ្យបុគ្គលអ្នកប្រព្រឹត្តអាក្រក់ ក្តៅក្រហាយ រោលរាល ឈ្មោះថាបាបជាផល។ អាកប្បកិរិយាអាក្រក់ ដោយកាយ វាចា ដែលអាចហ៊ានពុះពារ ប្រហារជីវិតមនុស្សសត្វជាដើម ដោយចេញមុខ ឥតអៀនខ្មាស់សោះ ឈ្មោះថា បាបគ្រោតគ្រាត ការប្រព្រឹត្តអាក្រក់ ដោយកាយ វាចា ដោយលាក់លៀម ឈ្មោះថា បាបយ៉ាងកណ្តាល ការប្រព្រឹត្តអាក្រក់ដោយផ្លូវចិត្ត ដែលស្ងាត់ កំបាំង កម្រនឹងឃើញជាក់ស្តែងបាន ឈ្មោះថា បាបយ៉ាងល្អិត។

បាបនេះ មានស័ព្ទសំរាប់និយាយផ្លាស់ប្តូរគ្នាច្រើនយ៉ាង គឺ ទុច្ចរិត (ការប្រព្រឹត្តអាក្រក់) អកុសលៈ (អំពើមិនល្អ មិនស្អាត) អករណីយៈ (អំពើដែលមិនត្រូវធ្វើ) វិសមចរិយា (ការប្រព្រឹត្តរំលោភ) អព្រហ្មចរិយៈ (ការប្រព្រឹត្តមិនប្រសើរ)។ បាបនេះ បើកំណត់តាមគន្លងនៃអំពើមាន១០យ៉ាង ដែលហៅថា អកុសលកម្មបថ១០ មានការសម្លាប់សត្វ លួចទ្រព្យអ្នកដទៃជាដើម មានការយល់ឃើញខុសជាទីបំផុត។ ការប្រព្រឹត្តតាមគន្លងនៃអកុសលកម្ម ដែលបុគ្គលណាធ្វើហើយក្តី កំពុងធ្វើក្តី ជាហេតុឲ្យមានកេរ្តិ៍ឈ្មោះអាក្រក់ប្រចាំជីវិតរបស់បុគ្គលនោះ តាំងអំពីកាលដែលខ្លួនរស់នៅ រហូតដល់កាលដែលស្លាប់ហើយ។ ការប្រព្រឹត្តអាក្រក់ ដោយត្រៃទ្វារ ទោះបីក្នុងទីស្ងាត់កំបាំង អំពីអ្នកដទៃក្តី ក្នុងទីចំពោះមុខអ្នកដទៃក្តី ក៏ឈ្មោះថាអំពើបាប។

អ្នកធ្វើបាបច្រើនតែចូលចិត្តថា "ការធ្វើបាបក្នុងទីស្ងាត់កំបាំង

ទុកថាជាផ្លូវគេចខ្លួនមួយដែរ" ប៉ុន្តែបើតាមពិតនោះ ការប្រព្រឹត្តិអាក្រក់ ឬល្អក្នុងលោកនេះ មិនចេះស្ងាត់កំបាំងទេ គឺគ្រាន់តែស្ងាត់កំបាំង អំពីអ្នកដទៃ ដោយហេតុគេមិនបានដឹង មិនបានឮប៉ុណ្ណោះ ប៉ុន្តែត្រូវ ខ្លួនឯងទទួលដឹងមុនជាដរាប បើយ៉ាងនេះ តើនឹងឈ្មោះថា ធ្វើបាប ក្នុងទីស្ងាត់ដូចម្ដេចកើត? បុគ្គលអ្នកធ្វើបាប កាលបើនឹកឃើញ តែង រិះគន់ តិះដៀលខ្លួនឯងថា ជាមនុស្សប្រព្រឹត្តអាក្រក់ ថោកទាប លុះ ពេលមរណកាលជិតមកដល់ តែងកើតសេចក្ដីក្ដៅក្រហាយ ស្ដាយ ក្រោយ ដោយឃើញនិមិត្តអាក្រក់មកបណ្ដាលឲ្យឃើញ នាំឲ្យភិត ភ័យញាប់ញ័រក៏មាន ឃើញខ្លួនឯងធ្វើបាបដោយខ្លួនឯង ដែលនាំឲ្យ មានវិប្បដិសារី ក៏មាន។ ករណីដូចរៀបរាប់មក ដោយសង្ខេបនេះ ទើបព្រះមានព្រះភាគទ្រង់សំដែងថា "ការធ្វើបាបរាប់ថាជាអំពើអាក្រក់ ដែលបុគ្គល អ្នកមានបំណងល្អ ត្រូវលះចេញឲ្យជ្រះស្រឡះ ព្រោះ អំពើបាប ពុំមែនជាអំពើនាំមកនូវសេចក្ដីសុខត្រជាក់ចិត្តឡើយ សុទ្ធ តែ ជាអំពើនាំឲ្យបុគ្គលអ្នកធ្វើ មានសេចក្ដីទុក្ខ ក្ដៅក្រហាយតាំងអំពី មានជីវិតរស់នៅ រហូតដល់ពេលស្លាប់ទៅក៏ត្រូវទៅកើតក្នុងអបាយ ភូមិទាំង៤ណាមួយថែមទៀតសមដូចពុទ្ធភាសិតថា"**ទុក្ខោ បាបស្ស ឧច្ចយោ** ការសន្សំនូវបាប ជាហេតុនាំមកនូវទុក្ខ **បាបានំ អករណំ សុខំ** ការមិនធ្វើនូវបាបទាំងឡាយ ជាហេតុនាំមកនូវសុខ"។ ពុទ្ធភា- សិតនេះ គួរឃើញថា ការប្រព្រឹត្តឈ្លានពាន ទៅលើជីវិត ទ្រព្យ សម្បត្តិ ទីកន្លែង និងទឹកដីរបស់អ្នកដទៃ ឈ្មោះថាជាការទំលាយនូវ កម្មសិទ្ធ ឬបំបាត់សេរីភាពរបស់អ្នកដទៃ។ ការមិនធ្វើបាប ឈ្មោះថា

ជាអំពើល្អ រាប់ថាជាមនុស្សធម៌ ជាអំពើអោយអភ័យដល់ជីវិត ទ្រព្យសម្បត្តិទីកន្លែងនិងទឹកដីរបស់អ្នកដទៃ ឈ្មោះថាជាអំពើដើម្បីសេចក្តីសុខចំរើនដល់អ្នកដទៃផង ដល់ខ្លួនផង។ ការប្រព្រឹត្តិល្អ ដោយកាយ វាចាចិត្ត ទុកជាមានលំអក្នុងបទខាងដើមនៃព្រះពុទ្ធសាសនា ជាការចាំបាច់មួយក្នុងជីវិតរបស់មនុស្សសប្បុរស។ ការប្រព្រឹត្តិល្អ ជាផ្លូវនាំមកនូវសេចក្តីសុខចំរើន តាំងពីមានជីវិត រហូតដល់ពេលធ្វើមរណ-កាល ក៏ត្រូវទៅកើតក្នុងសុគតិសួគ៌ទេវលោក។

ព្រះពុទ្ធសាសនារាប់ថាជាសាសនាធំមួយ ដែលសកលលោកទទួលស្គាល់ឬដឹងឮគ្រប់ប្រទេស ជាសាសនាដែលសម្បូណ៌ដោយទ្រឹស្តីល្អៗ ដោយអត្ថបទល្អៗ មានសេចក្តីដ៏ជ្រាលជ្រៅសុខុម ដែលទាក់ទងដោយផ្លូវវិទ្យាសាស្រ្ត និងសិល្បៈជាច្រើនយ៉ាង។

ព្រះពុទ្ធសាសនា ដែលសំដែងអំពីបាប បុណ្យនោះ ចង្អុលបញ្ជាក់ថា បាប និងបុណ្យកើតមកអំពីបុគ្គលអ្នកធ្វើ ដោយផ្ទាល់ខ្លួន ពុំមែនកើតដោយនរណាមួយ ដែលស័ក្តិសិទ្ធិប្រគល់ឲ្យឬទទួលយកបាប ជំនួសអ្នកធ្វើបានឡើយ គឺបុគ្គលអ្នកធ្វើអំពើបាបដោយខ្លួនឯងត្រូវសៅហ្មង ត្រូវទទួលទោសដោយខ្លួនឯង ពុំមាននរណាមួយក្រៅពីខ្លួនឯង ជាអ្នកទទួលទោសជំនួសបានទេ។ ពុទ្ធសាសនា មិនមានពិធីអង្វរករ បន់ស្រន់ ដើម្បីឲ្យរួចបាប ឬដើម្បីឲ្យបានបុណ្យទេ គឺថាពុំមានករណីកិច្ចអនុញ្ញាតឲ្យធ្វើបុណ្យលាងបាប ដោយការលុតក្រាបសុំអង្វរករនោះឡើយ។ ដំណើរនេះសមដូចពុទ្ធភាសិតក្នុងគម្ពីរធម្ម-បទខុទ្ទកនិកាយៈ

អត្តនា វ កតំ ចាបំ អត្តនា សង្កិលិស្សតិ
អត្តនា អកតំ ចាបំ អត្តនា វ វិសុជ្ឈតិ
សុទ្ធិ អសុទ្ធិ បច្ចត្តំ នាញ្ញោ អញ្ញំ វិសោធយេ។

ប្រែថា"បាបដែលបុគ្គលធ្វើហើយដោយខ្លួនឯង រមែងសៅហ្មង ដោយខ្លួនឯង បាបដែលបុគ្គលមិនធ្វើហើយ ដោយខ្លួនឯង រមែងបរិសុទ្ធដោយខ្លួនឯង សេចក្តីបរិសុទ្ធ និងមិនបរិសុទ្ធ ឲ្យផលចំពោះខ្លួន បុគ្គលដទៃមិនអាចញុំាងបុគ្គលដទៃឲ្យបរិសុទ្ធបានទេ"។

ពុទ្ធភាសិតនេះ បំភ្លឺសេចក្តីឲ្យឃើញថា បាបនិងបុណ្យដែលបុគ្គលណាធ្វើដោយផ្ទាល់ខ្លួន បុគ្គលនោះ ត្រូវបានទទួលផលរបស់បាបនិងបុណ្យដោយផ្ទាល់ខ្លួនវិញដែរ ពុំមានព្រះអាទិទេពឬវត្ថុស័ក្តិសិទ្ធិណាមួយក្នុងលោក អាចជួយរ៉ាប់រងទទួលទោសពៃរ៍ជំនួសអ្នកធ្វើ ឬដោយលស់លាត្រាប្រណីបានឡើយ។

កាលសាធុជន ពិចារណាឃើញទោសនៃការប្រព្រឹត្តអាក្រក់ ឃើញអានិសង្ស នៃការប្រព្រឹត្តល្អហើយ គប្បីលះបង់នូវទុច្ចរិត វៀរចាកអំពើបាបអកុសល គប្បីចំរើនសុចរិត បំពេញកុសលកម្ម ឲ្យមានបរិបូណ៌ឡើងក្នុងសន្តាន។

មួយទៀតលោកពោលថា អំពើបាប ជាអំពើអាក្រក់ គ្រោតគ្រាត ឬកណ្តាល ដែលកើតអំពីកាយ និងវាចា បុគ្គលត្រូវលះបង់ដោយការប្រតិបត្តិតាមវិន័យ ដោយហេតុថា វិន័យជាឧបាយសម្រាប់ទូន្មាននូវកាយ និងវាចា មិនឲ្យប្រព្រឹត្តបំពាន បំពារ ប៉ះពាល់ទៅលើជីវិត និងទ្រព្យសម្បត្តិអ្នកដទៃជាដើម។ បុរសស្ត្រី អ្នកវៀរចាកអំពើ

បាបដោយកាយ វាចាហើយ ឈ្មោះថាជាអ្នកជំរះខ្លួនប្រាណឲ្យជ្រះមន្ទិលគ្រោតគ្រាត ជាអ្នកមានកាយវាចាបរិសុទ្ធស្អាត គួរដល់ភាវនាកម្ម ប្រៀបដូចសាច់សំពត់ សស្អាត ដែលប្រាសចាកមន្ទិល គ្រឿងប្រឡាក់ អាចទទួលនូវការជ្រលក់ដោយពណ៌ផ្សេងៗបានដោយល្អ។ ដំណើរនេះ បុគ្គលអ្នកមានបំណងល្អ គប្បីបំពេញកុសលធម៌ តាមគោលនៃពុទ្ធសាសនា ឬពុទ្ធឱវាទទីពីរតទៅទៀត។

២. **កុសលស្សូបសម្បទា** ការញុំាងកុសលឲ្យកើត។ ពាក្យថា "កុសល" ក្នុងពុទ្ធឱវាទនេះ បានដល់សេចក្ដីល្អទាំងអស់ ដែលលោកសង្គ្រោះយកសុច្ចរិតធម៌ និងបុញ្ញកម្មផ្សេងៗ មានការធ្វើទានរក្សាសីលជាដើម។ កុសលនេះ ប្រែថា អំពើឈ្លាសវៃ អំពើឥតទោស អំពើជាគ្រឿងលះកិលេស។ ការដែលគ្រាន់តែលះបាបកម្មប៉ុណ្ណោះ ទុកថាជាកិច្ចវត្តដ៏ប្រសើរដែរហើយ ប៉ុន្តែពុំទាន់សម្រេចត្រឹមប៉ុណ្ណោះទេ ត្រូវនៅមានការធ្វើសេចក្ដីល្អ ដោយការញុំាងកុសលកម្មឲ្យកើតឡើងក្នុងសន្តាន ជំនួសសេចក្ដីអាក្រក់ ដែលលះបានហើយ ថែមឡើងទៀត។ ពុទ្ធឱវាទទីពីរ ទុកជាដំបូន្មានទាំងកាយ វាចា ចិត្ត ឲ្យកាន់តែមានចរិយាល្អខ្ពង់ខ្ពស់ប្រសើរឡើងទៀត។

ដើម្បីអប់រំកាយវាចាចិត្តឲ្យមានសីលធម៌ឲ្យបានបទល្អ ត្រូវបំពេញកុសលធម៌ឲ្យកើតបរិបូណ៌ឡើង ព្រោះកុសលធម៌ជាឧបាយនាំមកនូវសេចក្ដីសុខសប្បាយ រីករាយ តាំងពីលោកនេះ រហូតដល់លោកខាងមុខ សមដូចពុទ្ធភាសិតថា៖

**ឥធ មោទតិ បេច្ច មោទតិ កតបុញ្ញោ ឧភយត្ថ មោទតិ**

ប្រែថា"បុគ្គលអ្នកមានបុណ្យធ្វើហើយ រមែងរីករាយត្រេកអរក្នុងលោកទាំងពីរ គឺរីករាយក្នុងលោកនេះ លុះលះលោកទៅហើយក៏រមែងរីករាយទៀត"។

"ការបំពេញកុសលធម៌ ឬបុញ្ញកម្ម លោកចាត់ថាជាការបោសសំអាតជុសខាត់នូវមន្ទិល គឺកិលេសថ្នាក់កណ្តាលឲ្យជ្រះចេញចាកខន្ធសន្តាន ដើម្បីបែរឈមទៅរកប្រយោជន៍ និងសេចក្តីសុខ សមដូចព្រះពុទ្ធដីកាក្នុងបហានភាវនាសូត្រ មានដើមថា **យស្មា ច ខោ ភិក្ខវេ កុសលំ ភាវិតំ ហិតាយ សុខាយ សំវត្តតិ** សេចក្តីថា ៖ "ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុតែកុសល ដែលអ្នកទាំងឡាយចំរើនហើយ ទើបប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ"។

**អកុសលំ ភិក្ខវេ បជហថ កុសលំ ភិក្ខវេ ភាវេថ** ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរលះបង់ នូវអកុសលចេញ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរចំរើននូវកុសលឡើង។

ពាក្យថា "ញ៉ាំងកុសលឲ្យកើត" បានដល់ការបណ្តុះ បង្កើតកសាងសន្សំរឿយៗឲ្យកើតមានឡើង ដោយការបំពេញទាន រក្សាសីលនិងការចំរើនសមថកម្មដ្ឋាន ដើម្បីរម្ងាប់នីវរណ្ឌបក្កិលេស មានកាមឆន្ទជាដើម។ កុសលស្សូបសម្បទា ជាគោលនៃពុទ្ធសាសនាទីពីរនេះ លោកសង្គ្រោះថា ជាអនុសាសនី គឺពាក្យប្រៀនប្រដៅ មានលំអក្នុងថ្នាក់កណ្តាល ដែលបុគ្គលត្រូវបំពេញ បន្ទាប់អំពីការមិនធ្វើបាបនោះមក ដ្បិតករណីកិច្ចក្នុងការលះបាបទុច្ចរិតនោះ កាលបើបុគ្គលបានធ្វើហើយ មិនត្រូវឈប់ ផ្អាកត្រឹមប៉ុណ្ណោះទេ ត្រូវបំពេញ

ករណីកិច្ចក្នុងការបណ្តុះចំរើនបុណ្យកុសលឲ្យកើតមានឡើងតទៅទៀត ប្រៀបដូចទីដី ដែលមានឈើព្រៃផ្សៃ កាលបើ បុគ្គលត្រូវការកាប់គាស់រាន ឲ្យស្លាយចេញអស់ហើយ ត្រូវតែមានការដាំ បណ្តុះព្រោះពូជដំណាំ មានសណ្តែក ឬស្រូវជាដើម ត្រង់កន្លែងនោះឡើងទៀត។

ការលះបាបអកុសល និងការបំពេញបុណ្យកុសល ដូចរៀបរាប់មកហើយនេះ ព្រះអរហន្តសម្មាសម្ពុទ្ធ ទ្រង់សំដែងហើយថា ជាកិច្ចវត្តមួយ ដ៏ឧត្តមដោយពិត ប៉ុន្តែពុំទាន់អស់ការប្រតិបត្តិ បំពេញតទៅទៀតទេ ព្រោះថាបុគ្គលក្នុងលោកនេះ ដែលឋិតនៅក្នុងឋានៈជាបុថុជ្ជនគោត្រ តែងមានចិត្តទាក់ទងប្រទ្បាក់ដោយកិលេស ជាហេតុនាំឲ្យសៅហ្មង នាំឲ្យទំលាក់ក្រាញ រើរុះដោយការប៉ះប្រទះនឹងអា-រម្មណ៍ទាំងឡាយមានរូបារម្មណ៍ជាដើមដែលអាចចូលមកគ្របសង្កត់ញាំញីសន្តានចិត្ត របស់ខ្លួនបានទៀត ក្នុងកាលណាមួយ ព្រោះចិត្តនៅប្រកបដោយមន្ទិល គឺកិលេសនៅឡើយ ដោយហេតុថា ធម្មតាចិត្តរបស់បុថុជ្ជន ដែលនៅកម្រើក ញាប់ញ័រដោយលោកធម៌ កាលបើមានចិត្តត្រេកអរ ក្នុងការលះអកុសល បំពេញកុសលនោះ ច្រើនតែឋិតនៅចំពោះតែក្នុងរយៈកាលដែលកំពុងធ្វើ កំពុងប្រតិបត្តិ លុះផុតអំពីកាលនោះហើយ ចិត្តរបស់បុថុជ្ជន ច្រើនរើរុះផ្លាស់ប្តូរងាកបែរទៅរកអំពើបាបទុច្ចរិតវិញ ប្រៀបដូចជានាវា ដែលគេចែវច្រាស់ខ្សែទឹក ឬដូចជាគេដើរឡើងភ្នំ។

កាលបើយ៉ាងនេះ បុគ្គល ត្រូវមានករណីកិច្ច ក្នុងការបំពេញ

សេចក្ដីល្អតាមពុទ្ធឱវាទទីពតទៅទៀត ដើម្បីឲ្យបានសម្រេចដល់ទីបំផុតនៃគោលបំណង ដូចសេចក្ដីដែលត្រូវអធិប្បាយតទៅនេះ ៖

៣. **សចិត្តបរិយោទបនំ** ការញ៉ាំងចិត្តរបស់ខ្លួនឲ្យផូរផង់។

ពុទ្ធឱវាទទីពនេះ មានសេចក្ដីដ៏សុខុមពន់ពេក ព្រោះជាឱវាទដើម្បីជម្រះ សំអាតនូវចិត្ត ដែលច្រឡូកច្រឡំដោយកិលេស ឲ្យទៅជាចិត្តស្អាតផូរផង់។ ពិតណាស់ គ្រោងកាយរបស់មនុស្ស សត្វទាំងអស់ មិនមានធម្មជាតិអ្វី ជាប្រធាន ជាធំជាងចិត្តទេ មានតែធម្មជាតិគឺចិត្តជាប្រធាន ជាធំជាងអវៈយវៈទាំងអស់។ ចិត្ត ជាអ្នកបង្គាប់ការឲ្យកាយ វាចា ទទួលធ្វើទាំងល្អ ទាំងអាក្រក់ បើចិត្តល្អ ក៏បង្គាប់ឲ្យធ្វើល្អ បើចិត្តអាក្រក់ ក៏បង្គាប់ឲ្យធ្វើអាក្រក់ ប៉ុន្តែធម្មតាចិត្តកាលបើបានប្រទះអារម្មណ៍ដែលគួររីករាយ ក៏រមែងត្រេកអរ កាលបើប្រទះអារ-ម្មណ៍ដែលគួរស្អប់ក៏អាក់អន់។ អំណរ សំអប់ និងសេចក្ដីវង្វេង រមែងកើតមកអំពីអារម្មណ៍ទាំង៥ មានរូបារម្មណ៍ជាដើម អារម្មណ៍ឈ្មោះថាជាឧបក្កិលេសរបស់ចិត្ត ឬថាចិត្តដែលស្អាតល្អ ឬសៅហ្មងព្រោះមានអារម្មណ៍ជាប្រភព (ជាដែនកើត)។ កិលេស (គ្រឿងសៅហ្មង) របស់ចិត្ត ទោះបីមានច្រើនយ៉ាង ក៏ពិតមែន ប៉ុន្តែបើនិយាយដោយសង្ខេប មានតែបីយ៉ាងគឺ ៖ **រាគៈ** សេចក្ដីស្រើបស្រាល ស្រឡាញ់ត្រេកអរ ក្ដួចកាន់ជ្រួលក់ចិត្តទៅក្នុងអារម្មណ៍១ **ទោសៈ** សេចក្ដីខឹងអាក់អន់ តូចចិត្ត ក្រេវក្រោធ ពិរោធ១ **មោហៈ** សេចក្ដីវង្វេង ភាន់ច្រឡំ១។ កិលេសទាំង៣នេះ រមែងធ្វើចិត្តឲ្យប្រឡាក់ ឲ្យសៅហ្មងប្រៀបដូចទឹកដែលលាយដោយពណ៌ផ្សេងៗមានពណ៌ខ្មៅជាដើម។

ចិត្តកាលបើកិលេសគ្របសង្កត់ ញាំញីបានហើយ រមែងជ្រួលច្រាល់ ននៈនរនាទ ត្រាច់ទៅតាមក្រសែនៃអំណាចរបស់កិលេសនោះៗ។

អរិយៈទាំងឡាយ មានព្រះពុទ្ធជាដើម ដែលធ្លាប់បានទទួល ការអប់រំ ប្រៀនប្រដៅចិត្ត រមែងមិនដាក់ធុរៈក្នុងការទូន្មានចិត្តឡើយ ព្រោះការទូន្មានចិត្ត លោករាប់ថាជាការក្រៃបំផុតជាងការទូន្មានសត្វ សាហាវមានដំរីជាដើម។ វិធីនៃការទូន្មានចិត្តនោះ ពុំមែនធម៌ណា មួយ ដែលក្រៅអំពីសមថកម្មដ្ឋាននោះទេ ព្រោះសមថកម្មដ្ឋាន លោក សង្គ្រោះថាជាកម្មវិធីឬជាមធ្យោបាយដ៏ប្រសើរសម្រាប់ទូន្មានប្រៀន ប្រដៅចិត្ត ដើម្បីឲ្យចិត្តបរិសុទ្ធ ប្រាសចាកគ្រឿងមន្ទិល សៅហ្មង។ វិធីនៃការទូន្មានចិត្ត ដែលចែកទៅតាមប្រភេទនៃសមថកម្មដ្ឋានទាំង ៤០នោះ បើនិយាយដោយរួបរួម មានតែត្រឹម២យ៉ាងគឺ ៖ បហានវិធី វិធីនៃការលះកិលេស១ ភាវនាវិធី វិធីនៃការចំរើនបណ្ដុះបណ្ដាល ដើម្បីឲ្យកុសលធម៌កើតឡើង១។

ការចំរើន អសុភកម្មដ្ឋាន ឬ ព្រហ្មវិហារធម៌ ឬក៏ ពិចារណា ចំពោះ កងសង្ខារ តាមដំណើរនៃ ត្រៃលក្ខណៈ មានអនិច្ចលក្ខណៈ ជាដើម ស្វាបស្ទង់រកសេចក្ដីពិត ដើម្បីធ្វើបតិកិរិយា(ការប្រព្រឹត្តតស៊ូ ឬប្រព្រឹត្តប្រឆាំង) នឹងកិលេសនោះៗ ដើម្បីអោយកិលេសស្ងប់រម្ងាប់ ចាលចាញ់ចេញទៅ ចាកខន្ធសន្តាន ដើម្បីឲ្យកើតប្រាជ្ញា ពិចារណា ឃើញសេចក្ដីទុក្ខ ដែលគួរធុញទ្រាន់គួររអា ឃើញហេតុដែលនាំបង្ក បង្កាត់ពូជឲ្យកើតទុក្ខ ឃើញមគ្គផលនិព្វាន ជាធម្មជាត ស្ងប់រម្ងាប់ រំលត់ទុក្ខ ឃើញឧបាយក្នុងការប្រតិបត្តិត្រូវ ដើម្បីដើរកាត់តម្រង់ទៅ

វកធម៌ រំលត់ទុក្ខ គឺព្រះនិព្វាន ។ ការចំរើន សមថកម្មដ្ឋាន និងការ ពិចារណា កងសង្ខារ កាលបើបុគ្គល ប្រកបដោយព្យាយាម ក្លៀវក្លា មានកម្លាំងល្អហើយ អាចសង្កត់សង្កិនញាំញីនូវកិលេសគ្រប់ថ្នាក់គឺ ទាំងកិលេសគ្រោតគ្រាត កណ្តាល ល្អិតបាន។ វិធីនៃការលះ និង ចំរើន ប្រៀបដូចជាឱសថ សម្រាប់កែរោគ ចំណែកខាងរោគ មាន ឈ្មោះ មានសមុដ្ឋានច្រើនយ៉ាង ឱសថសម្រាប់កែរោគ ក៏ត្រូវមាន ច្រើនមុខដែរ កិលេសមានឈ្មោះ មានសមុដ្ឋានច្រើនយ៉ាង កម្មដ្ឋាន ដែលបុគ្គលចំរើន ក៏ត្រូវមានប្រភេទច្រើនដូច្នោះដែរ។

ចិត្តរបស់បុគ្គលដែលបានចំរើនអប់រំរឿយៗ រមែងទៅជាចិត្ត បរិសុទ្ធ ផូរផង់ ជាចិត្តថ្លាស្អាត ផុតចាកមន្ទិល គឺកិលេសគ្រប់យ៉ាង ឈ្មោះថា ជាការញ៉ាំងចិត្តរបស់ខ្លួនឲ្យស្អាត។ វិធីជម្រះចិត្ត ឲ្យស្អាត បរិសុទ្ធនេះ ឈ្មោះថាជាលំអទី៣ដែលជាប់ព្រំប្រទល់នឹងព្រះនិព្វាន ព្រោះថា ព្រះពុទ្ធសាសនា មានគោលដែលជាសារៈ សំខាន់បំផុត នោះ ក៏គឺការទូន្មានចិត្ត ដើម្បីអោយទោរទន់ឈមទៅរកព្រះនិព្វាន ដែលជាគុណជាតបានទទួលសន្តិភាពជាលោកកុត្តរស្ថាពរតទៅ។ ការបាននូវ មគ្គ ផល និព្វាន រមែងបាន ដោយចិត្តបរិសុទ្ធ ផុតចាក កិលេស សមដូចពុទ្ធភាសិតក្នុងគម្ពីរធម្មបទខុទ្ទកនិកាយថា ៖

**បរិយោទបេយ្យ អត្តានំ ចិត្តក្លេសេហិ បណ្ឌិតោ**

**យេសំ សម្ពោធិយង្គេសុ សម្មា ចិត្តំ សុភាវិតំ**

ប៉ុណ្ណោះជាដើម ប្រែថា "បណ្ឌិត គប្បីញ៉ាំងខ្លួនឲ្យផូរផង់ចាក គ្រឿងសៅហ្មងនៃចិត្ត បុគ្គលណាអប់រំចិត្តល្អហើយ ក្នុងអង្គនៃធម៌

ជាគ្រឿងត្រាស់ដឹង ត្រេកអរហើយ ក្នុងការលះកិលេស ព្រោះការមិនជាប់ជំពាក់មាំ ក្នុងអារម្មណ៍ បុគ្គលនោះ ជាអ្នកមានអាសវៈអស់ហើយ មានសេចក្តីវង្វេងក្នុងលោករលត់អស់ហើយ។

ការលះ ការវៀរចាកបាបទាំងអស់ដោយអំណាចនៃការកាន់សីលឲ្យបរិសុទ្ធ ការញុំាងកុសលធម៌ អោយកើតឡើងក្នុងសន្តានឲ្យបរិបូណ៌ដោយអំណាចនៃការកាន់សីលផងការឲ្យទានផង ព្រមទាំងការប្រតិបត្តិតាមពុទ្ធឱវាទផ្សេងៗទៀតផង។ ការអប់រំចិត្តឲ្យល្អ ដោយអំណាច នៃសមថកម្មដ្ឋាន និងវិបស្សនាកម្មដ្ឋាន ឈ្មោះថា ជាវិធីប្រតិបត្តិដ៏ខ្ពស់បំផុតដើម្បីដុសខាត់ចិត្តឲ្យស្អាតចាកនីវរណូបក្កិលេស និងអនុសយក្កិលេស ដើម្បីឲ្យចិត្តបរិសុទ្ធ អោយកើតប្រាជ្ញា នឿយណាយចាកសង្ខារ រាងកាយ ឲ្យចិត្តមាននិន្នាការ (បែរឈមទៅរក) មគ្គផលនិព្វាន ដែលជាលទ្ធផល ដ៏ខ្ពស់បំផុត នៃការប្រតិបត្តិក្នុងផ្លូវព្រះពុទ្ធសាសនា។ ក្នុងពុទ្ធឧទាននៃគម្ពីរ ខុទ្ទកនិកាយ មានសេចក្តីថា អរិយសាវកសាវិកាច្រើនតែបន្លឺឧទានវាចាដោយសេចក្តីត្រេកអរ ក្នុងវេលា ដែលលោកមានចិត្ត ចុះស៊ប់ ក្នុងអរហត្តផល ថា "**ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយ** " ប្រែថា "ជាតិ(របស់អាត្មាអញ) អស់ហើយ ព្រហ្មចរិយធម៌ចប់ស្រេចហើយ ករណីយកិច្ច អាត្មាអញបានធ្វើហើយ កិច្ចដទៃប្រព្រឹត្តទៅ ដើម្បីមគ្គភាវនានេះទៀត ពុំមានឡើយ"។

គោលនៃព្រះពុទ្ធសាសនា៣យ៉ាង ដូចសេចក្តីដែលរៀបរាប់ពណ៌នាមកនេះ ជាឱវាទ នៃព្រះពុទ្ធទាំងឡាយគ្រប់ព្រះអង្គ ដោយ

មានពុទ្ធបំណងក្នុងការទូន្មាន ប្រៀនប្រដៅសត្វ ត្រូវគ្នាគ្រប់ព្រះអង្គទាំងអស់។ បុគ្គលអ្នកត្រូវការប្រតិបត្តិតាមផ្លូវព្រះពុទ្ធសាសនា គួរតែបំពេញកិច្ចសិក្សាឲ្យបរិបូណ៌ ហើយប្រតិបត្តិតាមលំអាន នៃពុទ្ធឱវាទ ជាលំដាប់លំដោយ ដូចអធិប្បាយមកនេះ ទើបឈ្មោះថា ប្រព្រឹត្តត្រឹមត្រូវចប់កិច្ចនៃព្រះពុទ្ធសាសនា។

គោលព្រះពុទ្ធសាសនា ៣យ៉ាង ចប់ប៉ុណ្ណេះ។

ព្រះឧចាលិវង្ស សូរ ហាយ

# ៤. ទុក្ខជម្មកាថា

**សំដែងអំពីទុក្ខធម៌ (ធម៌ក្រ) ៥យ៉ាង**

ធម៌នេះ ព្រះសម្មាសម្ពុទ្ធទ្រង់លើកឡើង សំដែងប្រារព្ធនឹងភិក្ខុមួយរូប ឈ្មោះវជ្ជីបុត្តកៈ នៅក្នុងក្រុងវេសាលី។ តាមសេចក្តីដំណាលថា ភិក្ខុនោះ ជាព្រះរាជបុត្តរបស់ព្រះមហាក្សត្រិយ៍ក្នុងដែនវជ្ជី លះបង់រាជសម្បត្តិ ដែលខ្លួនត្រូវទទួលសោយរាជ្យតាមលំដាប់វេន ហើយចេញទៅបួសនៅក្នុងដងព្រៃមួយមិនឆ្ងាយប៉ុន្មានអំពីក្រុងវេសាលី។ គ្រានោះអ្នកក្រុងវេសាលីរៀបចំតាក់តែងទីក្រុងទាំងមូលឲ្យមានលំអ ដោយគ្រឿងប្រដាប់ផ្សេងៗ មានទង់ជ័យ និងបដា ជាដើម នាំគ្នាលេងមហោស្រព ប្រគំដូរ្យតន្ត្រីជាច្រើនបែប មានសម្លេងលាន់ឮទ្រហឹងអឹងអាប់ អស់វេលាពេញមួយរាត្រី មុខគួរឲ្យរីករាយចិត្តយ៉ាងក្រៃលែង។ ភិក្ខុនោះកំពុងតែដើរចង្ក្រមក្នុងទីចង្ក្រម បានឮសូរស័ព្ទដូរ្យតន្ត្រីផ្សេងៗ ដូច្នោះហើយ ក្រឡេកមើលអត្តភាព របស់ខ្លួន ដែលប្រាសចាកគ្រឿងអលង្ការ ហាក់ដូចជាកំណាត់ឈើ ដែលគេបោះចោលក្នុងព្រៃ ក៏កើតសេចក្តីសង្វេគ ស្រងេះស្រងោចលន្លង់លន្លោចក្នុងចិត្ត គិតថា ធម្មតាមនុស្សក្នុងលោក គ្មាននរណាលាមកអន់ជាងអាត្មាអញទៅទៀតទេ ម្ល៉ោះហើយក៏ត្រូវសេចក្តីអផ្សុកបៀតបៀនក្នុងខណៈនោះ។ ទេវតាដែលនៅក្នុងដងព្រៃនោះមានបំណងនឹងញ៉ាំងភិក្ខុនោះឲ្យកើតសេចក្តីសង្វេគទើបនិយាយទៅរកភិក្ខុនោះថា "លោកម្ចាស់ នៅក្នុងព្រៃម្នាក់ឯងហាក់ដូចជាកំណាត់ឈើ ដែលគេបោះចោលក្នុងព្រៃ ក៏ពិតមែន ប៉ុន្តែមនុស្ស និងទេវតា ភាគច្រើនស្រឡាញ់រាប់អាន ចំពោះលោកម្ចាស់ ដូចសត្វនរក តែងស្រឡាញ់

ចំពោះអ្នកដែលទៅកើតឋានសួគ៌ដូច្នេះដែរ" ភិក្ខុនោះឮពាក្យទេវតាថាដូច្នោះហើយ វេលាព្រឹកឡើង ក៏ចូលទៅគាល់ ព្រះបរមសាស្ដាក្រាបទូលតាមសេចក្ដីនោះដោយសព្វគ្រប់។ ព្រះសម្មាសម្ពុទ្ធ ទ្រង់ព្រះសណ្ដាប់ពាក្យភិក្ខុនោះក្រាបទូលហើយ ទ្រង់ប្រជុំទុក្ខ (ការក្រ) ៥យ៉ាង ហើយត្រាស់ជាបទគាថាថា៖

ទុប្បព្វជ្ជំ ទុរភិរមំ ទុរាវាសា ឃរា ទុខា
ទុក្ខោ សមានសំវាសោ ទុក្ខានុបតិតទ្ធគូ
តស្មា ន ចទ្ធគូ សិយា ន ច ទុក្ខានុបតិតោ សិយា។

(ប្រែថា)ការបួសបានដោយក្រ ឬថាក្រនឹងបានបួស ការត្រេកអរត្រូវបានដោយក្រ ឬថា ក្រនឹងបានត្រេកអរត្រូវ ការនៅគ្រប់គ្រងផ្ទះ ជាការក្រ ការនៅរួមជាមួយនឹងមនុស្សស្មើគ្នាជាការក្រ អ្នកដើរទៅកាន់ផ្លូវឆ្ងាយ រមែងត្រូវទុក្ខជាប់តាម ព្រោះហេតុនោះ បុគ្គលមិនត្រូវដើរទៅកាន់ផ្លូវឆ្ងាយ ទាំងមិនត្រូវឲ្យសេចក្ដីទុក្ខជាប់តាមឡើយ។ ក្នុងផ្ទៃនៃគាថានេះ ព្រះសម្ពុទ្ធទ្រង់សំដែងអំពីទុក្ខ (ការក្រ) ៥យ៉ាង ដោយសេចក្ដីសង្ខេបពេក នៅក្នុងការចង្អៀត កំបាំងសេចក្ដី ពុំទាន់ទូលំទូលាយនៅឡើយ ក្រែងអស់លោកអ្នកអាន លំបាកពិចារណាសេចក្ដីនៃពុទ្ធភាសិតនេះ អោយយល់សព្វគ្រប់បាន ព្រោះហេតុនោះ សូមលើកយកគោលនៃពុទ្ធភាសិតមួយៗ ក្នុងផ្ទៃគាថានោះ មកតាំងជាមាតិកា ដើម្បីអធិប្បាយ ពង្រីកសេចក្ដី ឲ្យបានទូលាយ ងាយស្ដាប់ដូចតទៅនេះ៖

១. ការបួសបានដោយក្រ ឬថាក្រនឹងបានបួស

ការចេញបួស របស់បុគ្គលនីមួយៗ បានដោយក្រណាស់ គឺ

ក្រនឹងបានលះបង់ នូវគំនរនៃភោគសម្បត្តិ ទោះមានតិចក្តី ច្រើនក្តីផង ក្រនឹងបានលះបង់ នូវក្រុមញាតិសន្តានផង ហើយទៅបួស ប្តូរជីវិតក្នុងពុទ្ធសាសនានេះព្រោះថាបុគ្គលនីមួយៗដែលចេញទៅបួសក្នុងសាសនាដោយមានដំណើរផ្សេងៗគ្នា គឺបុគ្គលខ្លះ ឃើញទោសរបស់ឃរាវាស (ការនៅគ្រប់គ្រងផ្ទះ) ប្រកបដោយទោសទុក្ខច្រើនប្រការណាស់ មិនអាចធ្វើខ្លួនឲ្យបរិសុទ្ធស្អាតចាកទុក្ខបាន លុះគិតឃើញ ក៏នឿយណាយ ធុញទ្រាន់នឹងភេទឃរាវាស ហើយចេញទៅបួសក្នុងពុទ្ធសាសនា ដើម្បីស្វែងរកធម៌ ក៏មាន ។ បុគ្គលខ្លះ ឃើញទោសនៃការកើតស្លាប់ក្នុងវដ្តសង្សាររកទីបំផុតគ្មាន កើតមានសេចក្តីនឿយណាយនឹងខន្ធ៥របស់ខ្លួន ក៏គិតថា ការនៅក្នុងកណ្តាលផ្ទះ គឺកាមគុណយ៉ាងនេះ មិនអាចបំពេញសមណធម៌អោយហ្មត់ចត់បានឡើយ លុះតែបួស ទើបបំពេញសេចក្តីប្រតិបត្តិ ឲ្យគ្រប់គ្រាន់បាន កាលបើគិតឃើញដូច្នេះ ក៏ចេញទៅបួស ក្នុងពុទ្ធសាសនា ក៏មាន ។ បុគ្គលខ្លះគិតឃើញថា ការនៅធ្វើជាគ្រហស្ថនេះ ពិបាកប្រកបការងាររកទ្រព្យសម្បត្តិសម្រាប់ចិញ្ចឹមជីវិតណាស់ ទោះបីខំប្រឹងធ្វើការយ៉ាងណាក៏នៅតែត្រដាបត្រដួសស្ទើរតែពុំរស់ជាមនុស្ស បើធ្វើជាអ្នកបួសវិញទើបស្រួលងាយនឹងចិញ្ចឹមជីវិត ក៏ចេញទៅបួសក្នុងពុទ្ធសាសនាដោយហេតុនេះក៏មាន។ បុគ្គលខ្លះគិតឃើញថា អាត្មាអញមានវ័យល្មមបួស ជាសាមណេរ ឬជាភិក្ខុហើយ ព្រោះអ្នកដទៃ គេបួសរាល់គ្នា បើឯងមិនបួសទេ មុខតែអ្នកផងគេនិន្ទាយ៉ាងនេះ ឬយ៉ាងនោះពុំខាន ហើយចេញទៅបួសដោយហេតុនេះក៏មាន។ បុគ្គលខ្លះមិនបានជាគិតឃើញដល់ទុក្ខទោស ឬនឿយណាយនឹងភេទឃរាវាសប៉ុន្មាន

ទេ ប៉ុន្តែពួកញាតិ មានមាតាបិតាជាដើម និយាយណែនាំដាស់តឿន បង្ខិតបង្ខំឲ្យបួស ក៏សុខចិត្តលះភេទឃរាវាស ចេញទៅបួសដោយហេតុនេះក៏មាន។ល។ បុគ្គលនីមួយៗដែលបានចេញទៅបួស ទោះបីខាងដើម មានសេចក្ដីយល់ឃើញយ៉ាងណាក៏ដោយ ក៏ឈ្មោះថាកម្រមានបុគ្គលបួសបានដែរ ប៉ុន្តែក្នុងទីនេះ ព្រះសម្មាសម្ពុទ្ធ ទ្រង់ត្រាស់ថា ក្រនឹងបានបួស គឺកម្រមានបុគ្គល លះភោគសម្បត្តិ និងពួកញាតិ មានមាតាបិតា ឬប្រពន្ធកូនជាដើម ហើយចេញទៅបួសអស់មួយជីវិតក្នុងសាសនា។

២. ការត្រេកអរត្រូវបានដោយក្រ ឬថា ក្រនឹងបានត្រេកអរត្រូវ

ការដែលបុគ្គល បានលះភេទឃរាវាស ហើយបួស ក្នុងពុទ្ធ-សាសនាយ៉ាងនេះព្យាយាមចិញ្ចឹមជីវិតដោយការវៀរចាកអនេសនៈ (ការស្វែងរកមិនគួរ) ហើយប្រព្រឹត្តចិញ្ចឹមជីវិត ដោយភិក្ខាចារ (ការដើរសូមជាប្រក្រតី) ហើយត្រេកអរពេញចិត្តក្នុងការរក្សានូវកងសីល គឺសិក្ខាបទទាំងឡាយជាពុទ្ធប្បញ្ញត្តិ និងពុទ្ធានុញ្ញាត ដែលមានទាំងប៉ុន្មានមិនឲ្យខ្វះខាត ហើយបំពេញសេចក្ដីប្រតិបត្តិនូវធម៌ឲ្យសមគួរដល់ធម៌ នេះទុកជាការក្របំផុត គឺកម្រមានបុគ្គល ដែលបួសហើយមានគំនិតយល់ត្រូវប្រព្រឹត្តត្រូវដូច្នេះ ព្រោះបុគ្គលខ្លះបួសហើយ ច្រើនភ្លេចវង្វេងភាន់ច្រឡំដោយអំណាចសេចក្ដីល្ងង់ខ្លៅ ឬដោយអំណាចលាភសក្ការៈ កើតឡើងគ្របសង្កត់ បំបែរគំនិតឲ្យយល់ខុសផ្ទុយនឹងធម៌វិន័យរបស់ព្រះសម្មាសម្ពុទ្ធទៅវិញមានរបៀបរបបនិងការប្រព្រឹត្តិផ្សេងៗគ្នា ម្ល៉ោះហើយ ក៏ក្លាយទៅជាអ្នកបួសមានច្រើនបែប គឺបែបទី១. ឧបជីវិតា បួសដើម្បីចិញ្ចឹមជីវិត បានខាងមនុស្សអនាថា ជាអ្នក

គ្រីក្រខ្សត់កំព្រាបួសពឹងសាសនាស៊ី ដូចជាភូតបិសាច រំពៃចាំទទួល គ្រឿងសំណែនដែលមានគេបន់ស្រន់ មិនសូវអើពើនឹងការខុសត្រូវ របស់អ្នកបួសប៉ុន្មាន ជាអ្នកឥតអៀនខ្មាស លោភនឹងការរកចិញ្ចឹម ជីវិតដោយមិច្ឆាជីវៈ ក្លៀវក្លាដូចជាសត្វក្អែក។ បែបទី២. ឧបកីឡិកា បួសលេងៗ បានខាងអ្នកបួស ដែលពេញចិត្តក្នុងល្បែង របាំផ្សេងៗ អាស្រ័យសាសនាជាបង្អែក អាស្រ័យភេទសមណៈជាគ្រឿងបញ្ឆោត ឲ្យមនុស្សអ្នកល្ងង់ខ្លៅដែលរីករាយពេញចិត្តចំពោះល្បែងរបាំដូចគ្នា បូជា ដោយអាមិសទានផ្សេងៗ ពុំសូវអើពើនឹងធម៌វិន័យ ពុំសូវគិតគូ ពីសេចក្តីប្រតិបត្តិរកខុសរកត្រូវប៉ុន្មានឡើយ។ បែបទី៣. ឧបមុឃ្ឋិកា បួសក្នុងសាសនាជាមនុស្សវង្វេង បានខាងអ្នកបួសខ្ជិលច្រអូស មិន សិក្សារៀនសូត្រធម៌វិន័យឲ្យចេះដឹង ស្គាល់ផ្លូវនៃសេចក្តីប្រតិបត្តិល្អ អាក្រក់ទេ បណ្តោយខ្លួនឲ្យវង្វេង ធ្លាក់នៅក្នុងរណ្តៅ គឺសេចក្តីល្ងង់ ខ្លៅ មិនអាចទូន្មានប្រៀនប្រដៅដឹកនាំទាយកទាយិកាឲ្យស្គាល់ខុស ត្រូវ ក្នុងសេចក្តីប្រតិបត្តិ ធម៌វិន័យ ក្នុងពុទ្ធសាសនា បានឡើយ ត្រូវ លាភសក្ការៈគ្របសង្កត់ ក៏កើតមានះ ប្រកាន់ចចេស រឹងត្អឹង ស្រវឹង ងេងងោងភ្លេចខ្លួនដូចជាជ្រូកស្រុកដែលគេបំប៉នដោយចំណី។ បែប ទី៤.ឧបទូសិកា បួសប្រទូស្តសាសនា បានខាងអ្នកបួសមិនយកចិត្ត ទុកដាក់ប្រតិបត្តិតាមធម៌វិន័យ គឺប្រព្រឹត្តខ្ជីខ្ជា ច្រឡើសបើស តាមទំ នើងចិត្ត ផ្ទុយពីពុទ្ធប្បញ្ញត្តិ និងពុទ្ធានុញ្ញាត អាស្រ័យកាសាវព័ស្រ្ត ជារនាំងបាំងភ្នែក នៃជនដទៃ ចាំតែជំទាស់ រារាំងចំពោះ ការសិក្សា ធម៌វិន័យរបស់គេមិនឲ្យចំរើនលូតលាស់ឡើងបាន លបប្រព្រឹត្តអំពើ ទុច្ចរិតផ្សេងៗ ហាក់ដូចជាពួកចោរប្លន់ បំផ្លិចបំផ្លាញ ពង្រេចពង្រឹល

សាសនាឲ្យវិនាសសាបសូន្យបាត់ទៅ។ បែបទី៥. ឧបនិស្សរណិកា បួសដើម្បីនឹងរលាស់ខ្លួន ចេញចាកទុក្ខ បានខាងអ្នកបួស ដែលនឹក ដល់ពាក្យប្ដេជ្ញារបស់ខ្លួនចំពោះមុខឧបជ្ឈាយ៍ថា ៖

*សព្វទុក្ខនិស្សរណនិព្វាន សច្ឆិករណត្ថាយ* ដូច្នេះជាដើម ហើយក៏ខំប្រឹងរៀនសូត្រចេះដឹងដោយខ្លួនឯងផង បានបង្ហាត់បង្រៀន ឬសំដែងប្រាប់អ្នកដទៃឲ្យមានការចេះដឹងផង ហើយប្រតិបត្តិដោយ សេចក្ដីរៀបរយល្អតាមធម៌វិន័យ ប្រតិបត្តិដោយត្រង់ តាមផ្លូវមជ្ឈិមា បដិបទា ប្រតិបត្តិដើម្បីត្រាស់ដឹងនូវព្រះនិព្វានជាឋានក្សេមផុតចាក ទុក្ខទាំងពួង ប្រតិបត្តិដ៏សមគួរ តាមលំដាប់ថ្នាក់ សីល សមាធិ បញ្ញា មិនឲ្យឃ្លៀងឃ្លាត ជាអ្នកប្រព្រឹត្តធ្វើសេចក្ដីស្ងប់ ដោយខ្លួនឯង ទាំង ដឹកនាំជនដទៃអោយប្រព្រឹត្តធ្វើសេចក្ដីស្ងប់ផងដែរ។ បណ្ដាអ្នកបួស ទាំង៥បែប ដូចបានពណ៌នាមកហើយនោះ អ្នកបួសបែបទី១ ដល់ទី ៤ ឈ្មោះថា ជាអ្នកបួសញាំញីពុទ្ធសាសនាឲ្យវិនាសសាបសូន្យ ឯ អ្នកបួសបែបទី៥ឈ្មោះថាជាអ្នកបួសញុំាងព្រះពុទ្ធសាសនាឲ្យចំរើន ថ្កុំថ្កើងរុងរឿង តាំងនៅអស់កាលជាអង្វែង ។ ព្រោះហេតុនោះ បាន ជាព្រះសម្មាសម្ពុទ្ធ ទ្រង់ត្រាស់ថា ការបួសក្រនឹងបានត្រេកអរត្រូវ គឺ កម្រមានបុគ្គលដែលបួសហើយយកចិត្តទុកដាក់ប្រព្រឹត្តលះមិច្ឆាជីវៈ ហើយព្យាយាមចិញ្ចឹមជីវិតដោយសម្មាជីវៈ ត្រេកអរពេញចិត្តមិនរួញ រានឹងការរក្សាកងសីល គឺសិក្ខាបទ ជាពុទ្ធប្បញ្ញត្តិ និងពុទ្ធានុញ្ញាត មិនឲ្យមានមោះហ្មង ហើយប្រព្រឹត្តធ្វើសេចក្ដីប្រតិបត្តិ នូវធម៌ តាម ធម៌ឲ្យបានគ្រប់គ្រាន់។

## ៣. ការនៅគ្រប់គ្រងផ្ទះ ជាការក្រ

ព្រះពុទ្ធដីកានេះទ្រង់សំដែងចំពោះឃរាវាសជនអ្នកនៅគ្រប់គ្រងផ្ទះសម្បែងជាប្រក្រតី។ ធម្មតាគ្រហស្ថជាម្ចាស់ផ្ទះនៅគ្រប់គ្រងផ្ទះ មិនមែនបានទទួលសេចក្ដីសុខស្រួលដោយចំណែកមួយទេ តែងមានសេចក្ដីទុក្ខជាប់នៅដោយច្រើន កាលបើប្រព្រឹត្តទុកដាក់ខ្លួនមិនល្អ ឬមិនសមគួរទេ រមែងឲ្យទុក្ខទោសប្រចាំនៅជានិច្ច។ ឃរាវាសជន រមែងមានករណីយកិច្ច ដែលត្រូវបំពេញ ត្រូវធ្វើ ច្រើនយ៉ាង គឺដោយឋានៈជាមនុស្សកតញ្ញូកតវេទី ត្រូវបំរើលោកអ្នកមានគុណូបការៈមាតាបិតានិងគ្រូអាចារ្យរបស់ខ្លួនផង ត្រូវចេញទ្រព្យសម្បត្តិតាមមុខការ ថ្វាយម្ចាស់ផែនដី ដើម្បីរាជការ មានបង់ពន្ធដារផ្សេងៗ ជាដើមផង។ដោយឋានៈជាបុព្វការី ត្រូវចិញ្ចឹមទំនុកបម្រុងបុត្តធីតារបស់ខ្លួនតាមផ្លូវលោកនិងផ្លូវធម៌ផង ត្រូវសង្គ្រោះទំនុកបំរុងជនជាបរិវារ ដែលនៅក្នុងបន្ទុករបស់ខ្លួនផង។ ដោយឋានៈជាគហបតី ត្រូវយកចិត្តទុកដាក់ប្រព្រឹត្តឲ្យស្មោះស្មើដល់គ្នានឹងគ្នា រវាងស្វាមី និងភរិយាផង ត្រូវសង្គ្រោះទំនុកបំរុងញាតិនិងមិត្រសម្លាញ់ផង ត្រូវសង្គ្រោះទំនុកបំរុងសមណព្រាហ្មណ៍(បព្វជិត) អ្នកកាន់ពុទ្ធសាសនា ដោយបច្ច័យទាំង៤ផង ត្រូវជួយសង្គ្រោះជនទុគ៌តខ្សត់ក្រកំព្រាតាមការគួរផង។ល។

ឃរាវាសជន កាលបើបានបំពេញករណីយកិច្ច របស់ខ្លួនដោយន័យ ដូចបានពណ៌នាមកហើយនោះ រមែងជាទីសរសើរ និងជាទីស្រឡាញ់រាប់អានរបស់ជនទូទៅ រាប់ថាបានទទួលសេចក្ដីសុខដែលឃរាវាសជនគប្បីបានទទួលតាមសមគួរ ប៉ុន្តែបើឃរាវាសជនណាមិនបានបំពេញករណីយកិច្ចនោះៗទេ ឃរាវាសជននោះ រមែង

បានទុក្ខ ពោលគឺ មិនមានអ្នកណានិយមរាប់អាន ជាអ្នកត្រូវនិន្ទារបស់ជនទូទៅ។ កាលបើដូច្នេះ ឃរាវាស(ការនៅគ្រប់គ្រងផ្ទះ)មានផ្លូវ ឬមុខប្រទ្បាយដែលត្រូវចំណាយ ឬត្រូវហូរចេញនៃទ្រព្យសម្បត្តិជាច្រើនយ៉ាង ជនជាគ្រហស្ថមិនអាចនឹងបំពេញឲ្យពេញគ្រប់គ្រាន់បានដោយងាយឡើយ ដូចក្អមធ្លុះ ពុំនោះសោតដូចជាមហាសមុទ្រមិនមានអ្នកណាមួយអាចធ្វើឲ្យពេញប្រៀបដោយទឹកបាន ក៏ដូច្នោះដែរ។ ព្រោះហេតុនោះ បានជាព្រះមានព្រះភាគទ្រង់ត្រាស់ថា ការនៅគ្រប់គ្រងផ្ទះជាការក្រ គឺកម្រមានជនជាគ្រហស្ថនៅគ្រប់គ្រងផ្ទះអាចបំពេញករណីយកិច្ចរបស់ខ្លួនឲ្យបានគ្រប់គ្រាន់ឡើយ។

### ៤. ការនៅរួមជាមួយមនុស្សស្មើគ្នា ជាការក្រ

ព្រះពុទ្ធដីកានេះ ទ្រង់សំដែង ចំពោះជនទាំងពីរប្រភេទ គឺទាំងគ្រហស្ថ ទាំងបព្វជិត ។ ជនទាំងឡាយណា គឺ បើខាងគ្រហស្ថសូម្បីស្មើគ្នាដោយ ជាតិ គោត្រ ត្រកូល ភោគៈ ក៏ដោយ ឬបើខាងបព្វជិត សូម្បីស្មើគ្នាដោយគុណធម៌មានសីលអាចារៈនិងពាហុសច្ចៈជាដើមក៏ដោយ ប៉ុន្តែបើចិត្តមិនស្មើគ្នា មិនរាប់រកគ្នា មិនគោរពគ្នាទៅវិញទៅមកទេ ដោយអាស្រ័យមានៈ រឹងត្អឹង តែរៀងខ្លួន ពោលអាងពាក្យថា "គេម៉េច អញម៉េច" យ៉ាងនេះជាដើម ហើយរមែងទៅជាអ្នកខ្វល់ខ្វាយដោយរឿងអធិករណ៍ ឈ្លោះប្រកែកទាស់ទែងខ្វែងគំនិតគ្នាឥតស្រាក ជនទាំងឡាយនោះឈ្មោះថា មិនស្មើគ្នាទេ ការនៅរួមជាមួយនឹងពួកជនមិនស្មើគ្នាដូច្នោះរមែងនាំមកនូវទុក្ខរឿយៗ។ សេចក្តីដែលពណ៌នាមកនេះ ខាងដើមនឹងខាងចុងហាក់ដូចជាផ្ទុយខ្វែងពីគ្នា គឺខាងដើម ព្រះអង្គទ្រង់សំដែងថា ការនៅរួម ជាមួយនឹង

មនុស្សស្មើគ្នា ជាការក្រ ឬនាំមកនូវទុក្ខ ខាងចុងសំដែងថា ការនៅរួមជាមួយនឹងពួកជនមិនស្មើគ្នា រមែងនាំមកនូវទុក្ខ សេចក្តីនេះ សូមជ្រាបថា ព្រះអង្គទ្រង់សំដែង សំដៅយកចិត្តជាប្រមាណ ព្រោះថាក្នុងសង្គមនៃជននីមួយៗ បើទុកជាមាន សម្បត្តិ គឺ ជាតិ វ័យ គោត្រត្រកូល និងទ្រព្យមានវិញ្ញាណ ឥតវិញ្ញាណស្មើគ្នាយ៉ាងណាក៏ដោយ តែបើចិត្តក្នុងសង្គមនោះមិនស្មើគ្នា មិនព្រមព្រៀងគ្នា មិនគោរពរាប់អានគ្នា ដោយស្មោះត្រង់ ទៅវិញទៅមកទេ សង្គមនៃជននោះឯងឈ្មោះថា មិនស្មើគ្នាដោយពិត។ ចំណែកខាងបព្វជិតវិញ ក៏ដូច្នោះដែរ បព្វជិតទាំងឡាយ ដែលនៅក្នុងកុដិនីមួយ ៗ ឬនៅក្នុងអារាមនីមួយៗ បើមានគុណធម៌ផ្សេងៗ គឺការសិក្សា រៀនសូត្រក្តី សីលក្តី អាចារៈ (ការកាន់ប្រព្រឹត្ត) ក្តី ពាហុសច្ចៈ ភាពជាពហុស្សូត គឺជាអ្នកចេះដឹងចំណេះវិជ្ជាអ្វីក្តី មានភាគស្មើគ្នាយ៉ាងណាក៏ដោយ ប៉ុន្តែបើខ្វះផ្លូវចិត្ត គឺមិនមានសេចក្តីព្រមព្រៀងគ្នា មិនគោរពគ្នាទៅវិញទៅមកតាមចាស់ក្មេង មិនរាប់អានគ្នាដោយស្មោះត្រង់ទៅវិញទៅមកទេ បព្វជិតទាំងឡាយនោះឈ្មោះថាមិនស្មើគ្នាទេ។ លុះតែជនទាំងឡាយណា បើជាគ្រហស្ថ ត្រូវស្មើគ្នាដោយសម្បត្តិគឺជាតិ វ័យ គោត្រត្រកូលនិងភោគៈ ឬបើជាបព្វជិត ត្រូវស្មើគ្នាដោយគុណធម៌គឺ សីលនិងចំណេះវិជ្ជាជាដើមផង ទាំងផ្លូវចិត្តគំនិតក៏ស្មើគ្នាផង ជនទាំងឡាយនោះ ទើបមានសេចក្តីសុខចំរើន។ បើមិនដូច្នោះទេ ជនទាំងនោះ រមែងទទួលនូវទុក្ខជាធម្មតា គឺមានតែអធិករណ៍ ការឈ្លោះទាស់ទែងខ្វែងគំនិតគ្នាតែម្យ៉ាងប៉ុណ្ណោះ។ ព្រោះហេតុនោះ បានជាព្រះសម្មាសម្ពុទ្ធ ទ្រង់ត្រាស់សំដែងថា ការនៅរួមជាមួយនឹងមនុស្ស

ស្មើគ្នាដោយសម្បត្តិ និងដោយគុណធម៌ តែមិនស្មើគ្នាដោយផ្លូវចិត្ត ផងទេ ជាការក្រ ឬរមែងនាំមកនូវទុក្ខរឿយៗ។

៥. អ្នកដើរទៅកាន់ផ្លូវឆ្ងាយ រមែងត្រូវទុក្ខជាប់តាម

ផ្លូវឆ្ងាយមាន២យ៉ាងគឺ កន្តារទ្ធា ផ្លូវឆ្ងាយ គឺកន្តារ១ វដ្តទ្ធា ផ្លូវឆ្ងាយ គឺវដ្តៈ១ ។ បណ្តាផ្លូវឆ្ងាយទាំងពីរយ៉ាងនោះ ផ្លូវឆ្ងាយគឺកន្តារ សំដៅយកផ្លូវដែលមាននៅក្នុងលោកនេះ។ កន្តារៈប្រែថាផ្លូវលំបាក ផ្លូវដែលមានគ្រោះថ្នាក់ ឬផ្លូវឆ្ងាយដាច់ស្រយាលមាន៥យ៉ាងគឺ ៖

១.ចោរកន្តារ ផ្លូវលំបាកព្រោះចោរ, ២.វាឡកន្តារ ផ្លូវលំបាកព្រោះសត្វកាចសាហាវ, ៣.អមនុស្សកន្តារ ផ្លូវលំបាកព្រោះអមនុស្ស ឬបិសាច, ៤.និរុទកកន្តារ ផ្លូវលំបាកព្រោះគ្មានទឹក, ៥.អប្បភក្ខកន្តារ ផ្លូវលំបាក ព្រោះខ្សត់អាហារ។ មនុស្សក្នុងលោក ដែលធ្វើដំណើរដើរពីតំបន់មួយទៅកាន់តំបន់មួយ ឬពីប្រទេសមួយទៅកាន់ប្រទេសមួយ តាមផ្លូវកន្តារ បើមិនទាន់ដល់ទីដែលខ្លួនប៉ងនោះ ដរាបណា ក៏នៅឈ្មោះថា ជាអ្នកដំណើរដរាបនោះ លុះតែបានដល់ទី ដែលខ្លួនប៉ងនោះហើយ ទើបឈ្មោះថាជាអ្នកមានផ្លូវឆ្ងាយដល់ហើយ ឬមានដំណើរដល់ហើយ។ ធម្មតាមនុស្សដែលដើរទៅកាន់ផ្លូវកន្តារ រមែងជួបប្រទះនឹងសេចក្តីទុក្ខលំបាកណាមួយ ជួនកាល ត្រូវចោរកំហែងរំលោភ បៀតបៀនតាមអំពើចិត្ត ក៏មាន ជួនកាល ត្រូវសត្វសាហាវមានខ្លា ជាដើម បៀតបៀនក៏មាន ជួនកាល ត្រូវអមនុស្ស ឬបិសាចបំភ័យបៀតបៀនក៏មាន។ល។ការធ្វើដំណើររបស់មនុស្សទាំងឡាយក្នុងលោកនេះ រមែងជួបប្រទះនឹងសេចក្តីទុក្ខលំបាក ឬអន្តរាយណាមួយ ទោះតូចឬធំ នឹងគេចចៀសវាងពុំរួចយ៉ាងណា ឯសត្វទាំងឡាយ

ដែលអាស្រ័យនៅក្នុងវដ្តៈក៏ដូច្នោះដែរ។ បើសត្វទាំងឡាយអន្ទោល ទៅមកនៅក្នុងវដ្តៈដរាបណា ក៏ឈ្មោះថាជាអ្នកដើរទៅកាន់ផ្លូវឆ្ងាយ ឬជាអ្នកដំណើរ ដរាបនោះ ព្រោះហេតុអ្វី? ព្រោះហេតុថា វដ្តៈ មិន ទាន់អស់នៅឡើយ សូម្បីអរិយបុគ្គលទាំងឡាយ មានសោតាបន្ន បុគ្គលជាដើម ក៏ឈ្មោះថា ជាអ្នកដំណើរដែរ លុះតែ ព្រះអរហន្ត ខីណាស្រពដែលធ្វើវដ្តៈឲ្យអស់ហើយ ទើបឈ្មោះថា លោកមានផ្លូវ ឆ្ងាយដល់ហើយ ឬថាលោកមានដំណើរដល់ទីហើយ។

វដ្តៈមាន៣យ៉ាងគឺ កិលេសវដ្តៈ វដ្តៈគឺកិលេស១ កម្មវដ្តៈ វដ្តៈ គឺកម្ម១ វិបាកវដ្តៈ វដ្តៈគឺវិបាក១។

ពាក្យថា វដ្តៈ ប្រែថា "គ្រឿងវិល" ឬថា "ធម៌ជាគ្រឿងបង្វិល សត្វ"។ បដិសន្ធិវិញ្ញាណរបស់សត្វដែលវិលវល់អន្ទោលទៅមកក្នុង ភពតូច.ធំមិនមានទីបំផុត ដោយអំណាចកិលេសជាបច្ច័យ ដូចតណ្ហា ជាកិលេសជាតិនាំសត្វឲ្យប្រាថ្នាជាប់ស្អិតក្នុងវត្ថុកាមនិងកិលេសកាម កោធៈ សេចក្តីក្រោធខឹងចំពោះសត្វ និងសង្ខារដទៃប៉ុណ្ណោះជាដើម ហៅថា កិលេសវដ្តៈ។

កាលបើកិលេសមាន កម្ម គឺអំពើក៏មានដែរ គឺថា កិលេសជា ហេតុដឹកនាំសត្វអោយមានការស្វះស្វែងធ្វើនូវកម្ម គឺកិច្ចការផ្សេងៗ កម្មជាគ្រឿងញ៉ាំងសត្វ ឲ្យស្ទុះស្ទា វិលវល់ឥតឈប់ឈរ ដូច្នេះទើប ហៅថា កម្មវដ្តៈ។

កាលបើកម្មវដ្តៈមាន វិបាកវដ្តៈក៏មានដែរ ព្រោះវិបាកគឺផល របស់កម្ម ជាកុសល ឬអកុសល រមែងនាំសត្វឲ្យវិលវល់ជាប់នៅក្នុង លោក រកទីបំផុតបានដោយកម្រ ទើបហៅថា វិបាកវដ្តៈ ។ វដ្តៈទាំង

៣យ៉ាងនេះ ជាហេតុ ជាផល ជាប់ទាក់ទងដល់គ្នានឹងគ្នា គឺកាលបើ
កិលេសកើតមានឡើង ជាហេតុជាបច្ច័យនាំសត្វឲ្យធ្វើនូវកម្ម កាល
បើកម្មកើតមានឡើង ជាហេតុជាបច្ច័យ នាំសត្វឲ្យបានជួបប្រទះនូវ
វិបាកគឺផល កាលបើវិបាកគឺផលកើតមានឡើង ក៏ប្រែត្រឡប់ទៅជា
ហេតុនាំសត្វអោយជាប់ចិត្តញ៉ាមចំពោះអារម្មណ៍នោះៗទៀត រហូត
ទាល់តែចិត្តសៅហ្មង នាំឲ្យវង្វេងវង្វាន់វិលវល់ ប្រកបដោយកិលេស
មានអវិជ្ជា និងតណ្ហា ជាដើម ។ កាលបើវដ្តៈ ឋិតនៅក្នុងចិត្ត និង
ចេតសិករបស់សត្វ នៅមានដរាបណា សត្វ ក៏រមែងស្ទុះស្ទា វិលវល់
នៅក្នុងភព រកទីបំផុតគ្មានដរាបនោះ លុះតែលោកអ្នក មានបារមី
ញាណចាស់ក្លា បានសម្រេចអរហត្ត ទើបអាចកាត់ផ្តាច់នូវវដ្តៈទាំង
នោះចេញបាន។

ក្នុងផ្ទៃនៃអត្ថបទនេះព្រះសម្មាសម្ពុទ្ធទ្រង់លើកឡើងសំដែង
អំពីទុក្ខរបស់បុគ្គល អ្នកធ្វើដំណើរទៅកាន់ផ្លូវឆ្ងាយ គឺ វដ្តៈ ។ បុគ្គល
ណាដើរទៅកាន់ផ្លូវឆ្ងាយ គឺវដ្តៈ បុគ្គលនោះត្រូវទុក្ខប្រកិតជាប់តាម
ជានិច្ច គ្រប់ជំហាន ឬគ្រប់ជាតិ ដូចជាកង់រទេះប្រកិតជាប់តាមជើង
គោ ដែលគេទឹមក្នុងនឹម ពុំនោះសោត ដូចស្រមោល ដែលអន្ទោល
ជាប់តាមប្រាណរបស់បុគ្គល ព្រោះថា បុគ្គលដែលនៅមានពូជ គឺ
កំណើតមិនទាន់អស់ ឬមិនទាន់ផុតរលត់នៅឡើយ តែងតែមាន
ដំណើរវិលវល់នៅក្នុងភពគឺចេញចាកភពមួយទៅកាន់ភពមួយទៀត
ឬចេញចាកកំណើតមួយទៅកាន់កំណើតមួយទៀត ជាប់តៗគ្នា មិន
មានទីបំផុត គ្រាន់តែខ្ពស់ និងទាប ល្អ និងអាក្រក់ ប៉ុណ្ណោះ ទោះបី
ទៅកើតក្នុងកំណើតណា ឬក្នុងភពណា រមែងមានភ្លើងទុក្ខ ជរាទុក្ខ

ព្យាធិទុក្ខ មរណទុក្ខ ជាដើម និងភ្លើងកិលេស មានរាគៈ ទោសៈ មោហៈ ជាដើម ប្រកិតជាប់តាមដុតពោលរាលកំដៅ ឬបៀតបៀន ញាំញីបុគ្គលនោះ ឲ្យរងទុក្ខទោសគ្រោះថ្នាក់គ្រប់ជាតិក្នុងភពនោះៗ ឥតមានស្រាកស្រាន្តឡើយ។បុគ្គលដែលអន្ទោលទៅមកកើតស្លាប់ៗ វិលវល់ក្នុងវដ្តៈនេះដរាបណា ទុក្ខទាំងអស់រមែងជាប់តាមបៀតបៀន បុគ្គលនោះដរាបនោះដែរ បើបុគ្គលមានវដ្តៈអស់ត្រឹមណា ទុក្ខក៏អស់ត្រឹមនោះដែរ។ សេចក្តីទុក្ខទាំងឡាយ មានជរាទុក្ខ និងព្យាធិទុក្ខជាដើម ដែលតាមផ្តន្ទា បៀតបៀនសត្វទាំងឡាយ គ្រប់ៗរូប អាស្រ័យមកអំពីមានឧបាទាន (សេចក្តីប្រកាន់មាំ) ជាបច្ច័យ ឧបាទានដែលកើតមានឡើង អាស្រ័យមកពីតណ្ហា(សេចក្តីប្រាថ្នា)ជាបច្ច័យ តណ្ហាដែលកើតមានឡើង អាស្រ័យមកពី វេទនា (ការដឹងអារម្មណ៍) ជាបច្ច័យ វេទនាដែលកើតមានឡើង អាស្រ័យមកអំពីមានផស្សៈ (ការពាល់ត្រូវអារម្មណ៍) ជាបច្ច័យ ផស្សៈដែលកើតមានឡើង អាស្រ័យមកអំពីមាន អាយតនៈ (ប្រភពជាទីកើត នៃអារម្មណ៍) ជាបច្ច័យ អាយតនៈ ដែលកើតមានឡើង អាស្រ័យមកអំពីមាននាមរូប (នាមធម៌ និងរូបធម៌) ជាបច្ច័យ នាមរូបដែលកើតមានឡើង អាស្រ័យមកអំពីមានវិញ្ញាណ (សេចក្តីដឹងផ្សេងៗ) ជាបច្ច័យ វិញ្ញាណដែលកើតមានឡើង អាស្រ័យមកអំពីមាន សង្ខារ (សភាវៈខាងតាក់តែង ឲ្យកើត) ជាបច្ច័យ សង្ខារដែលកើតមានឡើង អាស្រ័យមកអំពីមាន អវិជ្ជា(សេចក្តីល្ងង់វង្វេង)ជាបច្ច័យ អវិជ្ជាដែលកើតមានឡើង អាស្រ័យមកអំពីមានអាសវៈ(សភាវៈជាទីហូរមកនៃកិលេស) ជាបច្ច័យ អាសវៈដែលកើតមានឡើង អាស្រ័យមកអំពីមាន អវិជ្ជាជាបច្ច័យ។ អវិជ្ជា

និងអាសវៈជាគូប្រាស្រ័យទាក់ទងដល់គ្នានឹងគ្នា អវិជ្ជានេះឈ្មោះថាជាតួអាសវៈ ឬថាអាសវៈជាតួអវិជ្ជាដូច្នេះក៏បាន មួយទៀតអវិជ្ជានេះឈ្មោះថាកើតអំពីអាសវៈក៏បាន ឯអាសវៈឈ្មោះថា កើតអំពីអវិជ្ជាក៏បាន ប្រៀបដូចជាមេមាន់កើតអំពីស៊ុតមាន់ ឯស៊ុតមាន់ក៏កើតអំពីមេមាន់ដូច្នោះដែរ។

អវិជ្ជានេះជាអាសវៈនាំបណ្តាលហេតុដ៏ខ្លាំងក្លា ជាបច្ច័យទាក់ទងដល់កិលេសឯទៀតៗ មានតណ្ហាជាដើមអោយកើតឡើង រហូតដល់ ក ផ្តុំជប់កំណើតសត្វ អោយកើតឡើង ហៅថា ជាតិ។ បើជាតិកើតមានឡើងហើយ ទុក្ខទាំងឡាយ មានជរាទុក្ខ ព្យាធិទុក្ខ និងមរណទុក្ខជាដើម ក៏កើតមានឡើងព្រមគ្នាដែរ បើជាតិមាននៅដរាបណា សត្វទាំងឡាយ ក៏រមែងអាស្រ័យទៅក្នុងវដ្តៈ ដរាបនោះដែរ ។ ព្រោះហេតុនោះ បានជាព្រះអរហន្តសម្មាសម្ពុទ្ធ ទ្រង់សំដែងថា បុគ្គលអ្នកដើរទៅកាន់ផ្លូវឆ្ងាយ គឺវដ្តៈ រមែងត្រូវសេចក្តីទុក្ខជាប់តាមហេតុនោះ បុគ្គលមិនត្រូវដើរទៅកាន់ផ្លូវឆ្ងាយ គឺវដ្តៈ ទាំងមិនត្រូវបណ្តោយខ្លួនឲ្យសេចក្តីទុក្ខជាប់តាមឡើយ។

នៅទីបញ្ចប់ នៃធម្មទេសនា របស់ព្រះមានព្រះភាគហើយ ភិក្ខុនោះក៏នឿយណាយ ចំពោះទុក្ខទាំង៥យ៉ាង ដែលព្រះអង្គទ្រង់លើកឡើងសំដែងចំពោះខ្លួន ហើយទំលាយនូវសំយោជនៈទាំងពីរ ចំណែកខាងក្រោម៥ និងចំណែកខាងលើ៥ ហើយបានឋិតនៅក្នុងអរហត្តផលផុតចាកវដ្តៈត្រឹមនេះឯង។

ចប់ ទុក្ខធម្មកថា។

ព្រះទេពសត្ថា កិម តូរ

# ៤. ទសបារមី

ព្រះពោធិសត្វនៃយើង កាលទ្រង់ចាប់ជាតិទាំង១០(ដែលហៅថាទសជាតិ) ក្នុងជាតិនីមួយៗទ្រង់ខំកសាងបំពេញបារមីដោយតឹងរ៉ឹងហ្មឹងហ្មាត់មិនដែលបន្ធូរបន្ថយឬបណ្តោតបណ្តោយសោះឡើយ។

សួរថា បារមី ប្រែថា ដូចម្តេច? អធិប្បាយយ៉ាងណា?

ឆ្លើយថា បារមីស័ព្ទនេះលោកប្រែបានច្រើនយ៉ាង តែក្នុងទីនេះយកតែស័ព្ទពីរយ៉ាងមកប្រែព្រមទាំងអធិប្បាយដូចមានសេចក្តីតទៅ

១. បារមី ប្រែថាគុណជាតិជាគ្រឿងដល់នូវព្រះនិព្វាន ព្រោះតែកិរិយាកសាងនូវបុណ្យកុសលអ្វីមួយដែលសម្បយុត្តដោយបញ្ញា។

២. បារមី ប្រែថាការរក្សា ឬការបំពេញនូវគុណធម៌អ្វីមួយដែលជាធម៌ដ៏ខ្ពង់ខ្ពស់។

សេចក្តីអធិប្បាយ ធម៌ទាំងឡាយណា ដែលជាគុណ ដ៏វិសេស មានទាន សីល ភាវនា ជាដើម ដ៏សម្បយុត្តដោយបញ្ញា ប្រាសចាក តណ្ហា ទិដ្ឋិ មានៈ លោភៈ ទោសៈ មោហៈ ធម៌ទាំងឡាយនោះ ឈ្មោះថា បារមី។

ធម៌ទាំងឡាយណា ដែលមិនមានគុណវិសេស មានទាន សីល ភាវនា ជាដើម ដ៏ប្រាសចាកបញ្ញា ហើយសម្បយុត្តតែដោយ តណ្ហា ទិដ្ឋិ មានៈ លោភៈ ទោសៈ មោហៈ ធម៌ទាំងឡាយនោះ មិនឈ្មោះថា បារមីទេ។

ទាន សីល ភាវនាណា ដែលសាធុជនបានធ្វើហើយ ដោយតាំងចិត្តថា មិនចង់បានលាភសក្ការៈ ឬគុណវិសេសផលប្រយោជន៍ពីអ្នកទទួលក្តី ឬក៏មិនប្រាថ្នាយកកេរ្តិ៍ឈ្មោះ យសស័ក្តិ ទៅកើតជា

នេះ ជានោះក្តី គឺធ្វើដោយតាំងចិត្តថា ឲ្យអស់តែកិលេស ពីក្នុងខន្ធសន្តាន ហើយយកព្រះនិព្វានជាគោលប៉ុណ្ណោះ ទាន សីល ភាវនានោះ ទើបឈ្មោះថា បារមីធម៌។

ទាន សីល ភាវនាណា ដែលសាធុជនបានធ្វើហើយ ដោយតាំងចិត្តប្រាថ្នា ចង់បានលាភសក្ការៈ ឬ ទាមទារគុណបំណាច់ ផលប្រយោជន៍ ពីអ្នកទទួលក្តី ចង់ឲ្យគេពោលសរសើរ លើកតំកើងខ្លួនជាអ្នកធំ អ្នកគ្រាន់បើក្តី ឬមានបំណង ចង់ទៅកើតជានេះ ជានោះ ឲ្យបានថ្កុំថ្កើង រុងរឿងក្តី ទាន សីល ភាវនានោះ មិនបានឈ្មោះថា បារមីធម៌ឡើយ។

ពុទ្ធសាសនិកជនណាបានបំពេញកុសលអ្វីមួយប្រកបដោយចិត្តជ្រះថ្លា រីករាយ ទាំងប្រកបដោយ ការចេះដឹង ប៉ិនប្រសប់ វាងវៃ ស្អប់ខ្ពើមធុញទ្រាន់ភពបី ពុទ្ធសាសនិកជននោះបានឈ្មោះថាជាអ្នកបានបំពេញបារមីធម៌ដោយពិត។កុសលនេះហៅថាវិវដ្តគាមិកុសល។

ពុទ្ធសាសនិកជនណាបានបំពេញកងការកុសលអ្វីមួយដោយចិត្តជ្រះថ្លា រីករាយដែរ តែប្រាសចាកបញ្ញា គឺធ្វើដោយ ការល្ងង់ខ្លៅ ហើយប្រាថ្នាភពតូចភពធំ ចង់កើតជានេះជានោះជាដើម ពុទ្ធសាសនិកជននោះមិនបានឈ្មោះថា ជាអ្នកបំពេញបារមីធម៌ទេ។ កុសលនេះ ហៅថា វដ្តគាមិកុសល។

## បារមីមាន១០យ៉ាង

១. ទានបារមី, ២. សីលបារមី, ៣. នេក្ខម្មបារមី, ៤. បញ្ញាបារមី, ៥.វិរិយបារមី, ៦. ខន្តីបារមី, ៧. សច្ចបារមី, ៨. អធិដ្ឋានបារមី,

៩. មេត្តាបារមី, ១០. ឧបេក្ខាបារមី។ ក្នុងបារមីមួយៗ លោកចែកចេញជាបីៗ រួមត្រូវជាបារមី៣០គត់។

បារមី ទាំង៣០នេះ ព្រះពុទ្ធ ជាគ្រូនៃយើងក្តី ព្រះបច្ចេកពុទ្ធ និងអនុពុទ្ធក្តីឬព្រះអសីតិសាវ័កក្តី សុទ្ធតែបានបំពេញបារមីទាំងនេះគ្រប់ៗអង្គ គ្រាន់តែមានបំណងប្រាថ្នា និងការកសាង ធូន់ដោយបារមីនេះ បារមីនោះ ខុសៗគ្នា ប៉ុណ្ណោះ អង្គខ្លះ ប្រាថ្នាជាពុទ្ធភូមិ អង្គខ្លះ ប្រាថ្នាជា បច្ចេកភូមិ អង្គខ្លះ ប្រាថ្នាជាសាវ័កភូមិ ម្ល៉ោះហើយ លទ្ធផល គឺផលដែលបានសម្រេចនៃលោកទាំងនោះ ក៏ទៅជាធូន់ស្រាល យូរឆាប់ ស្រណុកពិបាក តាមលំដាប់ថ្នាក់ ឧបនិស្ស័យវាសនាប៉ុណ្ណោះឯង។

## ១. ទានបារមី

ការបរិច្ចាគធនទ្រព្យ ឲ្យទៅជាទាន ដោយចិត្តមេត្តា ប្រណីអាណិត ខ្លោចផ្សាទូទៅ ចំពោះមនុស្ស សត្វមិនរើសមុខ ទាំងមិនប្រាថ្នា ទាមទារបំណាច់ ផលប្រយោជន៍ អំពីមនុស្ស សត្វ អ្នកទទួលវិញឡើយ គឺតាំងចិត្តថា បរិច្ចាគធនទ្រព្យនេះ អោយអស់តែ សេចក្តីកំណាញ់ពីក្នុងខន្ធសន្តានប៉ុណ្ណោះ យ៉ាងនេះហៅថា ទានបារមី ៗ ប្រែថា គុណជាតិ ជាគ្រឿងដល់នូវត្រើយ គឺព្រះនិព្វាន ព្រោះការបរិច្ចាគធនទ្រព្យ។ បារមីនេះចែកចេញជា៣យ៉ាងគឺះ

១. បុត្តទារស្សបិ ការបរិច្ចាគ នូវធនទ្រព្យ បុត្រ ភរិយា មិនស្រណោះអាឡោះអាល័យឲ្យទៅជាទាន ហៅថា ទានបារមី។

២. អត្តនោ អង្គស្សបិ ការបរិច្ចាគនូវអវយវៈធំតូចនៃខ្លួន មានសាច់ ស្បែក ឈាម សរសៃ ឲ្យទៅជាទាន ហៅថា ទានឧបបារមី។

៣. ជីវិតស្សបិ ការបរិច្ចាគនូវជីវិត មានពុះទ្រូង រូងយកថ្លើម ប្រមាត់ បេះដូងជាដើម ឲ្យទៅជាទាន ហៅថា ទានបរមត្ថបារមី។

ឧទាហរណ៍ដូចជា...

### វេស្សន្តរជាតក[១]

ព្រះពោធិសត្វចាប់ជាតិជាវេស្សន្តរជាបុត្តព្រះបាទស្រីសញ្ជ័យ ព្រះចៅជេតុត្តរ ព្រះពោធិសត្វអង្គនេះ ទ្រង់បំពេញទានបារមី។

លំដាប់នោះព្រះបាទស្រីសញ្ជ័យទ្រង់អភិសេកព្រះពោធិសត្វ និងព្រះនាងមទ្រីអោយជាអគ្គមហេសី។ ព្រះអង្គមានព្រះរាជបុត្រពីរព្រះអង្គ គឺចៅជាលី និងនាងកណ្ហាជិនា។ ព្រះអង្គ ទ្រង់បំពេញទានបារមី ចំណាយព្រះរាជទ្រព្យអោយជាទានក្នុង១ថ្ងៃៗរាប់សែនកោដិកហាបណៈ ដល់មនុស្សទុគ៌ត សូម្បីតែដំរីបច្ចយនាគ ក៏ទ្រង់បរិច្ចាគទានដែរ។

ឯពួកអ្នកសិវិរាស្ត្រ ខ្លាចក្រែងសាបសូន្យរាជសម្បត្តិ ទើបចូលទៅក្រាបទូលព្រះរាជា ឲ្យបំបរបង់ព្រះពោធិសត្វ ចេញពីនគរ ព្រះពោធិសត្វក៏នាំនាងមទ្រី និងបុត្រាបុត្រីចូលទៅនៅក្នុងព្រៃ។

សម័យថ្ងៃមួយ ព្រះនាងដើររកបេះផលានុផលក្នុងព្រៃ ទុកព្រះរាជបុត្រអោយនៅចាំអាស្រម។ ជួនជាក្នុងកាលនោះ មានជូជកព្រាហ្មណ៍ព្រឹទ្ធាចារ្យចូលទៅសុំព្រះរាជបុត្រ ព្រះពោធិសត្វក៏ប្រទានបុត្រាបុត្រីទាំងពីរអង្គដល់ព្រាហ្មណ៍នោះទៀត។

ក្រោយមក មានឥន្ទព្រាហ្មណ៍ ចូលមកសុំព្រះនាងមទ្រី ព្រះ

---

[១] ជាតកទី១០

អង្គក៏ព្រមប្រទាន ប៉ុន្តែព្រះឥន្ទគ្រាន់តែនិម្មិតបំពេញទានបារមីប៉ុណ្ណោះ ហើយថ្វាយមកវិញ។

ចំណែកឯព្រះបាទស្រីសញ្ជ័យទ្រង់ត្រាស់បង្គាប់អស់នាហ្មឺនសព្វមុខមន្ត្រីឲ្យទៅអញ្ជើញព្រះពោធិសត្វមកសោយរាជសម្បត្តិវិញ ព្រះអង្គក៏ព្រមទទួលដោយព្រះទ័យជាកតញ្ញូតាធម៌ចំពោះគុណូបការនៃព្រះវររាជបិតា។ ព្រះពោធិសត្វ និងនាងមទ្រី ព្រមទាំងបុត្រាបុត្រី បាននៅជាសុខក្សេមក្សាន្ត ក្នុងនគរ ជេតុត្តររៀងទៅ ។ លុះអស់ព្រះជន្មាយុ ក៏បានទៅឧប្បត្តិក្នុងស្ថានតុសិតទេវលោកនាយ។

## ២. សីលបារមី

ការរក្សាកាយ វាចា អោយរៀបរយប្រក្រតី អោយមានចរិយាសណ្តាប់ធ្នាប់ត្រឹមត្រូវល្អក្តី ឬតាំងវិរតិចេតនា វៀរចាកបាប ហើយសមាទាននូវសិក្ខាបទ៥, ៨, ២២០ក្តី សង្រួមឥន្ទ្រីយក្នុងសីល ដែលបានកាន់ប្រព្រឹត្តហើយឲ្យបរិសុទ្ធផូរផង់ មិនឲ្យពព្រុះធ្លុះធ្លាយ ដើម្បីសង្កត់សង្កិន នូវវិតិក្កមទោស ឲ្យឃ្លាតចេញពី ខន្ធសន្តាន ទាំងមិនលុះក្នុងកណ្តាប់ដៃ នៃតណ្ហា គឺមិនប្រាថ្នា ចង់បានស័ក្តិយសនោះៗសោះឡើយ មានតែព្រះនិព្វាន យកមកជាគោលអារម្មណ៍ប៉ុណ្ណោះយ៉ាងនេះ ហៅថា សីលបារមី ។ ប្រែថា គុណជាតិជាគ្រឿងដល់នូវត្រើយ គឺព្រះនិព្វាន ព្រោះតែការរក្សាកាយវាចាឲ្យរៀបរយប្រក្រតី។ បារមីនេះ ចែកចេញជា៣យ៉ាងគឺ ៖

១.បុត្តទារស្សបិ ការរក្សាកាយ វាចា ឲ្យរៀបរយ ប្រក្រតី ឬសង្រួមក្នុងសីល មិនឲ្យពព្រុះធ្លុះធ្លាយ ព្រោះតែបុត្រ ភរិយា ហៅថាសីលបារមី។

២. អត្តនោ អង្គស្សបិ ការរក្សាកាយ វាចា ឲ្យរៀបរយប្រក្រតី ឬសង្រួមក្នុងសីល មិនឲ្យពព្រុះធ្លុះធ្លាយ ព្រោះតែអវយវៈតូចធំរបស់ខ្លួន ហៅថា សីលឧបបារមី។

៣. ជីវិតស្សបិ ការរក្សាកាយ វាចា អោយរៀបរយប្រក្រតី ឬសង្រួមក្នុងសីល មិនឲ្យពព្រុះ ធ្លុះធ្លាយ ព្រោះតែជីវិត ហៅថា សីលបរមត្ថបារមី។ ឧទាហរណ៍ដូចជា......

### ភូរិទត្តកុមា[១]

ព្រះពោធិសត្វចាប់ជាតិជាភូរិទត្ត ទ្រង់បំពេញសីលបារមី។

កាលកន្លងទៅហើយ ព្រះពោធិសត្វទ្រង់ច្យុតមកចាប់បដិសន្ធិក្នុងផ្ទៃនៃនាង សមុទ្ទជា ជាអគ្គមហេសី នៃព្រះបាទធតរដ្ឋ ក្នុងពិភពនាគ។ នាមដើមហៅថា "ទត្តកុមា" ក្រោយមកព្រះអង្គបានឡើងទៅដោះស្រាយបញ្ហាថ្វាយសក្កទេវរាជៗថ្វាយព្រះនាមថា "ភូរិទត្តកុមារ" វិញ ព្រោះមានប្រាជ្ញាលើសទេវតាទាំងពួង។

ភូរិទត្តពោធិសត្វ មានចិន្តាថា "ប្រយោជន៍អ្វី ដល់អាត្មាអញនៅជាសត្វតិរច្ឆានដូច្នេះ គួរតែអាត្មាអញ ទៅរក្សាសីល ឲ្យបរិសុទ្ធក្នុងស្ថានមនុស្ស ប្រសើរជាង" ក៏ថ្វាយបង្គំលាសក្កទេវរាជ មកកាន់ស្ថានមនុស្ស។ ភូរិទត្តទៅព័ទ្ធព័ន្ធ នូវដំបូកមួយ ជិតឆ្នេរ យមុនានទី តាំងសច្ចាធិដ្ឋានថា "អាត្មាអញ នឹងរក្សាឧបោសថសីល បើនរណាមួយ ត្រូវការឆ្អឹងសាច់ឈាមសរសៃស្បែករបស់អញ ក៏ចូរយកតាមប្រាថ្នាចុះ" ហើយផ្ទេចនេត្រាជាសុខក្នុងឧបោសថនោះទៅ។

[១] ជាតកទី៦

កាលនោះ មានព្រាហ្មណ៍អាលម្ពាយ(ហ្មពស់) ម្នាក់ ដើរទៅឃើញព្រះអង្គហើយ ក៏ចូលទៅចាប់ទាញកន្ទ្រាក់ ហែកមាត់ច្រកថ្នាំពិសក្តី វាយដំច្រំធាក់ ជិះជាន់ញាំញី ទាល់តែមានព្រះលោហិតធ្លាក់តាមមាត់ និងនាសិកក្តី ទោះបីព្រាហ្មណ៍ប្រើឲ្យរាំ ស៊ីឈ្នួលអ្នកស្រុកយកផលប្រយោជន៍ មកចិញ្ចឹមប្រពន្ធ កូនក្តី ក៏មិនប្រទូស្ត តប តវិញឡើយ បើជាបើកពពារព្រួសពិស អាចធ្វើឲ្យព្រាហ្មណ៍នោះ ទៅជាផេះក៏បាន ប៉ុន្តែនាគមិនធ្វើដូច្នោះឡើយ តែងតែខំប្រឹងតាំងហឫទ័យឲ្យរឹងប៉ឹងមាំមួនក្នុងសីលរបស់ខ្លួនជាដរាប។ លុះអស់ជន្មាយុក៏បានទៅកើត ក្នុងស្ថានតាវត្តឹង្សទេវលោក សោយទិព្វសម្បត្តិ អស់កាលយូរអង្វែង។

## នេក្ខម្មបារមី

ការចេញចាកកាម ទៅសាងបព្វជ្ជា ដោយចិត្តជ្រះថ្លា ចំពោះសមណភេទក្តី មានចិត្តធុញទ្រាន់នឿយណាយក្នុងទ្រព្យសម្បត្តិបុត្រភរិយា ដែលជាទីស្រឡាញ់ ពេញចិត្ត ក៏ខំស្មឹងស្មាធ៏ចំរើនសមថធម៌និងវិបស្សនាធម៌ ឲ្យកើតឯកគ្គតារម្មណ៍ក្តី ឬក៏មានចិត្តភ័យខ្លាច តក់ស្លុត ចំពោះសត្វ និងសង្ខារ ដែលវិលកើត វិលស្លាប់ រកទីបំផុតគ្មានហើយស្វែងរកពោធិញាណ ដើម្បីកំចាត់បង់នូវកិលេសឲ្យអស់ពីខន្ធសន្តាន យ៉ាងនេះហៅថា នេក្ខម្មបារមី ។ ប្រែថា គុណជាតិជាគ្រឿងដល់នូវត្រើយ គឺព្រះនិព្វាន ព្រោះចេញសាងបព្វជ្ជា។ បារមីនេះចែកចេញជា៣យ៉ាង ៖

១. បុត្តទារស្សបិ ការចេញសាងបព្វជ្ជាឥតជាប់ជំពាក់ទាក់ទាមនឹងបុត្រភរិយា ដែលជាទីស្រឡាញ់ពេញចិត្ត ហៅថា នេក្ខម្មបារមី។

២. អត្តនោ អង្គស្សបិ ការចេញសាងបព្វជ្ជា ឥតគិតដល់អវយវៈតូចធំរបស់ខ្លួន ដែលជាទីគាប់ចិត្ត ហៅថា នេក្ខម្មឧបបារមី។

៣. ជីវិតស្សបិ ការចេញសាងបព្វជ្ជាឥតគិតដល់ជីវិតដែលជាទីស្រឡាញ់បណ្តាច់បណ្តូលរបស់ចិត្ត ហៅថា នេក្ខម្មបរមត្ថបារមី។

ឧទាហរណ៍ដូចជា......

**តេមិយជាតក**[១]

ព្រះពោធិសត្វ ចាប់ជាតិជាតេមិយ បំពេញនេក្ខម្មបារមី។

កាលកន្លងទៅហើយ ព្រះពោធិសត្វច្យុត មកចាប់បដិសន្ធិក្នុងផ្ទៃនៃព្រះនាងចន្ទាទេវី ជាអគ្គមហេសីនៃព្រះបាទកាសិករាជក្នុងក្រុងពារាណសី។ កាលព្រះពោធិសត្វប្រសូតបានព្រះជន្ម១ខែ ព្រះវររាជបិតា ទ្រង់ព្រះរាជទានពរថា នឹងផ្ទេររាជសម្បត្តិ ដល់តេមិយកុមារនេះ។ ព្រះអង្គគ្រាន់តែឮព្រះរាជឱង្ការប៉ុណ្ណោះ ក៏មានព្រះទ័យនឹកព្រួយជាខ្លាំង ព្រោះព្រះអង្គមានព្រះទ័យនឿយណាយក្នុងកិលេសកាម និងវត្ថុកាម ដោយយល់ឃើញថា "រាជសម្បត្តិនេះ ដែលធ្វើខ្លួនឲ្យធ្លាក់ ទៅក្នុងនរក វិលកើត វិលស្លាប់ រកទីបំផុតមិនឃើញ" ទើបព្រះអង្គធ្វើជាមនុស្សគខ្វិនថ្លង់។ ទុកជាព្រះវរមាតាបិតា លួងលោមយ៉ាងណាក្តី គំរាមកំហែងដោយឧបាយផ្សេងៗក្តីព្រះបរមពោធិសត្វនៅតែមិនព្រមធ្វើតាម ទើបព្រះវរបិតា ទ្រង់ប្រើសុនន្ទសារថី ឲ្យចាប់ព្រះអង្គយកទៅកប់ចោលក្នុងរណ្តៅ។

ពេលនោះ ព្រះពោធិសត្វ ទ្រង់ដោះព្រះអង្គ រួចពីគ្រោះថ្នាក់ហើយ ទើបបណ្តេញសុនន្ទសារថី អោយត្រឡប់មកវិញ ដើម្បីថ្វាយ

---

[១] ជាតកទី៣

ដំណឹង ដល់ព្រះវរមាតាបិតា ឲ្យបានជ្រាបថា "ព្រះអង្គ មិនមែនជាមនុស្សគខ្វិនថ្លង់ទេ ដែលធ្វើដូច្នោះ ព្រោះមិនត្រូវការរាជសម្បត្តិទេតើ!"។ តពីនោះមក ព្រះអង្គទ្រង់បំពេញនេក្ខម្មបារមី ចេញទៅទ្រង់ផ្នួសនៅក្នុងព្រៃ។

ព្រះវរមាតាបិតា បានជ្រាបដំណឹងហើយ ក៏លើកសេនាទៅតាមព្រះអង្គឲ្យមកសោយរាជសម្បត្តិវិញ លុះបានស្ដាប់ធម្មទេសនាក៏កើតសង្វេគ ទើបនាំគ្នាចូលកាន់បព្វជ្ជាក្នុងពេលនោះឯង។

## ៤. បញ្ញាបារមី

ការដឹងច្បាស់នូវ សាមញ្ញលក្ខណៈ មានអនិច្ចលក្ខណៈ ជាដើមក្ដី ការកំណត់ដឹងនូវ បញ្ចក្ខន្ធ ដោយចំណែកៗ មានរូបក្ខន្ធ ជាដើមក្ដី ការឈ្វេងយល់ ដោយឧបាយនៃសេចក្ដីករុណា ចំពោះសត្វទាំងឡាយឲ្យរួចចាកទុក្ខ គឺការកើតចាស់ឈឺស្លាប់ក្នុងភពវដ្ដសង្សារក្ដី ការត្រិះរិះពិចារណាពិនិត្យពិច័យ ចំពោះហេតុផលប្រយោជន៍និងឥតប្រយោជន៍ ឲ្យសត្វទាំងឡាយមិនរើសមុខក្ដី ហៅថា បញ្ញាបារមី ៗ ប្រែថា គុណជាតិជាគ្រឿងដល់នូវត្រើយ គឺព្រះនិព្វាន ព្រោះការដឹងច្បាស់ ឬការវិនិច្ឆ័យ។ បារមីនេះចែកចេញជា៣យ៉ាងគឺ៖

១. បុត្តទារស្សបិ ការដកចិត្តផុតស្រឡះ អំពីគ្រឿងឧបករណ៍និងបុត្តភរិយា ហើយធ្វើនូវការត្រិះរិះវិនិច្ឆ័យចំពោះប្រយោជន៍និងមិនមែនប្រយោជន៍ដល់សត្វទាំងឡាយឥតរើសមុខហៅថា បញ្ញាបារមី។

២. អត្តនោ អង្គស្សបិ ការដកចិត្តផុតស្រឡះអំពីអវយវៈតូចធំរបស់ខ្លួន ហើយធ្វើនូវការត្រិះរិះវិនិច្ឆ័យចំពោះប្រយោជន៍និងមិនមែនប្រយោជន៍ដល់សត្វទាំងឡាយឥតរើសមុខហៅថាបញ្ញាឧបបារមី។

៣. ជីវិតស្សបិ ការដកចិត្តផុតស្រឡះ អំពីជីវិត គឺការរស់នៅ ហើយធ្វើនូវការត្រិះរិះវិនិច្ឆ័យចំពោះប្រយោជន៍និងមិនមែនប្រយោជន៍ ដល់សត្វទាំងឡាយឥតរើសមុខ ហៅថា បញ្ញាបរមត្ថបារមី។

ឧទាហរណ៍ដូចជា......

**មហោសថជាតក[១]**

ព្រះពោធិសត្វចាប់ជាតិជាព្រះមហោសថបំពេញបញ្ញាបារមី។ កាលកន្លងទៅហើយ ព្រះពោធិសត្វ ទ្រង់ច្យុត មកចាប់បដិសន្ធិ ក្នុងផ្ទៃនៃនាងសុមនាទេវី ជាភរិយារបស់សិរីវឌ្ឍសេដ្ឋី ក្នុងនគរមិថិលា។ កាលប្រសូតមក មហាជនបានសន្មតនាមថា "មហោសថកុមារ" ព្រោះកុមារនេះ មានថ្នាំទិព្វនៅក្នុងដៃ។

ខាងក្រោយមក ព្រះរាជាទ្រង់ព្រះនាមវិទេហរាជ សោយរាជសម្បត្តិ ក្នុងនគរមិថិលានោះ បានតាំងមហោសថកុមារ ជាព្រះរាជបុត្រច្បង របស់ព្រះអង្គ ដោយហេតុកុមារនេះ មានបញ្ញាឈ្លាសវៃលើសលប់ជាងជននានាទាំងអស់។ លុះពោធិសត្វ មានព្រះជន្មាយុ ១៦វស្សាបានចូលទៅស្តីដណ្តឹងនាងអមរា ស្ត្រីប្រកបដោយបញ្ចពិធកល្យាណីជាភរិយា។ មហោសថបណ្ឌិត បំពេញបញ្ញាបារមី ដោយបានដោះស្រាយប្រស្នា១៩ប្រការដែលមហាជនសាកសួរ ព្រមទាំងប្រស្នាដទៃទៀតជាច្រើន បានជួយឧបត្ថម្ភព្រះរាជា ឲ្យមានសេចក្តីសុខក្សេមក្សាន្ត ក៏ព្រោះតែប្រាជ្ញារបស់ខ្លួនដែរ។

សម័យថ្ងៃមួយ ព្រះរាជាលើកយក មេណ្ឌបញ្ហា មកសួរថា អ្នកមានបញ្ញា និងអ្នកមានទ្រព្យ អ្នកណាប្រសើរជាង ? មហោសថ

[១] ជាតកទី៥។ ជាមហោសធក៏មាន។ ឱសថ និងឱសធ ប្រើបានដូចគ្នា។

បណ្ឌិតដោះស្រាយថា អ្នកមានបញ្ញាប្រសើរជាង ព្រោះសេចក្តីសុខដ៏ក្រៃលែង បុគ្គល នឹងយកទ្រព្យទៅទិញពុំបានឡើយ មានតែបញ្ញានេះហើយដែលធ្វើឲ្យខ្លួនបាននូវទីរលត់ទុក្ខ។ ព្រះរាជាមានព្រះទ័យសោមនស្សហើយព្រះរាជទានអោយមហោសថបណ្ឌិត នៅជាសុខសប្បាយតរៀងទៅ។

## ៤. វីរិយបារមី

សេចក្តីព្យាយាមជាគុណប្រយោជន៍យ៉ាងសំខាន់ អាចញ៉ាំងកិច្ចការ សេចក្តីប្រាថ្នាគោលបំណងគ្រប់យ៉ាង អោយសម្រេចបាន។ សេចក្តីប្រឹងប្រែង ស្ទឹងស្មាធ៍ ចំពោះកុសលធម៌ ដោយតឹងរ៉ឹង មិនបង្អោនចិត្តឲ្យធ្លាក់ចុះ ក្នុងអំណាចតណ្ហា គឺមិនប្រាថ្នាលាភ សក្ការៈ ឬផលប្រយោជន៍ពីជនដទៃ គឺព្យាយាមដើម្បីនឹងបំបាត់បង់នូវកិលេសឲ្យអស់រលីងពីខន្ធសន្តានប៉ុណ្ណោះ ទោះបីមានទុក្ខតគ្រាក តគ្រាំដូចម្តេច ក៏មិនបន្ធូរបន្ថយលះបង់ សេចក្តីព្យាយាមចោល ហៅថា វីរិយបារមី ។ ប្រែថា គុណជាតិជាគ្រឿងដល់នូវត្រើយគឺព្រះនិព្វាន ព្រោះសេចក្តីព្យាយាម។ បារមីនេះ ចែកចេញជា៣យ៉ាងគឺ៖

១. បុត្តទារស្សបិ សេចក្តីព្យាយាមចំពោះកម្មជាកុសល មានការបរិច្ចាគទ្រព្យធន ជាដើម មិនគិតដល់បុត្រ ភរិយា ដែលជាទីស្រឡាញ់ពេញចិត្តយ៉ាងនេះ ហៅថា វីរិយបារមី។

២. អត្តនោ អង្គប្បច្ចង្គស្សបិ សេចក្តីព្យាយាម ចំពោះកម្ម ជាកុសលយ៉ាងតឹងរ៉ឹង មិនគិតដល់អវយវៈ របស់ខ្លួនយ៉ាងនេះ ហៅថា វីរិយឧបបារមី។

៣. ជីវិតស្សបិ សេចក្តីព្យាយាមចំពោះ កម្ម ជាកុសល យ៉ាង

តឹងរ៉ឹង ស៊ូលះបង់ជីវិត មិនលះបង់សេចក្ដីព្យាយាមចោលយ៉ាងនេះ ហៅថា វីរិយបរមត្ថបារមី។ ឧទាហរណ៍ដូចជា......

**ជនកជាតក[១]**

ព្រះពោធិសត្វចាប់ជាតិជាព្រះជនក បំពេញវីរិយបារមី។

កាលកន្លងទៅហើយ ពោធិសត្វច្យុតចាកទេវលោកមកចាប់បដិសន្ធិ ក្នុងផ្ទៃនៃអគ្គមហេសី ព្រះបាទអរិដ្ឋជនក ក្នុងក្រុង មិថិលាមហានគរ។ ខាងក្រោយមក មានកើតចម្បាំងក្នុងនគរ ព្រះរាជស្វាមីទ្រង់សោយទិវង្គតទៅ ព្រះនាង ក៏ភាសខ្លួន ចេញពីនគរ ស្រាប់តែសក្កទេវរាជនិម្មិតភេទជាបុរសអ្នកបររទេះ មកនាំនាងយកទៅទុកឯក្រុងចម្បាកនគរ។ កាលពោធិសត្វប្រសូតមក ថ្វាយព្រះនាមថា "មហាជនកកុមារ"។ លុះព្រះអង្គមានព្រះជន្មាយុ១៦វស្សា ក៏លាព្រះមាតាត្រឡប់ទៅនគរវិញ ព្រះអង្គជិះសំពៅទៅដល់កណ្ដាលសមុទ្រ មានខ្យល់ព្យុះបោកបែកសំពៅ លិចក្នុងលំហសាគរ មនុស្សស្លាប់អស់នៅសល់តែពោធិសត្វមួយព្រះអង្គឯង ទ្រង់ខំព្យាយាម ហែលទឹកអស់៧ថ្ងៃ ទើបមណីមេខលាទេពធីតា មកស្រង់យកទៅដាក់ក្រោមដើមស្វាយក្នុងឧទ្យានក្បែរនគរមិថិលានោះ។ ពួកមហាជនបានលើកព្រះអង្គឲ្យសោយរាជសម្បត្តិ អភិសេកនាងសិម្ពិនីឲ្យជាអគ្គមហេសី ទើបព្រះអង្គទៅដង្ហែយកព្រះមាតា មកនៅក្នុងនគរមិថិលាវិញ។

ព្រះពោធិសត្វ សោយរាជសម្បត្តិបាន ៧ឆ្នាំ ទ្រង់ ព្យាយាមបរិច្ចាគ ព្រះរាជទ្រព្យឲ្យទាន រក្សាសីលពុំដែលលស់ខាន ព្រះអង្គមានព្រះទ័យនឿយណាយចំពោះកាមសុខ ទើបស្ដេចចេញទៅទ្រង់

---

[១] ជាតកទី២។

ព្រះផ្នួសតាបស នៅក្នុងព្រៃ ខំស្មឹងស្មាធ៍ ព្យាយាមធ្វើ សមណធម៌ អស់មួយពាន់ឆ្នាំ ទើបបានសម្រេចឈាន និងអភិញ្ញា ។ លុះអស់ព្រះជន្មាយុ ក៏បានទៅឧប្បត្តិក្នុងស្ថានព្រហ្មលោក។

## ៦. ខន្តិបារមី

ការអត់ធន់ ចំពោះសេចក្តី លោភ ក្រោធខឹងក្តី ចំពោះការស្រេកឃ្លាន ក្តៅត្រជាក់ ទុក្ខលំបាកក្តី ការទប់ទល់ទ្រាំទ្រចំពោះទោសកំហុសនៃជនដទៃ ដែលព្យាបាទ បៀតបៀន សង្កត់សង្កិន ញាំញីក្តី ហើយមិនប្រទូស្ត តប តទៅវិញ ហៅថាខន្តិបារមីៗប្រែថាគុណជាតិជាគ្រឿងដល់នូវត្រើយ គឺព្រះនិព្វាន ព្រោះការអត់ធន់ ឬអត់ទ្រាំ។ បារមីនេះ ចែកចេញជា៣យ៉ាងគឺ ៖

១. បុត្តទារស្សបិ ការអត់ធន់ទ្រាំ ចំពោះកំហុសនៃបុត្តភរិយា ឬក៏ជនដទៃ ហៅថា ខន្តិបារមី។

២. អត្តនោ អង្គស្សបិ ការអត់ធន់ទ្រាំចំពោះសេចក្តីទុក្ខលំបាកនៃអវយវៈរបស់ខ្លួន ហៅថា ខន្តិឧបបារមី។

៣. ជីវិតស្សបិ ការអត់ធន់ទ្រាំចំពោះការផ្តាច់បង់នូវជីវិត ហៅថា ខន្តិបរមត្ថបារមី។ ឧទាហរណ៍ដូចជា......

### ចន្ទកុមារជាតក[១]

ព្រះពោធិសត្វ ចាប់ជាតិជា ចន្ទកុមារ ជាបុត្រព្រះបាទវសវត្តី ក្នុងក្រុងពារាណសី។ ព្រះពោធិសត្វអង្គនេះ ទ្រង់បំពេញខន្តិបារមី។ ព្រះបាទវសវត្តី ទ្រង់តាំងចន្ទកុមារ ឲ្យជាឧបរាជ តាំងកណ្ឌហាលព្រាហ្មណ៍បុរោហិតអោយជាអ្នកវិនិច្ឆ័យ។ កាលព្រាហ្មណ៍បុរោហិត

[១] ជាតកទី៧។

នោះ បានកាន់ដំណែងតុលាការហើយ ក៏មានចិត្តល្មោភស៊ីសំណូក អំពីប្រជាជន កាត់ក្តីមិនត្រឹមត្រូវតាមច្បាប់។ ព្រះបាទវសវត្តីទ្រង់ជ្រាប ទើបដក កណ្ឌហាលព្រាហ្មណ៍ ចេញពីដំណែង ហើយប្រគល់នាទីនេះ ឲ្យចន្ទកុមារវិញ។

ឯកណ្ឌហាលព្រាហ្មណ៍ តាំងពីថ្ងៃនោះមក តែងគយគន់រំពៃមើលទោសចន្ទកុមារជានិច្ច ប៉ុន្តែរកចន្លោះនឹងចាប់ថ្នាក់ពុំបានសោះ។ ជួនជាក្នុងរាត្រី១ ព្រះវរបិតាទ្រង់សុបិននិមិត្ត ទើបត្រាស់សួរព្រាហ្មណ៍ថា ខ្ញុំឯង យល់សប្តិឃើញថា "បានឡើងទៅកាន់ឋានសួគ៌" តើត្រូវធ្វើបុញ្ញកម្មអ្វី ទើបបានទៅកើតក្នុងឋានសួគ៌ ? ព្រាហ្មណ៍ទុច្ចរិត នឹកឃើញដល់ ចន្ទកុមារ ដែលខ្លួនប៉ងនឹងព្យាបាទនោះ ទើបក្រាបទូលថា"សូមព្រះអង្គសម្លាប់ព្រះរាជបុត្ត ព្រះរាជធីតា និងអគ្គមហេសី ដើម្បីបូជាយញ្ញវិធី ទើបបានទៅកើត ក្នុងឋានសួគ៌"។ ព្រះរាជា ក៏ព្រមធ្វើតាម។ ទើបព្រះអង្គត្រាស់បង្គាប់ឲ្យចាប់ពោធិសត្វ ទៅដាក់ក្នុងទ្រុងបម្រុងនឹងសម្លាប់ តែពោធិសត្វ ឥតមានតក់ស្លុត នឹងសេចក្តី ស្លាប់នោះសោះ ទ្រង់ចេះតែខំបំពេញ ខន្តិបារមី មិនប្រទូស្ត តប តចំពោះព្រាហ្មណ៍នោះឡើយ។ ដោយគុណានុភាពបារមីនេះ ស្រាប់តែក្តៅរំជួលដល់អមរិន្ទ្រាធិរាជ ៗ ក៏ចុះមកស្រែកគំរាម អោយដោះលែងពោធិសត្វភ្លាម។ ពួកមហាជន ក៏ប្រហារព្រាហ្មណ៍នោះស្លាប់ទៅ ហើយបណ្តេញព្រះបាទវសវត្តី ចេញពីនគរ រួចអភិសេក ពោធិសត្វឲ្យសោយរាជសម្បត្តិ ទោះបីពោធិសត្វ អង្វរករគេយ៉ាងណា គេក៏ពុំស្តាប់សោះឡើយ។ លុះអស់ព្រះជន្មាយុ ក៏បានទៅឧប្បត្តិក្នុងទេវលោក។

# ៧. សច្ចបារមី

សេចក្តីទៀងត្រង់ គឺមិនពោលពាក្យកុហក មិននិយាយឲ្យខុសឲ្យភ្លាត់ពីសភាវៈពិត ឬក៏មិនពោលបំផ្លើសឲ្យលើសហួសពីការដឹង ការឃើញដោយតាំងចិត្តបរិសុទ្ធពិតត្រង់ចំពោះសត្វទាំងឡាយទុកដូចជាក្រុមញាតិឬមិត្តភ័ក្តិហើយមិនប្រាថ្នាទាមទារផលប្រយោជន៍គុណបំណាច់អ្វីមួយ អំពីសត្វដទៃនោះឡើយ គឺតាំងចេតនា ឲ្យតែទៀងត្រង់ ដើម្បីកំចាត់បង់នូវមុសាវាទ ដែលជាកិលេសជាតិ ឲ្យឃ្លាតចាកខន្ធសន្តានប៉ុណ្ណោះ យ៉ាងនេះហៅថា សច្ចបារមី ។ ប្រែថា គុណជាតិ ជាគ្រឿងដល់នូវត្រើយ គឺព្រះនិព្វាន ព្រោះសេចក្តីទៀងត្រង់។ បារមីនេះ ចែកចេញជា៣យ៉ាងគឺ៖

១. បុត្តទារស្សបិ ការមិនពោលពាក្យកុហក ឲ្យខុសឲ្យភ្លាត់ពីសភាវៈពិត ព្រោះតែបុត្រភរិយា ហៅថា សច្ចបារមី។

២. អត្តនោ អង្គស្សបិ ការមិនពោលពាក្យកុហក ឲ្យខុសឲ្យភ្លាត់ពីសភាវៈពិត ព្រោះតែអវយវៈរបស់ខ្លួន ហៅថា សច្ចឧបបារមី។

៣. ជីវិតស្សបិ ការមិនពោលពាក្យកុហក ឲ្យខុសឲ្យភ្លាត់ពីសភាវៈពិត ព្រោះតែជីវិតហៅថាសច្ចបរមត្ថបារមី។

ដូចឧទាហរណ៍ថា

### វិធុរជាតក[១]

ព្រះពោធិសត្វចាប់ជាតិជាព្រះវិធុរ បំពេញសច្ចបារមី។

កាលកន្លងទៅហើយ មានព្រះមហាក្សត្រមួយព្រះអង្គ ទ្រង់ព្រះនាម ព្រះបាទធនញ្ជ័យកោរព្យ សោយរាជ្យនៅនគរ ឥន្ទបត្តបុរី

---

[១] ជាតកទី៩។

ព្រះអង្គមានអ្នកប្រាជ្ញមួយរូបឈ្មោះ"វិធុរបណ្ឌិត" សម្រាប់ទូន្មានធម៌ចំពោះព្រះអង្គ ព្រមទាំងស្តេច១២១អង្គទៀត។

សេចក្តីដំណាលថា មានស្តេច៤ព្រះអង្គគឺ: ព្រះឥន្ទ្រាធិរាជ១ ព្រះវរុណនាគរាជ១ ស្តេចសុបណ្ណគ្រុឌ១ ព្រះរាជបុត្ត ព្រះបាទធនញ្ជ័យកោរព្យ១ បានមកជួបជុំគ្នា រក្សាឧបោសថសីល ក្នុងព្រៃឱទ្យានរបស់ព្រះបាទធនញ្ជ័យកោរព្យ។ ស្តេចទាំង៤អង្គនេះ តែងអួតដណ្តើមយកសេចក្តីបរិសុទ្ធរៀងៗខ្លួន ទើបចូលទៅរកព្រះវិធុរបណ្ឌិតអោយកាត់សេចក្តីថ្វាយ។ គ្រានោះ វិធុរបណ្ឌិត វិនិច្ឆ័យថា "បរិសុទ្ធដូចគ្នាទាំង៤អង្គ"។ ធម្មទេសនារបស់ពោធិសត្វក៏ល្បីល្បាញសុសសាយ ជ្រាបដំណឹងដល់ព្រះនាងវិមលាទេវី ជាអគ្គមហេសីនៃវរុណនាគរាជ ទើបព្រះនាងធ្វើឧបាយកលដើម្បីឲ្យបានជួបនឹងពោធិសត្វ។

កាលនោះ បុណ្ណកយក្ខទទួលយកអាសាថា ទៅយកបេះដូងពោធិសត្វឲ្យបាន ទើបបុណ្ណកយក្ខចូលទៅលេងបាស្កាភ្នាល់ជាមួយនឹងព្រះបាទធនញ្ជ័យកោរព្យ តាំងប្តេជ្ញាថា "បើព្រះរាជាចាញ់ នឹងឲ្យសម្បត្តិក្នុងនគរទាំងអស់"។ ព្រះរាជាបរាជ័យចាញ់យក្ខ យក្ខសុំយកតែវិធុរបណ្ឌិតមួយប៉ុណ្ណោះ ព្រះរាជាមិនព្រមឲ្យ ទើបអញ្ជើញពោធិសត្វឲ្យមកកាត់សេចក្តី ពោធិសត្វបំពេញសច្ចបារមី កាត់សេចក្តីថា "ត្រូវតែឲ្យទៅយក្ខជាដាច់ខាត"។ បុណ្ណកយក្ខ ក៏នាំពោធិសត្វ យកទៅសម្លាប់អស់វារៈ៩ដង តែមិនស្លាប់ឡើយ ដោយគុណានុភាពនៃសច្ចបារមី នោះឯង ។ លុះវិធុរបណ្ឌិតអស់ជន្មាយុ ក៏បានឧប្បត្តិក្នុងទេវលោក។

# ៨. អធិដ្ឋានបារមី

ការប្តេជ្ញាដោយផ្លូវចិត្ត ឬការតាំងចិត្តស៊ប់ ក្នុងកុសលធម៌ណាមួយ ដោយសេចក្តីបរិសុទ្ធ មិនលុះក្នុងអំណាចតណ្ហា គឺមិនប្រាថ្នាលាភ សក្ការៈ យសស័ក្តិ ឬផលប្រយោជន៍ពីជនដទៃ ហើយសមាទាននូវកម្មជាកុសលធម៌ដោយសេចក្តីតឹងរ៉ឹងមោះមុតអង់អាចដើម្បីកំចាត់បង់នូវកិលេសាសវៈទាំងពួង ទោះបីមានទុក្ខវេទនាមកជ្រៀតជ្រែក ឬគ្របសង្កត់ដូចម្តេច ក៏មិនបន្ធូរបន្ថយ ឬលះបង់ចិត្តដែលបានតម្កល់ស៊ប់ហើយនោះចោល ហៅថា អធិដ្ឋានបារមីៗ ប្រែថា គុណជាតិជាគ្រឿងដល់នូវត្រើយ គឺព្រះនិព្វាន ព្រោះការតាំងចិត្តស៊ប់ក្នុងកុសលធម៌។ បារមីនេះ ចែកចេញជា៣យ៉ាងគឺៈ

១.បុត្តទារស្សបិ ការតាំងចិត្តស៊ប់ក្នុងកុសលធម៌ដោយមធ្យ័ត្តទោះបីបុត្រ ភរិយា មានទុក្ខលំបាកយ៉ាងណា ក៏មិនបង្អោនចិត្តនឹកដល់បុត្រភរិយាទាំងនោះព្រមទាំងមិនបន្ធូរបន្ថយលះបង់កុសលធម៌ចោល យ៉ាងនេះ ហៅថា អធិដ្ឋានបារមី។

២. អត្តនោ អង្គប្បច្ចង្គស្សបិ ការតាំងចិត្តស៊ប់ក្នុងកុសលធម៌ដោយតឹងរ៉ឹង ទោះបីមានសេចក្តីទុក្ខវេទនា ដល់អវយវៈតូចធំរបស់ខ្លួនយ៉ាងណាក្តី ក៏មិនបន្ធូរបន្ថយ លះបង់កុសលធម៌ចោល យ៉ាងនេះហៅថា អធិដ្ឋានឧបបារមី។

៣. ជីវិតស្សបិ ការតាំងចិត្តស៊ប់ ក្នុងកុសលធម៌ដោយតឹងរ៉ឹងទោះបីមានសេចក្តីអន្តរាយដល់ជីវិតក៏មិនបន្ធូរបន្ថយលះបង់កុសលធម៌ចោល យ៉ាងនេះ ហៅថា អធិដ្ឋានបរមត្ថបារមី។ ដូចមានអតីតនិទានជាឧទាហរណ៍ថា......

## នេមិរាជជាតក[១]

ព្រះនេមិរាជពោធិសត្វ ទ្រង់បំពេញអធិដ្ឋានបារមី។

កាលនោះ ព្រះពោធិសត្វ ចាប់បដិសន្ធិ ក្នុងផ្ទៃនៃ ព្រះអគ្គមហេសី ព្រះមហាក្សត្រក្នុងនគរមិថិលា លុះគម្រប់ទសមាសហើយក៏ប្រសូតមក។ ព្រះមហាក្សត្រប្រទានព្រះនាមថា នេមិរាជកុមារ។

លុះព្រះវរបិតា មានព្រះកេសាស្កូវហើយ ក៏អភិសេក ព្រះនេមិរាជឲ្យគ្រងរាជសម្បត្តិព្រះអង្គ។ព្រះនេមិរាជទ្រង់មានព្រះរាជសទ្ធាបរិច្ចាគព្រះរាជទ្រព្យសាងសាលា៥ ក្នុងសាលាមួយៗទ្រង់ចំណាយ១សែនកហាបណៈរាល់ៗថ្ងៃឲ្យទាន ទ្រង់រក្សាសីល៥ និងឧបោសថកម្មជាប់ជានិច្ច។

រាត្រីមួយព្រះអង្គទ្រង់បរិវិតក្កថា "មានផលអ្វីហ្ន៎! ប្រសើរជាងទាន សីល ភាវនា ដែលអាត្មាអញបានធ្វើមកហើយដែរឬ?" ។ លុះទ្រង់ បរិវិតក្កប៉ុណ្ណោះហើយ ក៏ផ្ទំស្កល់ទៅ ។ ស្រាប់តែដល់ រាត្រីមជ្ឈិមយាម ព្រះអមរិន្ទឥន្ទកោសិយ ក៏ហោះមកដោះស្រាយបញ្ហាថា "អានិសង្សផ្នួសមានផលប្រសើរជាងផលទាំងនេះទៅទៀត"។

កាលបើព្រះអមរិន្ទឥន្ទកោសិយ បានហោះទៅដល់ ស្ថានតាវត្តឹង្សហើយ ក៏ប្រើមាតលីទេវបុត្រ ឲ្យប្រដាប់វេជយន្តរាជរថ ទឹមដោយសេះសិន្ធពទិព្វបរហោះមក អញ្ជើញព្រះពោធិសត្វ ឲ្យស្ដេចយាងទៅកាន់ស្ថានតាវត្តឹង្ស។ លុះទៅដល់ហើយ ព្រះអង្គទេសនាថ្វាយសក្កទេវរាជ ៗ មានសោមនស្ស ចំពោះព្រះអង្គ ក៏បូជាស្ថានតាវត្តឹង្សអោយសោយរាជ្យពាក់កណ្ដាល។ ព្រះអង្គ សំដែងសេចក្ដី

---

[១] ជាតកទី៤។

អរគុណ ហើយក៏លើកថ្វាយទៅសក្កៈវិញ ដោយទ្រង់ព្រះតម្រិះថា "ការសោយសម្បត្តិ ដោយសារអ្នកដទៃ ពុំប្រសើរឡើយ ទុកដូចជារបស់ខ្ចីគេ"។ ទើបព្រះអង្គលាព្រះឥន្ទ្រាធិរាជៗ ក៏ឲ្យមាតលីទេវបុត្រ ទឹមវេជយន្តរាជរថ ជូនព្រះអង្គមកកាន់មិថិលាមហានគរ នាមនុស្សលោកវិញ។

លុះដល់ព្រះកេសាស្កូវហើយ ក៏អភិសេក ព្រះរាជបុត្រ ឲ្យគ្រងរាជសម្បត្តិស្នងព្រះអង្គៗ ក៏ចេញសាងបព្វជ្ជាជាឥសី តាំងព្រះទ័យមាំ ក្នុងពោធិញ្ញាណ ប្រឹងចំរើនសមណធម៌ ដរាបដល់សម្រេចឈាន និងអភិញ្ញា៥ សមាបត្តិ៨។ លុះសោយព្រះទិវង្គតទៅ ក៏បានឧប្បត្តិក្នុងស្ថានព្រហ្មលោកនាយ។

## ៩. មេត្តាបារមី

សេចក្តីស្រឡាញ់រាប់អាន ឬការជិតស្និទ្ធ ប្រជិតប្រជីចំពោះសត្វទាំងឡាយ មិនមានរើសមុខ ដោយចិត្តបរិសុទ្ធ មិនលុះក្នុងអំណាចនៃតណ្ហា គឺមិនមានប្រាថ្នាលាភសក្ការៈ ឬផលប្រយោជន៍ពីអ្នកដទៃឡើយ ដោយមានគោលបំណងតែម្យ៉ាង ដើម្បីឲ្យសត្វបានសេចក្តីសុខចំរើន កុំឲ្យសត្វបានទុក្ខទោសពៃរ៍ ទាំងដើម្បីនឹងកំចាត់បង់នូវទោសព្យាបាទវិហឹសាទិក្កិលេស អោយអស់ពី ខន្ធសន្តាន តែប៉ុណ្ណោះ យ៉ាងនេះហៅថា មេត្តាបារមី ។ ប្រែថា គុណជាតិជាគ្រឿងដល់នូវត្រើយ គឺព្រះនិព្វាន ព្រោះសេចក្តីស្រឡាញ់រាប់អាន។ បារមីនេះ ចែកចេញជា៣យ៉ាងគឺ៖

១. បុត្តទារស្សបិ សេចក្តីស្រឡាញ់ រាប់អាន ចំពោះសត្វទាំងឡាយ ទោះបីសត្វ ដែលបៀតបៀន បុត្រ ភរិយា ក៏មានការរាប់អាន

ចំពោះសត្វទាំងនោះដែរ ហៅថា មេត្តាបារមី។

២. អត្តនោ អង្គស្សបិ សេចក្តីស្រឡាញ់រាប់អានចំពោះសត្វទាំងឡាយ សូម្បីសត្វដែលបៀតបៀនអវយវៈរបស់ខ្លួន ក៏មានការរាប់រកចំពោះសត្វទាំងនោះដែរ ហៅថា មេត្តាឧបបារមី។

៣. ជីវិតស្សបិ សេចក្តីស្រឡាញ់រាប់អានចំពោះសត្វទាំងឡាយ សូម្បីសត្វដែលបៀតបៀនជីវិត ក៏មានការរាប់រកចំពោះសត្វទាំងនោះដែរ ហៅថា មេត្តាបរមត្ថបារមី។ ឧទាហរណ៍ដូចជា......

### សុវណ្ណសាមជាតក[១]

ព្រះពោធិសត្វ ចាប់ជាតិជាសុវណ្ណសាម ទ្រង់បំពេញមេត្តាបារមី។ កាលកន្លងទៅហើយ ពោធិសត្វចាប់បដិសន្ធិក្នុងផ្ទៃនៃនាងទុប្បារិកា ជាភរិយានៃទុក្កុលៈ មាតាបិតាឲ្យនាមថា សាមៈ (ហៅថា សុវណ្ណសាម) នៅក្នុងសាលាដែលវេស្សកម្មទេវបុត្រនិម្មិតឲ្យក្នុងព្រៃហេមពាន្ត។

លុះដល់ព្រះពោធិសត្វដឹងក្តីឡើង មាតាបិតា ក៏ងងឹតចក្ខុទាំងពីរ។ សុវណ្ណសាមកុមារធ្វើការបំរើមាតាបិតា ឥតមានធុញទ្រាន់ឡើយ ព្រមទាំងខំចំរើនមេត្តាព្រហ្មវិហារជាប់ជានិច្ច។ ដោយគុណានុភាពនៃមេត្តាព្រហ្មវិហារនេះ ពោធិសត្វនៅក្នុងទីណាៗ តែងមានពួកម្រឹគចោមរោមជាបរិវារក្នុងទីនោះៗ។ ថ្ងៃមួយសុវណ្ណសាមកាន់ក្អមទៅដងទឹកស្ទឹងមិគសមតា មានហ្វូងម្រឹគចោមរោម ជាបរិវារទៅផង។ គ្រានោះព្រះបាទបិលយក្ខ ជាព្រះចៅក្រុងពារាណសី ស្តេចចេញទៅប្រពាតព្រៃដើម្បីបាញ់ម្រឹគ ទ្រង់បានទតឃើញសុវណ្ណសាម

---

[១] ជាតកទី១។

ពោធិសត្វ ដែលមានម្រឹគចោមរោមជាបរិវារ ដូច្នោះ ក៏លើកធ្នូបាញ់ ម្រឹគ មិនត្រូវម្រឹគ បែរជាត្រូវពោធិសត្វវិញ។ ពោធិសត្វក៏ដួលដេក ប្រះនៀលទូញថា "ឱ! លោកមាតាបិតាអើយ! លោកមុខជាក្សយ ជន្មាយុទាំងពីរនាក់ ពុំខានឡើយ!" ហើយក៏សន្លប់បាត់ស្មារតី ក្នុងទី នោះឯង។

ព្រះបាទបិលយក្ខ ឮនូវស័ព្ទវាចា នៃពោធិសត្វដូច្នោះ ក៏ទៅ នាំមាតាបិតាពោធិសត្វមកកាន់ទីនោះភ្លាម។ លុះមាតាបិតាមកដល់ ហើយ ទើបបួងសួងសច្ចាធិដ្ឋានថា "សូមឲ្យថ្នាំពិសសាបសូន្យចាក បុត្ររបស់ខ្ញុំ ឥឡូវនេះទៅ!"។ លំដាប់នោះ ហេតុទាំង៥យ៉ាង គឺៈ ពោធិសត្វជាសះស្បើយ១ មាតាបិតាមានចក្ខុភ្លឺឡើងវិញ១ អរុណរះ ឡើង១ ជនទាំងអស់បានដល់អាស្រមបទ១ ក៏កើតប្រាកដឡើង។ ពោធិសត្វលុះអស់ជន្មាយុ ក៏បានទៅឧប្បត្តិក្នុងព្រហ្មលោក។

## ១០. ឧបេក្ខាបារមី

ការតាំងចិត្តព្រងើយកន្តើយ មិនមានសោមនស្សទោមនស្ស ក្នុងឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ក្នុងទ្វារទាំង៥ក្តី ការតាំងចិត្តឲ្យនៅ ជាកណ្តាល មិនត្រេកអររីករាយ មិនមានថ្នាំងថ្នាក់អាក់អន់ ចំពោះ សត្វនិងសង្ខារទាំងឡាយ ទោះមានឧបការគុណក្តី មិនមានឧបការ គុណក្តី ឬក៏សត្វដែលគួរស្រឡាញ់រាប់អានក្តី សត្វដែលគួរស្អប់ខ្ពើម ធុញទ្រាន់ក្តី ក៏នៅតែតាំងចិត្ត ឲ្យព្រងើយៗ តាមប្រក្រតីទៅបាន តែងមានស្មារតី នឹកឃើញ ដឹងខ្លួនជានិច្ច មិនភ្លាំងភ្លាត់ យ៉ាងនេះ ហៅថា ឧបេក្ខាបារមី ។ ប្រែថា គុណជាតិជាគ្រឿងដល់នូវត្រើយ គឺ ព្រះនិព្វាន ព្រោះតែការតាំងចិត្តព្រងើយៗ កណ្តាលៗ។ បារមីនេះ

ចែកចេញជា៣យ៉ាងគឺ៖

១. បុត្តទារស្សបិ ការតាំងចិត្តឲ្យព្រងើយកន្តើយចំពោះបុត្រ ភរិយា ព្រមទាំងសត្វនិងសង្ខារ ចិត្តដែលតាំងស៊ប់នៅជាកណ្តាល យ៉ាងនេះ ហៅថា ឧបេក្ខាបារមី។

២. អត្តនោ អង្គស្សបិ ការតាំងចិត្តព្រងើយកន្តើយ ចំពោះ អវយវៈរបស់ខ្លួន ព្រមទាំងចំពោះសត្វនិងសង្ខារ ចិត្តដែលតាំងនៅ ស៊ប់យ៉ាងនេះ ហៅថា ឧបេក្ខាឧបបារមី។

៣. ជីវិតស្សបិ ការតាំងចិត្តព្រងើយកន្តើយ ចំពោះជីវិតព្រម ទាំងចំពោះសត្វនិងសង្ខារ ចិត្តដែលតាំងស៊ប់ នៅជាកណ្តាលយ៉ាង នេះហៅថា ឧបេក្ខាបរមត្ថបារមី។ ឧទាហរណ៍ដូចជា......

**នារទព្រហ្មជាតក**[១]

ព្រះពោធិសត្វជានារទព្រហ្មបំពេញឧបេក្ខាបារមី។ ក្នុងអតីត កាលមានព្រះមហាក្សត្រមួយព្រះអង្គទ្រង់ព្រះនាមអង្គតិរាជ សោយ រាជសម្បត្តិក្នុងក្រុងមិថិលា ដែនវិទេហៈ ទ្រង់មានព្រះរាជធីតាមួយ ព្រះអង្គ ព្រះនាមនាងរុចាទេវី ជាស្ត្រីបរិបូណ៌ដោយប្រាជ្ញា ហើយជា ទីគាប់ព្រះទ័យផង។ មានអាមាត្យ៣នាក់ អាមាត្យទី១ ទី២ ជាសម្មា ទិដ្ឋិ ឯអាមាត្យទី៣ ជាមិច្ឆាទិដ្ឋិ។ អាមាត្យទាំងអម្បាលនោះតែងនាំ សេចក្តីយល់របស់ខ្លួន ទៅក្រាបទូលព្រះរាជាផ្សេងៗគ្នា។

លុះថ្ងៃក្រោយមក ព្រះរាជាក៏ទ្រង់ជឿតាមយោបល់អាមាត្យ ទី៣ ទើបទ្រង់ យាងទៅជួបនឹង លោកគ្រូ គុណាជីវក ទ្រង់ជឿតាម គុណាជីវកជាមិច្ឆាទិដ្ឋិតែងពោលថាគ្មានបុណ្យបាបនរកស្ឋគ៌ឡើយ។

---

[១] ជាតកទី៨។

ហេតុនោះបានជានាងរុចារាជធីតាចូលទៅគាល់សម្តេចព្រះវររាជបិតា ក្រាបបង្គំទូលថា "សូមទ្រង់ព្រះមេត្តាប្រោស កុំជឿស្តាប់ពាក្យគ្រូគុណាជីវក ៗនោះ យល់ខុសទេ សូមព្រះអង្គ លះបង់មិច្ឆាទិដ្ឋិចោលស្រឡះចេញ ទើបបានរួចចាកទោសអំពីលោកន្តរនរក"។ ព្រះបាទអង្គតិរាជ លុះទ្រង់ព្រះសណ្តាប់ហើយ ក៏ទ្រង់អាសូរសំដីបុត្រីណាស់ដែរ ប៉ុន្តែទ្រង់នឹងលះមិច្ឆាទិដ្ឋិចោលចេញពុំបាន។

នាងរុចាទេវីទាល់ប្រាជ្ញា ក៏តាំងសច្ចាធិដ្ឋានបួងសួងដល់ទេវបុត្រ ទេវតានិងព្រហ្មសូមជួយដោះទុក្ខព្រះវរបិតាឲ្យរួចអំពីមិច្ឆាទិដ្ឋិ។

វេលានោះ ក៏ស្រាប់តែជ្រាបដល់ នារទព្រហ្មពោធិសត្វ ៗ ក៏និម្មិតភេទជាឥសី ហើយហោះចុះមកកាន់ នគរមិថិលា សំដែងធម្មទេសនាប្រោស ព្រះបាទអង្គតិរាជ ព្រះរាជាក៏ទ្រង់លះបង់មិច្ឆាទិដ្ឋិបានតាមលំដាប់ មានព្រះរាជហឫទ័យបែរមកខាងសម្មាទិដ្ឋិឡើងវិញ ហើយតាំងរក្សាសីល បរិច្ចាគព្រះរាជទ្រព្យ ឲ្យទានជាប់ជានិច្ចមិនដែលដាច់សោះ។ នារទព្រហ្មពោធិសត្វ ក៏វិលទៅកាន់ព្រហ្មលោកនាយវិញ។

សាធុជនទាំងឡាយ បើមានបំណង ដើម្បីទ្រទ្រង់ ព្រះពុទ្ធសាសនាឲ្យបានរុងរឿងក្តី មានប្រាថ្នាចង់ជួយឧបត្ថម្ភប្រទេសជាតិ ឲ្យបានសុខ ចំរើនក្តី គួរកាន់ ប្រព្រឹត្តតាមលំអាន នៃព្រះពោធិសត្វទាំង ១០ជាតិនោះចុះ ទើបព្រះពុទ្ធសាសនានឹងបានរុងរឿងថ្កុំថ្កើងឋិតថេរចិរកាល ទាំងប្រជាជនក្នុងប្រទេស ក៏បានសុខក្សេមក្សាន្ត រីករាយសប្បាយគ្រប់ៗគ្នា សមតាមគោលបំណងឥតឃ្លៀងឃ្លាតឡើយ។

ព្រះឥន្ទមុនី កែវ វណ្ណា

# ៦. ពហុការធម៌

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស។

កតមេ ទ្វេ ធម្មា ពហុការា។ សតិ ច សម្បជញ្ញញ្ច។ ឥមេ ទ្វេ ធម្មា ពហុការា។ ធម៌២មានឧបការៈច្រើន តើដូចម្ដេចខ្លះ?សតិ សេចក្ដីរលឹក១ សម្បជញ្ញៈ សេចក្ដីដឹងខ្លួន១ ធម៌ទាំង២នេះមានឧបការៈច្រើន

## អធិប្បាយ

ពាក្យថា "សតិ" សេចក្ដីរលឹក ជាតួសោភណចេតសិក។ ឯ "សម្បជញ្ញៈ" សេចក្ដីដឹងខ្លួន ក៏ជាតួចេតសិកដែរ ប៉ុន្តែជាតួបញ្ញា។

គុណធម៌ ២ប្រការនេះ ជាគូគ្នា ប្រាស្រ័យគ្នា ទៅវិញទៅមក លះបង់ចោលគ្នាមិនបាន តែងប្រព្រឹត្តទៅក្នុងករណីយកិច្ចជាមួយគ្នា ដូចស្រមោល តែងអន្ទោលតាមរូប លះបង់ចោលរូបមិនបាន ប្លែកតែសតិជាធម៌មានអាការៈជាភ្នាក់ងារ ខាងការនឹកឃើញចាំបានមិនភ្លេច ចំពោះអំពើរបស់ខ្លួនដែលនិយាយហើយ ដែលគិតហើយ ដែលធ្វើអ្វីៗរួចហើយ អស់កាលយូរអង្វែង ក៏អាចនឹកឃើញ ចាំបានគ្រប់សព្វមិនភាន់ច្រឡំ។

សតិនេះជាធម៌មានឥទ្ធិពលច្រើនជាងធម៌ទាំងពួង ទាំងមានសមត្ថភាពអាចចូលជ្រៀតជ្រក នៅអាស្រ័យក្នុងពួកធម៌ច្រើនយ៉ាងជាអនេកប្បការ ហួសវិស័យនឹងលើកយកមកពណ៌នាក្នុងទីនេះ ឲ្យសព្វគ្រប់ ទាំងអស់បានឡើយ ដូចក្នុងអារក្ខកម្មដ្ឋាន ៤ ត្រង់បទថា "មរណស្សតិ"ប្រែថាធម្មជាតិជាគ្រឿងនឹករលឹកចំពោះសេចក្ដីស្លាប់។ ដូចក្នុងពលធម៌៥មានពាក្យថា "សតិពលៈ" ប្រែថា ស្មារតីចាំបាន ជា

កម្លាំង។ ដូចក្នុងសត្តពោជ្ឈង្គ៧ ត្រង់បទថា "សតិសម្ពោជ្ឈង្គៈ" ប្រែថា សតិជាអង្គនៃធមិជាគ្រឿងត្រាស់ដឹង(នូវចតុរារិយសច្ច)។ ដូចក្នុងអដ្ឋង្គិកមគ្គ៨ត្រង់បទថា"សម្មាសតិ"ប្រែថាស្មារតីជាគ្រឿងរលឹកដោយប្រពៃ គឺរលឹកក្នុងសតិប្បដ្ឋាន៤។ ដូចក្នុងនាថករណធមិ១០ត្រង់បទថា "សតិនាថករណៈ" ប្រែថាធមិជាគ្រឿងធ្វើនូវទីពឹង។ ដូចក្នុងឥន្ទ្រិយ៥ ត្រង់បទថា "សតិន្ទ្រិយំ" ប្រែថាធម្មជាតធ្វើនូវសេចក្តីរលឹកជាធំ។

ឯពាក្យថា សម្បជញ្ញៈ សេចក្តីដឹងខ្លួននោះ គឺភ្នាក់ងារខាងដឹងខ្លួនក្នុងពេលដែលកំពុងធ្វើការងារអ្វីមួយ កំពុងថ្លែងសេចក្តីអ្វីមួយ កំពុងគិតការអ្វីមួយ ជាធមិមានសមត្ថភាពអាចគ្រប់គ្រងរក្សាចិត្តមិនឲ្យងាករេរបែរទៅកាន់ទីដទៃ តាមតែអំពើចិត្តឡើយ។

សេចក្តីថា ចិត្តរបស់បុគ្គលណា ដែលមាន សតិ សម្បជញ្ញៈ គ្រប់គ្រង រក្សាល្អហើយ ចិត្តរបស់បុគ្គលនោះ តែងជ្រើសរើសរកចំពោះតែរបស់ណាដែលល្អ។ ប្រៀបដូចរថទឹមសេះ មានសារថីប៉ិនប្រសប់ឈ្លាសវៃឡើងជិះបរទៅតាមផ្លូវ រមែងលឿនត្រង់ទៅតាមផ្លូវជារថដែលគួរគេ ពិតពិល រមិលមើល មិនទាស់ឆ្គង នឹងភ្នែក របស់មនុស្សទាំងពួង មិនធ្វើឲ្យជនណាមួយ មានសេចក្តីអន្តរាយឡើយ។

ការប្រព្រឹត្ត ធ្វើករណីកិច្ចគ្រប់យ៉ាង របស់មនុស្ស ក្នុងលោកនេះ កាលបើគ្មានសតិសម្បជញ្ញៈរមែងប្រព្រឹត្តធ្វើអ្វីមួយដោយកាយវាចា ចិត្ត ឲ្យភ្លាត់ នាំបណ្តាលឲ្យកើតគ្រោះថ្នាក់ និងសេចក្តីអន្តរាយដល់ខ្លួនផង ដល់អ្នកដទៃផង ព្រោះតែគ្មាន សតិសម្បជញ្ញៈនេះជាហេតុ ដូចរថទឹមសេះដែលគ្មានសារថីបរទេ សេះរមែងស្ទុះនាំរថទៅកាន់ទីផ្តេសផ្តាស ទៅតាមទំនើងចិត្តរបស់វា លុះតែប៉ះដល់ទង្គិចអ្វី

មួយ ដល់នូវការវិនាសរថខូចអសារបង់។

ចំណែកខាងមនុស្សដែលបរិបូណ៌ដោយសតិសម្បជញ្ញៈ បើប្រព្រឹត្តធ្វើអ្វីមួយ ដោយកាយវាចាចិត្ត មិនវិបត្តិខុស ខូចប្រយោជន៍ដែលល្អៗ ជាហេតុនាំអោយបានសេចក្តីសុខចំរើនដល់ខ្លួនផង ដល់អ្នកដទៃផង ព្រោះមានសតិសម្បជញ្ញៈជាហេតុ។

លក្ខណៈ គ្រឿងកំណត់សំគាល់របស់មនុស្ស ដែលប្រកបដោយ សតិ សម្បជញ្ញៈ នោះ គួរជ្រាបអំពីចរិយា ការប្រព្រឹត្ត របស់មនុស្សនោះៗឲ្យដឹងថា មនុស្សណាកាលដែលនឹងលើកជើងឈានដើរទៅខាងមុខ ឬថយក្រោយ មនុស្សនោះ មានស្មារតីប្រុងប្រយ័ត្នជានិច្ចដឹងខ្លួនថា "អាត្មាអញ កំពុងលើកជើង ឈានដើរទៅខាងមុខ ឬថយក្រោយ" កាលឱនកាយខាងមុខក្តី បែរកាយទៅខាងក្រោយក្តី ក៏មានស្មារតីដឹងខ្លួនជានិច្ចថា "អាត្មាអញកំពុងឱនកាយទៅខាងមុខ បែរកាយទៅខាងក្រោយ" កាលដែល ក្រឡេកមើលទៅមុខក្តី ទៅឆ្វេងក្តី ទៅស្តាំក្តី ទៅលើក្តី ទៅក្រោមក្តី ក៏មានស្មារតីដឹងខ្លួនជានិច្ចថា "អាត្មាអញកំពុងក្រឡេកមើលទៅមុខ ឆ្វេង ស្តាំ លើ ក្រោម" ។ល។ កាលដកដង្ហើមចេញវែង ចូលវែង ដកដង្ហើមចេញខ្លី ចូលខ្លី ក៏មានស្មារតីដឹងខ្លួនថា "អាត្មាអញកំពុងដកដង្ហើមចេញវែង ចូលវែង ដកដង្ហើមចេញខ្លី ចូលខ្លី"។

បុគ្គល ដែលប្រកបដោយ សតិ និងសម្បជញ្ញៈ រមែងឃើញភ័យក្នុងវាលវដ្តសង្សារ ដូចអធិប្បាយមកនេះ។

មែនពិត សតិចេតសិក នេះ ជាធម៌សំខាន់បំផុត ខាងធ្វើចិត្តអោយបរិសុទ្ធ ហ្មត់ចត់ល្អ សមដូចពុទ្ធដីកាក្នុងសតិប្បដ្ឋានសូត្រ ថា

"ឯកាយនោ អយំ ភិក្ខវេ មគ្គោ សត្តានំ វិសុទ្ធិយា សោកបរិទេវានំ សមតិក្កមាយ ទុក្ខទោមនស្សានំ អត្ថង្គមាយ ញាយស្ស អធិគមាយ និព្វានស្ស សច្ឆិកិរិយាយ យទិទំ ចត្តារោ សតិប្បដ្ឋានា" "ម្នាលភិក្ខុទាំងឡាយ ផ្លូវគឺសតិប្បដ្ឋាន៤នេះជាផ្លូវមូលតែមួយ(ប្រព្រឹត្តទៅ) ដើម្បីសេចក្តីស្អាតវិសេស នៃសត្វទាំងឡាយ ដើម្បីកន្លងបង់នូវសេចក្តីសោកស្រណោះអាឡោះអាល័យ សេចក្តីខ្សឹកខ្សួលរំជួលចិត្តទាំងឡាយ ដើម្បីរំលត់ទុក្ខនិងទោមនស្សទាំងឡាយ ដើម្បីត្រាស់ដឹងនូវធម៌ដែលគួរត្រាស់ដឹង ជាធម៌សម្រាប់យឺតយោងស្រោចស្រង់សត្វ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវនិព្វាន។

កាលបើបុគ្គល កំពុងតម្កល់ស្មារតី ពិចារណាអារម្មណ៍ណាមួយ ដូចពណ៌នាមកនេះ ចិត្តក៏ជាប់នៅក្នុងកុសលតែម្យ៉ាង បើចិត្តកំពុងជាប់នៅក្នុងកុសលធម៌បែបនេះហើយ ឧបក្កិលេសទាំងឡាយមានអភិជ្ឈាវិសមលោភៈនិងទោសៈជាដើមជាអកុសលក៏រកឱកាសជ្រៀតជ្រកកើតឡើងមិនបាន កាលបើដូច្នេះ ចិត្តក៏ប្រាសចាកមន្ទិលគ្រឿងសៅហ្មង ដល់នូវសភាពជាចិត្តជ្រះថ្លា រាល់ៗខណៈ ដោយលំដាប់។

**លក្ខណៈរបស់សតិមាន២យ៉ាងគឺ**

១. **អបិលាបនលក្ខណា** សតិ មានការមិនភ្លាំងភ្លាត់ ជាលក្ខណៈ។ សតិនេះតែងញ៉ាំងចិត្តរបស់បុគ្គលឲ្យនឹករលឹកឃើញនូវកុសលធម៌ទាំងពួងថាៈ នេះជាសតិប្បដ្ឋាន៤ នេះជាសម្មប្បធាន៤ នេះជាឥទ្ធិបាទ៤ នេះជាឥន្ទ្រិយ៥ នេះជាពលៈ៥ នេះជាពោជ្ឈង្គ៧

នេះជា មគ្គ ប្រកបដោយ អង្គ៨ នេះជា សមថកម្មដ្ឋាន ៤០ នេះជា វិបស្សនាញាណ១០ នេះជាអរិយសច្ច៤ នេះជាវិជ្ជា៨ នេះជាវិមុត្តិ នេះជា លោកុត្តរធម៌។ សតិនេះ តែងដាស់តឿនចិត្ត អោយនឹករលឹកចំពោះកុសល មិនឲ្យភាន់ច្រឡំ ហៅថា អបិលាបនលក្ខណាសតិ។

២. **បគ្គហនលក្ខណា** សតិ មានការផ្គងឡើងនូវចិត្ត ជាលក្ខណៈ។ ការផ្គងឡើងនូវចិត្តនេះថាធម៌នេះមានប្រយោជន៍ ធម៌នេះឥតប្រយោជន៍ ធម៌នេះជាកុសលធម៌ ធម៌នេះជាអកុសលធម៌ហៅថា បគ្គហនលក្ខណាសតិ។ឯសម្បជញ្ញៈ"សេចក្ដីដឹងខ្លួន" មាន៤យ៉ាងគឺ

១. **សាត្ថកសម្បជញ្ញៈ** ដឹងហេតុដែលមានប្រយោជន៍

២. **សប្បាយសម្បជញ្ញៈ** ដឹងហេតុដែលសប្បាយ

៣. **គោចរសម្បជញ្ញៈ** ដឹងហេតុដែលជាទីគោចរ។

៤. **អសម្មោហសម្បជញ្ញៈ** ដឹងហេតុដែលមិនវង្វេង។

ចប់ ពហុការធម៌។

# លោកបាលធម៌

លោកបាលធម៌ ប្រែថា "ធម៌រក្សាលោក"។ មួយទៀតហៅថា "ទេវធម៌" ដូចមានក្នុងខុទ្ទកនិកាយធម្មបទថា ៖

**ហិរិឱត្តប្បសម្បន្នា សុក្កធម្មសមាហិតា**
**សន្តោ សប្បុរិសា លោកេ ទេវធម្មាតិ វុច្ចរេ។**

សប្បុរសទាំងឡាយ អ្នកមានចិត្តស្ងប់រម្ងាប់ បរិបូណ៌ដោយហិរិនិងឱត្តប្បៈ ជាអ្នកមានចិត្តតំកល់នៅក្នុងធម៌ស អ្នកប្រាជ្ញពោលថា ជាបុគ្គលមានទេវធម៌ក្នុងលោក។

ក្នុងទីឃនិកាយត្រង់សង្គីតិសូត្រនៃពួកធម៌ពីរ មានបាលីថា:

**អហិរិកាញ្ច អនោត្តប្បញ្ច។ ហិរិ ច ឱត្តប្បញ្ច។**

សេចក្តីមិនខ្មាសបាប១ សេចក្តីមិនក្តៅនឹងបាប ឬមិនខ្លាចបាប១។ សេចក្តីខ្មាសបាប១ សេចក្តីក្តៅនឹងបាប១។

ហិរិនិងឱត្តប្ប: ក្នុងអាគតដ្ឋានផ្សេងៗ ហៅថា "ទេវធម៌" ខ្លះ ហៅថា "អរិយទ្រព្យ" ខ្លះ ហៅថា "លោកបាលធម៌" ខ្លះ។

ពាក្យថា"លោក"បានដល់លោកទាំង៣យ៉ាង គឺសង្ខារលោក១ សត្វលោក១ ឱកាសលោក១។ លោករាប់តាំងអំពីសត្វទាំងអស់ដែលរស់នៅបានដោយអាហារ ចាត់ជាលោកមួយ ជាដើម រហូតដល់ធាតុទាំង១៨ ជាលោក១៨ ជាទីបំផុត ហៅថា "សង្ខារលោក"។

លោកនេះ លោកខាងមុខ ទេវលោក មនុស្សលោក ឬថាលោកទៀង លោកមិនទៀងជាដើម ហៅថា "សត្វលោក"។

ព្រះចន្ទ្រ និងព្រះអាទិត្យ មានសេចក្តីរុងរឿងផ្សេងគ្នា ដើរប្រទក្សិណបំភ្លឺគ្រប់ទិសរហូតអស់ទីមួយពាន់លោកធាតុជាប្រមាណ អំណាចនៃព្រះចន្ទ្រ និងព្រះអាទិត្យ ប្រព្រឹត្តទៅក្នុងលោកធាតុទាំងមួយពាន់នុ៎ះឯង ហៅថា "ឱកាសលោក"។

បណ្តាលោកទាំងនោះ ក្នុងទីនេះ សំដៅយកសត្វលោក គឺមនុស្ស។ មនុស្សនេះ តែងមានសេចក្តីអន្តរាយ វិនាសទៅ ដោយប្រការផ្សេងៗ ឯធម៌ដែលគ្រប់គ្រង ថែរក្សាមនុស្ស ឲ្យបានសេចក្តីសុខចំរើន និងសន្តិភាព ហៅថា "លោកបាលធម៌"។ លោកបាលធម៌នេះ មាន២យ៉ាងគឺ ហិរិ១ ឱត្តប្ប:១។

ហិរិប្រែថា "សេចក្តីខ្មាសបាប" គឺ(ធម្មជាត) ខ្មាសឬខ្ពើមអំពើ

ទុច្ចរិត មានកាយទុច្ចរិតជាដើម។

ឱត្តប្បៈ ប្រែថា "សេចក្តីខ្លាចបាប" គឺ(ធម្មជាតិ) តក់ស្លុត ឬខ្លាចអំពើទុច្ចរិត មានកាយទុច្ចរិតជាដើម។

## សេចក្តីអធិប្បាយ

១. ហិរិ សេចក្តីខ្មាសបាប ជាអជ្ឈត្តសមុដ្ឋាន (មានហេតុខាងក្នុង ជាសមុដ្ឋាន) បានសេចក្តីថា ហិរិ កើតឡើង ព្រោះបុគ្គលពិចារណា ហេតុ៤យ៉ាងគឺ:

**១. ជាតឹ បច្ចវេក្ខិត្វា** ព្រោះពិចារណាជាតិ។

**២. វយំ បច្ចវេក្ខិត្វា** ព្រោះពិចារណាវ័យ។

**៣. សូរភាវំ បច្ចវេក្ខិត្វា** ព្រោះពិចារណាសូរភាព។

**៤. ពាហុសច្ចំ បច្ចវេក្ខិត្វា** ព្រោះពិចារណាពាហុសច្ច។

ពាក្យថា "ព្រោះពិចារណាជាតិ" បានសេចក្តីថា ជាតិមាន២យ៉ាង គឺជាតិខ្ពង់ខ្ពស់១ ជាតិថោកទាប១។

ជាតិក្សត្រ និងព្រាហ្មណ៍ ឬជាតិអ្នកមាន ស្តុកស្តម្ភ គឺជាតិគហបតី សេដ្ឋី ហៅថា ជាតិខ្ពង់ខ្ពស់។ ជាតិអ្នកស៊ីរបស់ដែល ឬទាសកម្មករជាដើម ហៅថា ជាតិថោកទាប។

បុគ្គលមានជាតិខ្ពង់ខ្ពស់ កាលបើជួបប្រទះនឹងអំពើបាប មានបាណាតិបាតជាដើមដែលខ្លួនល្មមធ្វើបាន ហើយពិចារណាថា អាត្មាអញមានជាតិខ្ពង់ខ្ពស់ ដោយមហាកុសលដែលខ្លួនបានធ្វើអំពីអតីតពិតៗ បើប្រសិនជាខ្លួនប្រព្រឹត្តធ្វើនូវអំពើបាបនេះ មុខជានឹងបានជាតិដ៏ថោកទាប ក្នុងកាលអនាគតពុំខាន លុះពិចារណា ដូច្នេះហើយ ក៏

ញ៉ាំងហិរិ សេចក្តីខ្មាសបាបអោយកើតឡើង លែងធ្វើអំពើបាប មានបាណាតិបាតជាដើម។ ចំណែកបុគ្គលមានជាតិថោកទាបវិញ កាលបើជួបប្រទះនឹងបាបកម្មមានបាណាតិបាតជាដើម ដែលខ្លួនល្មមធ្វើបាន ហើយពិចារណាថា អាត្មាអញមានជាតិថោកទាបនេះ ព្រោះតែបានធ្វើអំពើអាក្រក់ មានបាណាតិបាតជាដើមអំពីអតីតដោយពិត ប្រសិនបើអាត្មាអញធ្វើអំពើដ៏លាមកនេះ ទៅអនាគតអាត្មាអញមុខជាមានជាតិ ថោកទាបជាងនេះទៀតមិនខាន លុះពិចារណា ដូច្នេះហើយ ក៏ញ៉ាំងហិរិ សេចក្តីខ្មាសបាប ឲ្យកើតឡើង លែងធ្វើបាបកម្មមានបាណាតិបាតជាដើម។

ហិរិកើតឡើង ព្រោះបុគ្គលពិចារណាជាតិដូច្នេះ ទើបឈ្មោះថា "ព្រោះពិចារណាជាតិ"។

ពាក្យថា "ព្រោះពិចារណាវ័យ" សេចក្តីថា វ័យមាន៣យ៉ាងគឺ បឋមវ័យ១ មជ្ឈិមវ័យ១ បច្ឆិមវ័យ១។ វ័យគឺជំនាន់ ឬរយៈកាលនៃអាយុដែលនៅក្មេង ហៅថាបឋមវ័យ ជំនាន់កណ្តាលហៅថា មជ្ឈិមវ័យ ជំនាន់ដែលចាស់ ហៅថា បច្ឆិមវ័យ។

បុគ្គលដែលស្ថិតនៅ ក្នុងបឋមវ័យ កាលជួបប្រទះ បាបកម្មមានបាណាតិបាតជាដើម ដែលខ្លួនល្មមធ្វើបាន ហើយពិចារណាថា អំពើដ៏លាមកនេះ អាត្មាអញមិនគួរធ្វើទេ លុះពិចារណាដូច្នេះហើយ ក៏ញ៉ាំងហិរិ សេចក្តីខ្មាសបាប ឲ្យកើតឡើង លែងធ្វើបាបកម្ម មានបាណាតិបាតជាដើម។

បុគ្គលតាំងនៅក្នុងមជ្ឈិមវ័យ កាលជួបប្រទះ បាបកម្ម មានបាណាតិបាតជាដើមដែលខ្លួនល្មមធ្វើបាន ហើយពិចារណាថា អំពើ

អាក្រក់នេះ អាត្មាអញជាមនុស្សធំ ដឹងគុណទោសខុសត្រូវល្អអាក្រក់ បុណ្យបាប សព្វគ្រប់ហើយ មិនគួរធ្វើទេ លុះពិចារណាដូច្នេះហើយ ក៏ញុំាងហិរិ សេចក្តីខ្មាសបាបអោយកើតឡើង មិនធ្វើបាបកម្ម មាន បាណាតិបាតជាដើម។

បុគ្គលដែលតាំងនៅក្នុងបច្ឆិមវ័យកាលជួបប្រទះអំពើអាក្រក់ ដែលខ្លួនល្មមធ្វើបាន ហើយពិចារណាថា អាត្មាអញជាមនុស្សចាស់ ទទ្រេមទទ្រោមយ៉ាងនេះ មិនគួរធ្វើទេ លុះពិចារណាដូច្នេះហើយ ក៏ ញុំាងហិរិ សេចក្តីខ្មាសបាប អោយកើតឡើង មិនធ្វើបាបកម្ម មាន បាណាតិបាតជាដើម។

ហិរិកើតឡើង ព្រោះបុគ្គលពិចារណាវ័យ ៣យ៉ាង ដូច្នេះ ឈ្មោះថា "ព្រោះពិចារណាវ័យ"។

ពាក្យថា "ព្រោះពិចារណាសូរភាព" សេចក្តីថា ភាពនៃបុគ្គល អ្នកមានកម្លាំងក្លៀវក្លាអង់អាច ហៅថា សូរភាព បុគ្គលមានសូរភាព ទោះគ្រហស្ថក្តី បព្វជិតក្តី កាលជួបប្រទះនឹងបាបកម្ម មានបាណា- តិបាតជាដើមដែលខ្លួនល្មមធ្វើបាន ហើយពិចារណាថា អំពើអាក្រក់ នេះអាត្មាអញជាមនុស្សក្លៀវក្លាក្នុងទីប្រជុំមិនគួរធ្វើទេ លុះពិចារណា ដូច្នេះហើយ ក៏ញុំាងហិរិ សេចក្តីខ្មាសបាបអោយកើតឡើង លែងធ្វើ បាបកម្មដូច្នេះ ឈ្មោះថា "ព្រោះពិចារណាសូរភាព"។

ពាក្យថា "ព្រោះពិចារណាពាហុសច្ច" សេចក្តីថា ភាពនៃ បុគ្គលអ្នកចេះដឹងច្រើន អ្នកស្ទាត់ជំនាញច្រើន ហៅថា ពាហុសច្ចៈ។ បុគ្គល កាលជួបប្រទះ នឹងបាបកម្ម ដែលខ្លួនល្មមធ្វើបាន ហើយ ពិចារណាថា អំពើដ៏លាមកនេះ អាត្មាអញជាអ្នកស្ទាត់ជំនាញច្រើន

ចេះដឹងច្រើន មិនគួរធ្វើទេ លុះពិចារណា ដូច្នេះហើយ ក៏ញ៉ាំងហិរិសេចក្ដីខ្មាសបាបអោយកើតឡើង ដូច្នេះឈ្មោះថា "ព្រោះពិចារណាពាហុសច្ចៈ"។

ហិរិសេចក្ដីខ្មាសបាប ជាអជ្ឈត្តកសមុដ្ឋាន (មានហេតុខាងក្នុងជាសមុដ្ឋាន) ព្រោះពិចារណាហេតុ៤យ៉ាង ដោយប្រការដូច្នេះ។ ហិរិឈ្មោះថាជាអត្តាធិបតេយ្យ (មានខ្លួនជាធំ) ដោយប្រការដូច្នេះ។

ហិរិឈ្មោះថាជិគុច្ឆនលក្ខណៈ(មានការខ្ពើមបាបជាលក្ខណៈ) ឬជាសប្បតិស្សវលក្ខណៈ (មានការជឿស្ដាប់ជាលក្ខណៈ) ដោយប្រការដូច្នេះ។

ហិរិ ជាអករណរសៈ (មានការមិនធ្វើបាបជាកិច្ច)។

ហិរិ ជាសង្កោចនប្បច្ចុបដ្ឋាន មានការរួញរអាក្នុងការធ្វើបាបមានបាណាតិបាតជាដើមជាផល។

ហិរិ ជាអត្តគារវបដ្ឋាន (មានការគោរពខ្លួន) គឺប្រារព្ធយកខ្លួនជាធំ ហើយមិនធ្វើបាបទាំងឡាយ ជាហេតុ។

២. ឱត្តប្បៈ សេចក្ដីខ្លាចបាប ជាពហិទ្ធាសមុដ្ឋាន (មានហេតុខាងក្រៅជាសមុដ្ឋាន)សេចក្ដីថា បុគ្គលកាលជួបប្រទះបាបកម្មដែលខ្លួនល្មមធ្វើបានហើយគិតក្រែងរអែងហេតុខាងក្រៅថា បើអ្នកនឹងធ្វើបាបកម្ម អ្នកមុខជានឹងដល់នូវសេចក្ដីតិះដៀល ក្នុងចំនោមបរិស័ទទាំង៤ពុំខានហើយពិចារណាថាអ្នកចេះដឹងទាំងឡាយនឹងតិះដៀលអ្នក ដូចជាអ្នកក្រុង ដែលស្អប់ខ្ពើមវត្ថុមិនស្អាត ស្មោកគ្រោក ដូច្នោះអ្នកឯងត្រូវលោកអ្នកមានសីលទាំងឡាយ ចៀសវាងហើយ នឹងធ្វើដូចម្ដេចកើត ? លុះពិចារណាដូច្នេះហើយ ក៏មិនហ៊ានធ្វើ បាបកម្ម

មានបាណាតិបាតជាដើម។

ឱត្តប្បៈ ជាលោកាធិបតេយ្យ (មានលោកជាធំ) សេចក្តីថា កុលបុត្រខ្លះ ក្នុងលោកនេះ ប្រារព្ធយកលោក ជាអធិបតី គឺយកអ្នកដទៃអោយជាធំថា លោកសន្និវាសនេះធំណាស់ សមណព្រាហ្មណ៍ទាំងឡាយ អ្នកមានឫទ្ធិ មានចក្ខុទិព្វដឹងចិត្តរបស់អ្នកដទៃ តែងមាននៅក្នុងលោកសន្និវាស ដ៏ធំនោះឯង ។ ពួកលោកទាំងនោះ មើលឆ្ងាយក៏បាន ជិតក៏បាន ដឹងចិត្តដោយចិត្តក៏បាន។ ពួកលោកដឹងអញហើយ មុខជានិយាយ នឹងគ្នាលោកយ៉ាងនេះថា "នែ លោកដ៏ចំរើនទាំងឡាយ! លោកចូរមើល កុលបុត្រនោះចេញចាកផ្ទះ មកបួសដោយសទ្ធា ហើយនៅតែប្រឡាក់ប្រឡូស ដោយអកុសលដ៏លាមកទាំងឡាយទៀត"។ ពួកទេវតាអ្នកមានឫទ្ធិ មានចក្ខុទិព្វ ដឹងចិត្តរបស់អ្នកដទៃ តែងមាននៅប្រាកដក្នុងលោក ពួកទេវតាទាំងនោះ មើលឆ្ងាយក៏បាន ជិតក៏បាន ដឹងចិត្តដោយចិត្តក៏បាន ពួកលោកដឹងអញហើយ មុខជានឹងនិយាយគ្នាយ៉ាងនេះថា "នែលោកដ៏ចំរើនទាំងឡាយ! លោកចូរមើល កុលបុត្រនេះ ចេញចាកផ្ទះ មកបួស ដោយសទ្ធា ហើយនៅតែច្រឡូកច្របល់ដោយអកុសលដ៏លាមកទាំងឡាយទៀត" ។ លុះពិចារណា ដូច្នេះហើយ ក៏លះអកុសលចេញ ហើយចំរើននូវកុសលឲ្យកើតឡើង លះកម្មមានទោសចេញ ញុំាងកម្មមិនមានទោសឲ្យចំរើនឡើង ឈ្មោះថារក្សាខ្លួនឲ្យបរិសុទ្ធ។

ឱត្តប្បៈ ឈ្មោះថា ជាលោកាធិបតេយ្យ (មានលោកជាធំ) ដោយប្រការដូច្នេះ។

ឱត្តប្បៈឈ្មោះថាភយសភាវសណ្ឋិតៈ(តាំងនៅដោយសភាព

គឺសេចក្ដីតក់ស្លុតខ្លាចភ័យក្នុងអបាយ) ហើយមិនហ៊ានធ្វើបាប ព្រោះខ្លាចអបាយនោះ ដូចជាបុគ្គល អ្នកមានប្រាជ្ញា មិនហ៊ានចាប់ដុំដែកក្ដៅដែលភ្លើងកំពុងឆេះរន្ទាលច្រាលឆ្អៅ ព្រោះខ្លាចរលាកដូច្នេះ។

ឱត្តប្បៈ តាំងនៅដោយសភាព គឺសេចក្ដីខ្លាចបាប ដោយប្រការដូច្នេះ។

ឱត្តប្បៈ ជាឧត្តាសលក្ខណៈ (មានសេចក្ដីតក់ស្លុត) ចំពោះអំពើបាបជាលក្ខណៈ ឬជា វជ្ជភិរុកភយទស្សាវិលក្ខណៈ (មានការខ្លាចទោសនិងឃើញភ័យជាលក្ខណៈ) មាន៤យ៉ាងគឺ ៖

- **អត្តានុវាទភយ** ខ្លាចខ្លួនឯងតិះដៀលខ្លួនឯងបាន។
- **បរានុវាទភយ** ខ្លាចបុគ្គលដទៃតិះដៀលខ្លួនឯងបាន។
- **ទណ្ឌភយ** ខ្លាចព្រះរាជអាជ្ញា។
- **ទុគ្គតិភយ** ខ្លាចភ័យក្នុងទុគ្គតិ។

ឱត្តប្បៈ ឈ្មោះថា ឧត្តាសលក្ខណៈ (មានការតក់ស្លុត ខ្លាចបាប ជាលក្ខណៈ) ឬថា វជ្ជភិរុកភយទស្សាវិលក្ខណៈ (មានការខ្លាចទោស ឬឃើញភ័យ) ក្នុងហេតុខាងក្រៅ ៤យ៉ាង ក៏មិនហ៊ានធ្វើបាបជាលក្ខណៈ ដោយប្រការដូច្នេះ។

ឱត្តប្បៈ ជាអករណរសៈ មានការមិនធ្វើបាបជាកិច្ច។

ឱត្តប្បៈ ជាសង្កោចនប្បច្ចុបដ្ឋាន មានការរអាក្រែងរអែងក្នុងការធ្វើបាបជាផល។

ឱត្តប្បៈជាបរគារវបទដ្ឋាន (មានការគោរពកោតក្រែងបុគ្គលដទៃ) ហើយមិនហ៊ានធ្វើបាប ជាហេតុ។ ហិរិ និងឱត្តប្បៈទាំងពីរនេះ ជាគុណប្រាកដ ក្នុងការវៀរចាកបាប ជាធម៌គ្រប់គ្រង រក្សាមនុស្ស

មិនឲ្យមានសេចក្តីវិនាសអន្តរាយ។

មែនពិត មនុស្សក្នុងលោកនេះ ដែលកាប់សម្លាប់ លួចប្លន់ ឆក់ដណ្តើមទ្រព្យសម្បត្តិគ្នា ធ្វើគ្នានឹងគ្នាឲ្យវិនាស អន្តរាយ ដោយប្រការផ្សេងៗ ជាច្រើនបែបច្រើនយ៉ាង ព្រោះតែគ្មានធម៌ ពីរប្រការនេះ សំរាប់គ្រប់គ្រងរក្សា។

សមដូចពុទ្ធភាសិត[១]ថា **ទ្វេមេ ភិក្ខវេ សុក្កា ធម្មា លោកំ បាលេន្តិ។ កតមេ ទ្វេ។ ហិរិ ច ឱត្តប្បំ ច។ ឥមេ ខោ ភិក្ខវេ ទ្វេ សុក្កា ធម្មា លោកំ ន បាលេយ្យុំ ន យិធ បញ្ញាយេថ មាតាតិ វា មាតុច្ឆាតិ វា មាតុលានីតិ វា អាចរិយភរិយាតិ វា គរូនំ ទារាតិ វា សម្ភេទំ លោកោ អគមិស្ស យថា អជេឡកា កុក្កុដសូករា សោណសិគាលា។** "ម្នាលភិក្ខុទាំងឡាយ ធម៌សទាំង២នេះ តែងរក្សានូវលោក។ ធម៌សទាំងពីរនេះ តើដូចម្តេច? ធម៌សពីរនោះគឺ ហិរិ១ ឱត្តប្បៈ១។ ម្នាលភិក្ខុទាំងឡាយ (បើ) ធម៌សទាំងពីរនេះ មិនរក្សានូវលោកទេ លោកគឺមាតាក្តី ម្តាយមីងក្តី ម្តាយធំក្តី ភរិយារបស់អាចារ្យក្តី ប្រពន្ធរបស់គ្រូក្តី ក៏មិនប្រាដកក្នុងលោកនេះដែរ មុខជាដល់នូវ សម្ភេទ (ការច្រឡូកច្របល់) ដូចជា សត្វតិរច្ឆាន គឺពួក ពពែ ចៀម មាន់ ជ្រូក ឆ្កែ និងចចកជាដើមពុំខាន"។

ធម៌ស២យ៉ាងគឺ ហិរិនិងឱត្តប្បៈនេះជាឫសនៃកុសលធម៌ទាំងពួងដែលប្រព្រឹត្តទៅក្នុងភូមិ៤ មានកាមាវចរភូមិជាដើម ជាធម៌ឃុំគ្រងរក្សាលោក អោយបានសន្តិភាព មិនអោយប្រព្រឹត្តទុច្ចរិត មានការ

---

[១] អង្គុត្តរនិកាយទុកនិបាត បឋមបណ្ណាសក កម្មករណៈវគ្គ។

កាប់សម្លាប់គ្នា ជាដើម ទើបឈ្មោះថា "លោកបាលធម៌" ដោយប្រការដូច្នេះ។

មួយទៀត ក្នុងទេវធម្មជាតកថា: សាធុជនទាំងឡាយ អ្នកប្រកបដោយហិរិ និងឱត្តប្បៈ អ្នកតម្កល់នៅមាំក្នុងធម៌ស អ្នកស្ងប់រម្ងាប់ អ្នកប្រាជ្ញទាំងឡាយ មានព្រះពុទ្ធជាដើម ហៅថា "អ្នកទ្រទ្រង់ទេវធម៌ក្នុងលោក"។

ព្រះទេពមុនី ប្រាជ្ញ ប៉ុល

# ៧. សង្គហវត្ថុកថា

ឧបាយសម្រាប់សង្គ្រោះ គឺស្រោចស្រង់គ្នាអោយបានស្រួល ហៅថា "សង្គហៈ" សង្គហៈនោះចែកជា ៤ប្រការគឺ ទាន ការចែករលែកឲ្យ១ បេយ្យវជ្ជៈ ការពោលពាក្យពីរោះគួរចាប់ចិត្ត១ អត្ថចរិយា ការប្រព្រឹត្តអោយជាប្រយោជន៍ដល់គ្នានឹងគ្នា១ សមានតា សេចក្តីស្មោះស្មើ ក្នុងធម៌នឹងបុគ្គលនោះៗ តាមសមគួរ១។

ធម៌៤ប្រការនេះ រមែងប្រមូលជនទាំងឡាយ ឲ្យមូលគ្នាក្នុងលោកប្រៀបដូចជា ភ្លៅរថ ដែលជាស្នូល ជាគ្រឿងញុាំងរថ អោយប្រព្រឹត្តទៅបានដូច្នោះឯង ។ កាលបើសង្គហៈទាំងនេះមិនមានទេ មាតាក្តី បិតាក្តី នឹងមិនគប្បីបាននូវសេក្តីគោរពរាប់អាន ឬបូជា ព្រោះហេតុដែលមានបុត្រឡើយ បណ្ឌិតទាំងឡាយពិចារណាឃើញសង្គហវត្ថុទាំងនេះថាជាកិច្ច ដ៏ប្រពៃហើយ ទើបលោក បំពេញសង្គហធម៌ទាំងនោះ តាមសមគួរដល់កម្លាំង ព្រោះហេតុនោះ បានជាលោកបាននូវគុណសម្បត្តិធំ ជាបុគ្គលគួរឲ្យអ្នកផងគេសរសើរ។

សូមពណ៌នាក្នុងសង្គហវត្ថុកថាជាលំដាប់តទៅ ៖

ការសង្គ្រោះអ្នកដទៃជាចំណែកឧបត្ថម្ភ ជាបវេណីរបស់អ្នកធំ ដែលស្ថិតនៅក្នុងទីជាបុព្វការី គឺ មាតាបិតាមានភារៈខាងសង្គ្រោះបុត្រ អាចារ្យមានភារៈខាងសង្គ្រោះសិស្ស ឥស្សរជនមានព្រះរាជាជាដើមមានភារៈខាងសង្គ្រោះអ្នកដែលត្រូវជ្រកកោនពឹងពាក់។ ជនដែលបានធ្វើសេចក្តីសង្គ្រោះចំពោះរូបអ្នកណាមួយហើយ ឈ្មោះថាជាបុព្វការី របស់អ្នកនោះបាន ជនដែលជាបុព្វការីនោះ គួរទទួលបដិភារៈ គឺកិច្ចធ្វើតបអំពីគេវិញ។

សូម្បីជនដែលជាអ្នកតូចតាច មិនគិតត្រឹមតែប្រយោជន៍ខ្លួន គិតដល់ប្រយោជន៍អ្នកឯទៀតផង គឺមានចិត្តទូលាយផ្សាយសង្គ្រោះញាតិមិត្រ និងជនឯទៀត ជាបុគ្គលស្រឡាញ់រាប់អាន ជួយលើកដំកើងអោយដល់ទីជាអ្នកធំ។ ព្រោះហេតុនោះ ព្រះសម្ពុទ្ធដែលទ្រង់មានដំណើរល្អ ដោយសេចក្ដីប្រតិបត្តិ ចំពោះព្រះអង្គ ទ្រង់នាំសត្វជាពុទ្ធវេនេយ្យឲ្យសម្រេចគុណសម្បត្តិ គឺកិរិយាដំកល់ខ្លួនត្រូវ ព្រះអង្គទ្រង់សំដែងសង្គហឧបាយ ទុកជាផ្លូវ ដូចន័យដែលបាន ពោលទុកខាងដើម រួមចូលដោយសង្ខេបជាបួនគឺ ទានៈ បេយ្យវជ្ជៈ អត្ថចរិយាសមានតា។

ទាន ការអោយនោះ ចែកចេញជាពីរប្រការគឺ ការឲ្យសំដៅចំពោះរូបបុគ្គល ហៅថាបាដិបុគ្គលិកទាន ឬអសាធារណទាន១ ការឲ្យជាសាធារណៈទូទៅមិនចំពោះ ហៅថា សង្ឃទាន ឬសាធារណទាន១។ មាតាបិតាអោយអាហារគ្រឿងប្រដាប់លេង ឬសម្រាប់ប្រើប្រាស់ដល់បុត្រធីតា ក្នុងវេលាដែលនៅកម្លោះក្រមុំ ដូចជាឲ្យទ្រព្យជាដើមទុន ឲ្យទីស្ថានផ្ទះសម្បែង ក្នុងកាលដែលបុត្រធីតាចំរើនវ័យឡើងហើយ ចៅហ្វាយនាយឲ្យទ្រព្យសម្បត្តិ ដល់កូនក្មួយនិងកម្មករញាតិមិត្រចែករបស់ដល់គ្នីគ្នា នេះជាគំរូ នៃបាដិបុគ្គលិកទាន ប៉ែកខាងអនុគ្រោះ។ កូនប្រុស ស្រីដែលមានផ្ទះសម្បែងហើយ បានជូនបាយទឹក និងសំពត់អាវ ដល់មាតាបិតា ដែលចាស់ជរា បើមានដំណើរទៅស្រុកឆ្ងាយ ខំរករបស់អ្វី ដ៏សមគួរមកជូនមាតាបិតា កូនក្មួយ ឬកម្មករជូនរបស់ដល់ចៅហ្វាយនាយ ឬម្ចាស់ជាហេតុសំដែងចំណងមេត្រីភក្ដីទៅរកចៅហ្វាយនាយនោះ នេះជាគំរូនៃបាដិបុគ្គលិក

ទានប៉ែកខាងបូជាគឺតបស្នងសងគុណ។ ឥស្សរជន ឬអ្នកមានទ្រព្យ ផ្សាយមេត្តា អាសូរ ប្រណី ដល់មហាជន ហើយលះបង់ សេចក្តីកំណាញ់ បរិច្ចាគទ្រព្យ លើកថ្នល់ ជីកព្រែក ធ្វើស្ពាន ដើម្បីជាផ្លូវទៅមកស្រួល សង់សាលា ដាំដើមឈើ ជីកស្រះ ដើម្បីជាទីសំណាក់អាស្រ័យតាំងបង្កើតឬទំនុកបំរុងផ្ទះពេទ្យ (អារោគ្យសាលា)រក្សាជម្ងឺ តាំងបង្កើត ឬទំនុកបំរុងសាលាបង្រៀន ជាទីឲ្យចំណេះ ដល់ក្មេងប្រុសស្រី នេះជាគំរូ នៃសាធារណទាន។ ទានមានសភាពយ៉ាងនេះ មានអានិសង្ស ដ៏វិសេសវិសាល ព្រោះពង្រីកសេចក្តីសុខ អោយធំទូលាយ។ ឯសេចក្តីសុខ ដែលជនម្នាក់ៗត្រូវបាន កាលបើប្រៀបផ្ទឹមនឹងសុខ ដែលជនចំនួនច្រើននាក់ត្រូវបាននោះ ឈ្មោះថា សុខយ៉ាងល្មម គឺជាសុខបន្តិចបន្តួច ព្រោះមនុស្សតែម្នាក់នោះ នឹងរស់នៅក៏មិនយូរប៉ុន្មានទេ វត្ថុទាំងពួងមានទ្រព្យជាដើម ដែលមនុស្សតែម្នាក់បានមកនោះ ក៏រមែងឲ្យសម្រេចប្រយោជន៍ បានតែក្នុងវេលាដែលមានជីវិតរស់នៅប៉ុណ្ណោះ លុះដល់ស្លាប់ហើយ ក៏មិនអាចសម្រេចប្រយោជន៍តទៅទៀតបានឡើយ។ ព្រោះហេតុនោះសុខក្តី វត្ថុដែលជាទីតាំងនៃសុខក្តី ដែលជនម្នាក់ៗត្រូវបាន ឈ្មោះថា សុខយ៉ាងតូច។

ឯសុខដែលជនទាំងឡាយ ក្នុងត្រកូលនីមួយៗ គឺមាតាបិតាបុត្រភរិយា រហូតដល់វង្សាគណាញាតិត្រូវបានទូទៅគ្រប់គ្នា សុខនោះ កាលបើប្រៀបនឹងសុខចំពោះខ្លួនមនុស្សម្នាក់ៗវិញ ឈ្មោះថាជាសុខដ៏ធំទូលាយជាង ព្រោះជាសុខ ដែលគេបានច្រើនគ្នា។ បើទុកជាដូច្នោះ សុខចំពោះត្រកូលមួយៗនោះ កាលបើប្រៀបធៀប

នឹងសុខរបស់ជនដែលរួមជាតិ ក៏គង់ឈ្មោះថា ជាសុខបន្ទាប់បន្សំនៅឡើយ។ សុខដែលជនរួមជាតិរួមភាសាដោយច្រើនត្រូវបាន ជាសុខដ៏ធំទូលាយជាង ព្រោះជាសាធារណសុខ បើទុកជាដូច្នោះ គង់មិនទូលាយស្មើនឹងសុខដែលជនក្នុងលោកទាំងមូលត្រូវបាន ព្រោះជាសាធារណសុខមិនមានទីបំផុត សមដូចពុទ្ធភាសិតថា:

មត្តាសុខបរិច្ចាគា បស្សេ ចេ វិបុលំ សុខំ
ចជេ មត្តាសុខំ ធីរោ សម្បស្សំ វិបុលំ សុខំ។

"បើបុគ្គលឃើញសុខដ៏ទូលាយ ព្រោះលះសុខយ៉ាងល្មម អ្នកប្រាជ្ញឃើញសុខដ៏ធំទូលាយ គប្បីលះសុខយ៉ាងល្មមៗនោះចេញទៅ"។

ព្រះពុទ្ធភាសិតនេះមានទំនងគួរឲ្យជនទាំងឡាយជញ្ជឹងនឹកដល់សុខ ដែលជនច្រើនគ្នាត្រូវបាន ថាជាសុខសំខាន់ជាង ហើយនឹងបានលះប្រយោជន៍ ចំពោះខ្លួនចោលចេញ ព្យាយាមប្រឹងធ្វើឲ្យសម្រេចប្រយោជន៍ដល់ជនច្រើនជាអនេក។

បើរំពឹងមើលជីវិត របស់មនុស្សទាំងឡាយ ក៏ឃើញថា ជាធម្មជាតខ្លី តិច មិនប្រព្រឹត្តទៅបានវែង ច្រើនប៉ុន្មានឡើយ។ បើរំពឹងមើលសេចក្តីតាំងនៅនៃត្រកូលក៏ឃើញថា ប្រព្រឹត្តទៅយូរជាងជីវិតបុគ្គលម្នាក់។ បើរំពឹងដល់ សេចក្តីតាំងនៅនៃជាតិ ក៏ឃើញថា តាំងនៅយឺនយូរជាងសេចក្តីតាំងនៅនៃត្រកូលមួយៗ។

កាលបើត្រកូលក្តី ជាតិក្តី តាំងនៅបានត្រឹមណា កេរ្តិ៍ឈ្មោះរបស់ខ្លួន ក៏តាំងនៅបានត្រឹមនោះ ព្រោះមានពូជវង្ស សល់នៅ ។ ដោយហេតុនោះ គួរឃើញប្រយោជន៍ ខាងជនច្រើនជាធំ ជាងចំណែកខាងខ្លួនវិញ រំលែកប្រយោជន៍ចំណែកខ្លួន ដើម្បីឲ្យសម្រេច

ប្រយោជន៍ដល់ជនច្រើនដោយបំណងសុខវិសាលធំទូលាយ ដើម្បីសុខនៃជនច្រើន ទំនុកបំរុង ដល់ជនទាំងឡាយ ដោយអធ្យាស្រ័យផ្សព្វផ្សាយដោយមេត្តា ជាការប្រសើរណាស់ ។ បើទុកជាជនទាំងនោះមិនជាប់ទាក់ទងនឹងខ្លួន ដែលគួរឲ្យអនុគ្រោះទេ សេចក្តីនេះគប្បីឃើញក្នុងការបរិច្ចាគទក្ខិណាទានដល់បព្វជិត ឲ្យទានដល់ជនអនាថា មនុស្សជរា មនុស្សពិការ រហូតដល់រំលែកឲ្យដោយសភាពជាសាធារណៈ។

ក្នុងបាលី ដែលលោកសំដែង សង្ឃទាន ថាមានផលច្រើនជាងបាដិបុគ្គលិកទាន ព្រោះមានផលរីកផ្សាយទូលាយជាងគ្នានោះក៏ដើម្បីសំដែងបញ្ជាក់ឲ្យឃើញសេចក្តីក្នុងដំណើរនេះដែរ។

ទានជាសង្គហឧបាយ ឃិតឃោងចិត្ត របស់អ្នកបានទទួលឲ្យចូលចិត្ត ជិតដិតរាប់រក, មាតាបិតាប្រសិនបើមិនអើពើនឹងចងចិត្តបុត្រទុក ដោយឲ្យទ្រព្យរបស់ផ្សេងៗ តាមកាលវេលាទេ ក៏មិនជាទីស្រឡាញ់នៃបុត្រ ដូចជាបានយកចិត្តទុកដាក់ធ្វើមក អំពីកាលដែលបុត្រនៅកំពុងពេញវ័យ ចៅហ្វាយនាយអ្នកត្បិតត្បៀត ក៏មិនជាទីចូលចិត្ត រាប់អាន របស់កូនក្មួយ ដូចលោកដែលជាអ្នក មានចិត្តទូលាយឡើយ។

សូម្បីបុត្រធីតា និងកូនក្មួយ ក៏ដូចគ្នា លុះតែអើពើ ក្នុងការរំលែក ចែកជូនឲ្យ សំដែងទឹកចិត្តឲ្យអ្នកធំឃើញ ទើបនឹងបានជាទីពេញចិត្ត របស់លោកយ៉ាងច្រើន លោកអ្នកបរិច្ចាគទ្រព្យ ធ្វើជាសាធារណប្រយោជន៍ រមែងជាទីសរសើរនៃមហាជន សុទ្ធសឹងតែមានគេចូលចិត្តទាំងអស់ ប៉ុន្តែការអោយ ដែលចាត់ជាសង្គ្រោះពិត

ប្រាកដនោះ លុះតែទំនុកបម្រុងឲ្យបានប្រយោជន៍ពិតៗ បើមិនរំពឹងមើលផលល្អរបស់អ្នកទទួលទេ ការសង្គ្រោះនោះ នឹងវិនាសខូចទៅវិញក៏សឹងមាន ដូចជាមនុស្សសូមទាន មិនមែនជាមនុស្សជរាពិការអាចនៅរកស៊ីចិញ្ចឹមជីវិតតាមទំនើងខ្លួនឯងបាន ប៉ុន្តែជាមនុស្សផេតអៀនខ្មាស ចេះតែអាស្រ័យកម្លាំងអ្នកដទៃតែប៉ុណ្ណោះ មនុស្សយ៉ាងនេះ បើទុកជាមានគេឲ្យដល់ប៉ុន្មានៗ ក៏មិនអាចនឹងលើកខ្លួនឡើងអំពីរណ្តៅ គឺសេចក្តីក្រីក្របាន ឬមនុស្សកញ្ជះកញ្ជាយ មិនចេះសំច័យទ្រព្យ បើទុកជាបានទ្រព្យដល់ប៉ុន្មាន ក៏មិនរួចអំពីបំណុលអ្នកដទៃឡើយ។

ការឲ្យមិនសម្លឹងមើលផលល្អ ដល់អ្នកបានទទួលយ៉ាងនេះ មិនហៅថា សប្បុរិសទានឡើយ ជនជាសប្បុរស រមែងមិនកំណាញ់ចេះកាន់យកសារប្រយោជន៍នៃទ្រព្យ ដោយទំនុកបម្រុងអ្នកដទៃ។ ទានដែលអ្នកឲ្យចេះធ្វើតែល្មមល្អ ឲ្យមានប្រយោជន៍ទាំងពីរខាង គឺដល់ខ្លួនអ្នកឲ្យ និងអ្នកទទួលយ៉ាងនេះ ទើបហៅថា សង្គ្រោះឃិតយោងពិតប្រាកដ រាប់ថាសង្គហវត្ថុទី១។

បើគ្រាន់តែចេះឲ្យប៉ុណ្ណោះ ប៉ុន្តែមិនចេះនិយាយពីរោះ គួរចាប់ចិត្តផងទេ វត្ថុដែលឲ្យនោះ បើទុកជាច្រើន ក៏ប្រាកដហាក់ដូចជាតិច បើនិយាយពីរោះគួរឲ្យចាប់ចិត្ត ភ័ស្តុភារដែលឲ្យសូម្បីតិច ក៏ប្រាកដហាក់បីដូចជាច្រើន ព្រោះធ្វើឲ្យកើតសេចក្តីស្រឡាញ់ស្និទ្ធស្នាលស្មោះ ព្រោះហេតុនោះ បានជាព្រះសម្ពុទ្ធជាម្ចាស់ចាត់បេយ្យវជ្ជៈ ថាជាសង្គហវត្ថុទី២។

បេយ្យវជ្ជៈប្រែថា ពាក្យដែលពីរោះគួរពេញចិត្តចាប់ចិត្ត ចែក

ជា២ប្រការគឺ បិយវាចា បានខាងវាចាពីរោះ ទន់ផ្អែមជាទីស្រឡាញ់របស់អ្នកស្តាប់១ អត្ថសញ្ហិតាវាចា បានខាងវាចា ប្រកបដោយប្រយោជន៍១ អ្នកណានិយាយដោយពាក្យទន់ផ្អែម ដូចពាក្យហៅរកថា ″អ្នក″ ថា ″នាង″ អ្នកនោះ មានអ្នកផងស្រឡាញ់ដោយពិត ។ ដូចលោកដែលជាឥស្សរជន ឈ្លាសក្នុងបដិសណ្ឋារៈ ពោលពាក្យរាក់ទាក់ ប្រាស្រ័យរួសរាយដល់អ្នកតូចទូទៅគ្រប់ថ្នាក់គ្រប់ជាន់ អាចធ្វើខ្លួនឲ្យជាទីស្រឡាញ់ចូលចិត្តរបស់មនុស្សទាំងឡាយ ចេះនិយាយដឹកនាំឲ្យមានគំនិតធ្វើកិច្ចការដោយសេចក្តីប្រឹងប្រែង ហើយសុចរិតផង ដូចមានគាថាក្នុងគម្ពីរជាតកថា ៖

**មនាបមេវ ភាសេយ្យ នាមនាបំ កុទាចនំ**

**មនាបំ ភាសមានស្ស គរុភារំ ឧទព្វហិ**

**ធនញ្ចនំ អលាភេសិ តេន ចត្តមនោ អហុ**[១]

ក្នុងវេលាណាៗក៏ដោយ បុគ្គលត្រូវពោលតែពាក្យជាទីគាប់ចិត្ត មិនត្រូវពោលពាក្យមិនគាប់ចិត្តឡើយ កាលបើព្រាហ្មណ៍ ពោលពាក្យដែលគាប់ចិត្ត គោ ″នន្ទិវិសាល″ អូសភារៈដែលធ្ងន់រួចទៅបាន ហើយញុំាងព្រាហ្មណ៍ ឲ្យបានទ្រព្យជាកម្រៃ ឯខ្លួនឯង ក៏មានសោមនស្សត្រេកអរដោយសារបានសងគុណព្រាហ្មណ៍។

ក្នុងផ្ទៃរឿង ដំណាលអំពីព្រាហ្មណ៍ បានភ្នាល់នឹងសេដ្ឋី ថាមានគោអាចអូសរទេះផ្ទុករបស់ធ្ងន់ ដែលចងភ្ជាប់គ្នាជាច្រើនទៅរួច ព្រាហ្មណ៍បានពោលពាក្យលួងលោម គោនន្ទិវិសាល ឲ្យមានគំនិតអង់អាច នន្ទិវិសាល អូសរទេះសម្រេច ព្រាហ្មណ៍ឈ្នះបានទ្រព្យ

---

(១) ខុទ្ទកនិកាយ ឯកនិបាត ជាតក បឋមភាគ។

២ពាន់កហាបណៈ។ នន្ទិវិសាលត្រេកអរថា បានតបស្នងសងគុណព្រាហ្មណ៍។ នេះជាសេចក្តីប្រៀបដោយឥស្សរជនអ្នកចេះនិយាយយកចិត្តបរិវារឲ្យធ្វើការងារធ្ងន់ៗបានសម្រេចសមបំណងរបស់ខ្លួន។

អត្ថសញ្ហិតាវាចា គឺវាចា ដែលប្រកបដោយប្រយោជន៍នោះ គឺអ្នកនិយាយ ចូលចិត្តនិយាយដាស់គំនិតអ្នកស្តាប់ ឲ្យប្រុងស្តាប់ចូលចិត្តពន្យល់អ្នកស្តាប់ និយមរាប់អានដោយឃើញប្រយោជន៍ គួរធ្វើតាមដោយពិត។ ព្រះអានន្ទត្ថេរមានបដិភាណក្នុងវាចា ព្រះបរមសាស្តា ទ្រង់លើកដំកើងចំពោះអង្គលោកថា បើបរិស័ទ៤ គឺ ភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ពួកណាមួយចូលទៅរកលោកសូម្បីត្រឹមតែឃើញលោកក៏មានចិត្តត្រេកអរ បើលោកសំដែងធម៌ បរិស័ទទាំងនោះ ក៏មានសោមនស្សរីករាយដោយភាសិតរបស់លោក មិនចេះឆ្អែតមិនចេះនឿយណាយ ដោយកថានោះឡើយ ទាល់តែលោកឈប់ស្ងៀមខ្លួនឯង ប្រៀបដូច ព្រះបាទបរមចក្រពត្តិរាជ អាចញ៉ាំងបរិស័ទ៤ គឺក្សត្រ ព្រាហ្មណ៍ គហបតី សមណៈ គ្រប់ពួកឲ្យត្រេកអរដោយព្រះរាជតម្រាស់របស់ព្រះអង្គដូច្នោះដែរ។

ព្រះបរមសាស្តា ទ្រង់ត្រាស់ទេសនា ដឹកនាំវេនេយ្យសត្វ ឲ្យឃើញដោយបញ្ញាថា យ៉ាងណាជាធម៌ យ៉ាងណាមិនមែនជាធម៌ ពន្យល់ឲ្យលះអធម៌ចោល ហើយឲ្យសមាទាន កាន់យកនូវធម៌ ឲ្យអាចហ៊ាន រីករាយក្នុងកិច្ចនោះៗ អាចបណ្តុះសេចក្តីគោរពរាប់អានរបស់មហាជន ទាំងគ្រហស្ថ និងបព្វជិត ថែមទាំងបានជាសាវ័កដូចព្រះសារីបុត្រ និងព្រះអានន្ទ ដែលឈ្លាសក្នុងវាចា ជាកម្លាំងផងព្រះអង្គអាចប្រតិស្ឋានព្រះពុទ្ធសាសនាតមកបាន។ វាចាល្អកាត់ថ្លៃ

មិនបាន រមែងញ៉ាំងប្រយោជន៍ ឲ្យសម្រេច ទាំងក្នុងការជួបជុំ ទាំងក្នុងការដឹកនាំ រាប់ជាសង្គហវត្ថុទី២។

ការអោយ ការនិយាយពីរោះ ជាគុណចាប់ចិត្តចងមេត្រីបានយ៉ាងស្និទ្ធ ប៉ុន្តែបើជាមនុស្សចេះតែមើលបំណាំទៅវិញទៅមក មិនប្រព្រឹត្តប្រយោជន៍ ដល់គ្នា នឹងគ្នា គ្រាន់តែអោយ គ្រាន់តែនិយាយសម្រួលតាមការដូច្នេះ សេចក្តីស្និទ្ធ ក៏នឹងសាប រលាបទៅវិញបានងាយ។ ព្រោះហេតុនោះ អត្ថចរិយា ការប្រព្រឹត្តអោយជាប្រយោជន៍ដល់គ្នា ទើបជាគុណដ៏សំខាន់ដែលត្រូវតែប្រាថ្នាក្នុងការឃិតយោងចិត្ត របស់គ្នា នឹងគ្នាទៅវិញទៅមក។ អត្ថចរិយា ទើបរាប់ថា ជាសង្គហវត្ថុទី៣។

អត្ថចរិយា គឺការប្រព្រឹត្តិអោយជាប្រយោជន៍នោះ ចែកចេញជាពីរប្រការគឺវេយ្យាវច្ចៈ កិរិយាជួយខ្វល់ខ្វាយដើម្បីញ៉ាំងកិច្ចនោះៗឲ្យសម្រេច១ ធម្មសមាទបនា ការដឹកនាំក្នុងធម៌១។

មាតាបិតាខ្វល់ខ្វាយធ្វើធុរៈឲ្យកូន ដូចឲ្យកូនបានទទួលការសិក្សា ឲ្យតាំងគ្រួសារ និងគេហស្ថានទីលំនៅ ឯកូនប្រុសស្រីជួយខ្វល់ខ្វាយក្នុងកិច្ចការរបស់មាតាបិតា។ឥស្សរជនជួយធុរៈយ៉ាងនោះដល់អ្នកដែលត្រូវការពឹងពាក់ ព្យាបាល ទំនុកបម្រុង អោយមានកេរ្តិ៍ឈ្មោះ យសស័ក្តិ ប្រាកដក្នុងប្រជុំជន រមែងជាទីនិយម រាប់អានរបស់អ្នកពឹងពាក់ អ្នកដែលពឹងពាក់សោតទៀត តាំងចិត្ត ធ្វើកិច្ចការរបស់លោកឲ្យសម្រេចតាមទំនងដែលលោកប៉ុនប៉ង ធ្វើខ្លួនឲ្យលោកជឿជាក់ទុកចិត្តបាន រមែងជាទីស្រឡាញ់ពេញចិត្តរបស់លោក។

មិត្តសំឡាញ់ជួយខ្វល់ខ្វាយកិច្ចធុរៈគ្នាទៅវិញទៅមក ដោយ

កម្លាំងកាយខ្លះ ដោយកម្លាំងវាចាខ្លះ ដោយកម្លាំងគំនិតខ្លះ ឲ្យសមតាមទំនងពុទ្ធភាសិត ថា "**អត្ថម្ហិ ជាតម្ហិ សុខា សហាយា** គ្នីគ្នាទាំងឡាយ កាលបើធុរៈកើតឡើងរមែងជួយឲ្យបានសេចក្ដីសុខ"។ មេត្រីយ៉ាងស្និទ្ធនឹងគ្នាបាននោះ ដោយជួយធុរៈគ្នានឹងគ្នា តាមសណ្ដាប់ញាតិ ទើបរាប់រកគ្នាបានយូរ បើទុកជាមានពូជវង្ស ជិតដិត ដោយកំណើត ប៉ុន្តែរយាលពីគ្នា ដោយជួយធុរៈ ក៏មិនស្និទ្ធ ស្មើនឹងញាតិដែលជួយធុរៈគ្នានោះឡើយព្រោះហេតុនោះបានជាមានពុទ្ធភាសិតថា **វិស្សាសា បរមា ញាតី** ការស្និទ្ធស្នាល រាប់ថាញាតិដ៏ប្រសើរ"។

ធម្មសមាទបនា គឺការដឹកនាំក្នុងធម៌នោះ ដូចការបបួលសិក្សា ឬធ្វើកុសលណាមួយឲ្យស្រុះគំនិតគ្នា មានសាមគ្គីស្និទ្ធស្នាលនឹងគ្នាជាមិត្រតទៅ។ ធម្មកថិកអ្នកទេសនា ដឹកនាំអ្នកដែលឥតសទ្ធា ឲ្យមានសទ្ធា ញុំាងមនុស្សដែលគ្មានសីល ឲ្យជាអ្នកមានសីល ញុំាងមនុស្សដែលប្រព្រឹត្តក្នុងអបាយមុខ ៤យ៉ាងណាមួយ ឲ្យលះអបាយមុខចេញ ការប្រព្រឹត្តិប្រយោជន៍ ដែលធ្វើអោយសមដល់កាល ដល់បុគ្គលដែលឲ្យសម្រេចនូវសុភផលដូចពោលមក រាប់ថាជាសង្គហវត្ថុទី៣។

សូម្បីការឲ្យ ការនិយាយពីរោះដល់កាលវេលាធ្វើប្រយោជន៍ដល់គ្នាដូច្នេះ តែបើមិនចេះរៀបចំខ្លួនឲ្យសមរម្យដល់មាត្រ សមដូចសុភាសិតថា "បង់បោយមិនមើលប្រាណ ដាំចង្ក្រានមិនប្រមាណឆ្នាំង" សេចក្ដីរាប់អានគ្នានោះ ក៏នឹងសាបរលាបទៅវិញ លុះតែអាស្រ័យសេចក្ដីប្រព្រឹត្តិល្មមសមដល់មាត្រផង ទើបនឹងមានការស្និទ្ធមាំឡើងហើយគង់នៅយឺនយូរជាថាវរៈទៅបាន ព្រោះហេតុនោះបានជាព្រះ

តថាគតបរមគ្រូទ្រង់ត្រាស់ថា សមានតា ជាសង្គហវត្ថុទី៤។

សមានតា គឺភាពជាអ្នកស្មោះស្មើក្នុងធម៌នោះៗ ចែកចេញជា២ប្រការគឺ បុគ្គលាធិដ្ឋាន មានបុគ្គលជាទីតាំង១ ធម្មាធិដ្ឋាន មានធម៌ជាទីតាំង១។ ញាតិមានវ័យតិច សូម្បីពិសេសជាងដោយឥស្សរិយយស ដោយភោគសម្ប័ទ ដោយបរិវារ មិនធ្វើមានះក្អេងក្អាងមើលងាយគេ ធ្វើកិរិយាទន់ភ្លន់កោតក្រែងសំពះគំនាប់ដល់ញាតិអ្នកមានវ័យចំរើនជាងខ្លួន អំពីដើមមក ធ្លាប់រាប់អានយ៉ាងណា ខាងក្រោយមកក៏រាប់អានយ៉ាងនោះ។ ញាតិទាំងឡាយបានទទួលសេចក្តីគោរពកោតក្រែងយ៉ាងនោះហើយ រមែងស្រឡាញ់ចូលចិត្តសំដែងអាការរាប់អាន តបទៅវក ធ្វើសាមគ្គីនឹងគ្នាទៅវិញទៅមក ដោយន័យនេះវង្សត្រកូល រមែងតាំងជាពួក សម្រេចបានទៅជាកម្លាំងធំ នេះជាសមានតាក្នុងធម៌គឺអបចាយនៈ បានខាងសេចក្តីគោរពកោតក្រែង។

ឯញាតិដែលស្មើគ្នាដោយជំនាន់វ័យ សំដែងសេចក្តីរាប់អានគ្នាដោយពេញចិត្តមិនមើលងាយគ្នា។ ញាតិដែលជាអ្នកធំមានមេត្តារាប់រកញាតិដែលជាអ្នកតូច ស្និទ្ធស្នាលទៅវិញទៅមក ជួយគ្នាទៅវិញទៅមក គាំពារវង្សត្រកូលរបស់ខ្លួនឲ្យចំរើន សាមគ្គីនៃញាតិនេះរមែងញុំាងសុខអោយកើតមានទូទៅសព្វគ្នា។ ព្រះសព្វញ្ញុពុទ្ធ ទ្រង់លើកឡើងត្រាស់ ជាពាក្យឧបមា ប្រៀបដោយអ្នកប្រាជ្ញថា "**ធីរោ ច សុខសំវាសោ ញាតីនំវ សមាគមោ** អ្នកប្រាជ្ញមានការនៅរួមជាមួយនាំឲ្យបានសុខ ដូចជាការជួបជុំ គឺសេចក្តីព្រមព្រៀង នៃពួកញាតិដូច្នោះដែរ។

មិត្រនឹងមិត្រ ធ្លាប់ស្និទ្ធស្នាលយ៉ាងណា មិត្រម្ខាង មិនរវាត

រយោលដោយសារសេចក្តីចំរើនដែលជួយជ្រោមជ្រែង គង់តែនៅរាប់អានដដែលមិត្រខាងម្ខាងទៀត ស្និទ្ធស្នាលតាមទម្លាប់ពីដើមមិនប្រែប្រួល មិត្រទាំងពីរខាងបានរក្សានូវមិត្រធម៌ឲ្យមាំមួន សូម្បីមិនជាប់ញាតិ គង់អាចចងស្ពាន មេត្រីគ្នាបាន ដោយវិស្សាសៈ ញុំាងប្រយោជន៍ឲ្យសម្រេចបានដូចគ្នា។ ញាតិនឹងញាតិ មិត្រនឹងមិត្ររាប់រកគ្នាដោយរបៀបជា សមានតា បានខាងកិរិយារាប់អាន ទាំងនេះជាបុគ្គលាធិដ្ឋានមានបុគ្គលជាទីតាំង។

ជនអ្នកឋិតនៅក្នុងគណៈ ដូចភិក្ខុសង្ឃរមែងឋិតនៅបានដោយអំណាច មានធម៌ស្មើគ្នា បើមិនដូច្នោះទេ ក៏មិនអាចនឹងរក្សាសាមគ្គីឲ្យគង់នៅបានឡើយ ព្រោះហេតុនោះបានជាលោកដែលជាប្រធាននៃគណៈ ត្រូវបំភ្លឺ ដើម្បីឲ្យមនុស្សទាំងឡាយ ក្នុងគណៈ និយមធ្វើតាមសណ្តាប់ធ្នាប់របស់គណៈ គយគន់ កំចាត់ ប្រាប់បំបាត់មនុស្សដែលល្មើស រក្សាសាមគ្គីរបស់គណៈ ឲ្យមាំមួនឡើង នេះចាត់ជាសមានតា ឬធម្មចរិយាប៉ែកខាងធម្មាធិដ្ឋាន។ សមានតានេះ បើធ្វើឲ្យសមដល់ហេតុផលរបស់បុគ្គល ឬគណៈហើយ រមែងឃិតយោងបុគ្គលនិងគណៈនោះឲ្យនៅក្នុងសាមគ្គី រាប់ជាសង្គហវត្ថុជាគំរប់៤។

សង្គហវត្ថុ ៤ប្រការ រមែងចងរួបរួមសាមគ្គី របស់ជនទាំងឡាយ ក្នុងលោកឲ្យខ្ជាប់មាំ និងឲ្យប្រព្រឹត្តទៅដោយមូលត្រកូលគ្នាប្រៀបដូចជាភ្លៅរថជាស្នូលញុំាងរថឲ្យប្រព្រឹត្តទៅដូច្នោះ។ ប្រសិនបើសង្គហឧបាយទាំងនេះមិនមានទេ គឺថាមិនមានអ្នកអើពើនឹងធ្វើនូវសង្គហធម៌នេះទេ មាតាបិតាមានបុត្រមិនសង្គ្រោះ ក៏មិនត្រូវបានទទួលបដិភារៈអំពីបុត្រឡើយ បណ្ឌិតទាំងឡាយ ពិចារណាឃើញ

សង្គហឧបាយទាំងនេះថា ជាកិច្ចដ៏ប្រពៃ បានប្រកបដោយសមគួរ តាមកម្លាំង បានជាលោកបាននូវគុណសម្បត្តិ ជាទីស្រឡាញ់ រាប់អានរបស់បុត្រធីតា មហាជនទូទៅ សព្វទីទាំងពួង។

សង្គហវត្ថុ ៤ប្រការនេះ សង្គហណា គួរដល់បុគ្គលណា ក្នុងវេលាណា បើបុគ្គលបានលៃលកធ្វើឲ្យសមហើយ រមែងចំរើនដោយបរិវារសម្បត្តិដល់ការណ៍នោះៗ មានរឿងក្នុងជាតកថា សម័យមួយ ក្នុងវេលាដែលព្រះមានព្រះភាគ ទ្រង់គង់នៅនា ក្រុងអាឡវី ហត្ថកឧបាសកចូលទៅគាល់ មានពួកឧបាសកតាមទៅដោយច្រើន ព្រះមានព្រះភាគត្រាស់សួរថា "ម្នាលហត្ថកៈ បរិវាររបស់អ្នក មានចំនួនច្រើន អ្នកសង្គ្រោះ យិតយោងចិត្តរបស់គេ បានដោយឧបាយយ៉ាងណា?" ហត្ថកៈឧបាសក ក្រាបទូលថា "បពិត្រព្រះមានជោគ ខ្ញុំព្រះអង្គ សង្គ្រោះពួកបរិស័ទនេះ ដោយសង្គហវត្ថុ ៤ប្រការ ដែលព្រះអង្គត្រាស់ប្រទានប្រៀនប្រដៅទុក ខ្ញុំព្រះអង្គឃើញថា អ្នកណាគួរបានទទួលសង្គ្រោះ ដោយអាការៈដូចម្ដេច ក៏សង្គ្រោះអ្នកនោះបានដោយអាការៈដូច្នោះ ខ្ញុំព្រះអង្គ សង្គ្រោះគេដោយការអោយវត្ថុសម្រាប់ទំនុកបម្រុងខ្លះ ដោយនិយាយស្ដី យកចិត្តគេខ្លះ ដោយប្រព្រឹត្តិ ប្រយោជន៍ដល់គេខ្លះ ដោយប្រព្រឹត្តិ ស្មោះស្មើ ក្នុងផ្លូវរក្សាសាមគ្គីខ្លះ"។

ព្រះមានព្រះភាគទ្រង់ប្រទានសាធុការថា ធ្វើយ៉ាងនេះប្រពៃហើយ ត្រូវហើយ ហើយត្រាស់សរសើរថា ម្នាលហត្ថកៈ អ្នកកើតមកដើម្បីសង្គ្រោះបរិស័ទច្រើនពិតប្រាកដក្នុងអតីតកាល បុរសណាបានគៀរគរបរិស័ទទុក ឲ្យបានច្រើន បុរសនោះ ក៏សុទ្ធតែបានធ្វើ

សម្រេចដោយសង្គហវត្ថុ៤ប្រការនេះដែរបើទុកជាក្នុងអនាគតកាល ក៏គង់មានដូចគ្នា សូម្បីក្នុងបច្ចុប្បន្ននេះ ក៏មានយ៉ាងនេះដែរ។

កាលដែល ហត្ថកឧបាសក ត្រឡប់មកវិញហើយ ព្រះអង្គ ត្រាស់សរសើរចំពោះភិក្ខុទាំងឡាយថា ហត្ថកឧបាសក ជាបុគ្គល អស្ចារ្យប្លែក ចូរអោយលោកទាំងឡាយចាំទុកចុះ។ នេះសំដែងឲ្យ ឃើញថា បណ្ឌិតអ្នកប្រកបដោយសង្គហវត្ថុ រមែងជាទីសរសើរនៃ វិញ្ញូជនដទៃ ហើយបាននូវគុណសម្បត្តិជាធំ មានគេគោរពរាប់អាន ទូទៅឥតអាក់ ត្រូវតាមន័យសុភាសិត ដែលបានសំដែងហើយ ពី ខាងដើមនោះឯង។

ព្រះគ្រូញាណសត្ថា ប៉ែន សុខ

# ៨. បដិច្ចសមុប្បាទសង្ខេប

## នមត្ថុ រតនត្តយស្ស!

សូមលោកអ្នកអានពិចារណាជាមួយនឹងខ្ញុំ អំពីបដិច្ចសមុប្បាទធម៌ ក្នុងទីនេះ!

បដិច្ចសមុប្បាទធម៌ យើងចេះស្ទើរគ្រប់គ្នា តែងបានសូត្របានស្ដាប់ ក្នុងវេលានិមន្តព្រះសង្ឃ ស្វាធ្យាយបង្សុកូល ឧទ្ទិសផលជូនបុព្វការីបុគ្គលជាច្រើនគ្រាមកហើយ។

តាមរបៀបប្រយោគបាលីនៃធម៌នេះ ហាក់ដូចជាពាក្យកម្រងកែវ ដែលព្រះសម្ពុទ្ធបរមគ្រូទ្រង់ចងឡើង ដើម្បីឲ្យគ្រាន់តែស្រណុកចាំ ស្រណុកសូត្រ ស្រណុកស្ដាប់ប៉ុណ្ណោះ ប៉ុន្តែបើពិចារណាឲ្យហ្មត់ចត់នោះ ហាក់ដូចមិនងាយនឹងចាក់ធ្លុះបាន។

ពាក្យថាបដិច្ចសមុប្បាទ បើប្រែយកសេចក្ដីថា ហេតុដើម ឬថា អាស្រ័យហេតុនេះនោះក៏កើតមានឡើងក៏បាន ឬក៏ថា ហេតុនេះមាន ព្រោះអាស្រ័យដំណើរនោះ ដូច្នេះ ក៏បាន។

ធម្មជាតិក្នុងពិភពលោក សុទ្ធតែនៅក្នុងអំណាចនៃច្បាប់ធម៌បដិច្ចសមុប្បាទទាំងអស់។សូមលើកយកឧទាហរណ៍១មកពិចារណា:

ខ្ញុំបានផ្លែដូងទុំ១ យកមកបណ្ដុះដាំ ។ ១០ឆ្នាំក្រោយមក ផ្លែដូងទុំនោះ ក៏ក្លាយទៅជាដូងមួយដើមយ៉ាងខ្ពស់ មានធាងត្រសាយត្រសុំសាខា មានផ្លែជាច្រើនធ្លាយ។ ក្មេងម្នាក់ត្រូវការចង់បានផ្លែដូងនោះក៏ឡើងទៅបេះ ប៉ុន្តែដោយវាមិនប្រសប់ទាំងដោយធ្វេសប្រហែសក្មេងក៏ធ្លាក់ពីចុងដូងនោះមក ហើយមានរបួសយ៉ាងដំណំ។

យើងពិចារណាទៅឃើញថា ដើមដូងដ៏ខ្ពស់នេះ កើតមកពី

ផ្លែដូងទុំមួយ ក្មេងធ្លាក់ព្រោះឡើងមិនប្រយ័ត្ន ហើយក្មេងនោះមានរបួសយ៉ាងដំណំ ព្រោះអាស្រ័យការធ្លាក់។

ដូច្នេះ ប្រសិនបើខ្ញុំមិនបានផ្លែដូងទុំមក ខ្ញុំក៏ពុំបានបណ្ដុះដាំដើមដូងក៏មិនដុះឡើង ទាំងផ្លែដូងថ្មីក៏គ្មាន ក្មេងខ្ញុំក៏មិនត្រូវការឡើងមិនបានធ្លាក់ ហើយវាមិនមានរបួសដែរ។

តាមឧទាហរណ៍ខាងលើនេះ ឃើញថា ក្មេងមានគ្រោះថ្នាក់ព្រោះអាស្រ័យដំណើរ និងបុព្វហេតុ ដែលកើតមាន ជាតំណខាងដើមមក។ របស់ទាំងអស់ក្នុងលោកនេះសុទ្ធតែអាចយកមកពន្យល់បានតាមលំអាននៃហេតុនិងផលយ៉ាងនេះជាដរាប។ ក្នុងលោកនេះគ្មានដំណើរណាមួយដែលអាចកើតឡើងបានដោយមិនបាច់អាស្រ័យហេតុរបស់ខ្លួន ពីខាងដើមមកទេ ។ របស់អ្វីក៏ដោយ បើគ្មានដើមកំណើតជាតំណ ពីខាងដើមហើយ ក៏មិនអាចកើតឡើងបាន ទាំងមិនអាចបណ្ដាលទៅជារបស់អ្វីមួយទៀតបានទេ។

អាស្រ័យហេតុនេះហើយ ទើបមានតំណ រកទីបំផុតគ្មាន។ យើងអាចស្រាវជ្រាវរកហេតុដើមបំផុត នៃរបស់គ្រប់យ៉ាងបានទាំងអស់ ហើយរបស់ទាំងនោះ អាចបន្តទៅជានេះ ជានោះ កើតឡើងដោយអាស្រ័យនឹងខ្លួនបាន។

វិទ្យាសាស្ត្រគ្រប់យ៉ាង គ្រាន់តែជាដំណើរ នៃហេតុការណ៍ដែលកើតមានបន្តៗគ្នាប៉ុណ្ណោះ ឈើលូតលាស់បានល្អ អាស្រ័យនឹងជីជាតិដែលត្រូវទំនង ដីមានជីជាតិអាស្រ័យនឹងវត្ថុនេះ វត្ថុនោះផ្សំគ្នា យ៉ាងនេះដរាបតទៅ។

ចលនានៃគ្រឿងចក្រ ដូចម៉ាស៊ីនកប៉ាល់ជាដើម ប្រព្រឹត្តទៅ

បានអាស្រ័យចំហាយទឹកហើយចំហាយទឹកកើតមកពីទឹកនិងភ្លៀង។

ដោយហេតុនេះ សូម្បីរបស់តូចមួយក្នុងលោក ក៏យើងអាចស្រាវជ្រាវ រាវរកហេតុផលទៅវិញទៅមកបាន ។ របស់មួយបង្កើតរបស់មួយឡើងបន្តៗគ្នា ឥតឈប់ឥតស្រាក ដូចជារលកទឹកមួយបង្កើតរលកទឹកមួយហើយមួយទៀតយ៉ាងនោះឯង។

ក្នុងទីនេះ យើងត្រូវរាវរកឲ្យដឹងហេតុដំបូងបំផុត ទាំងឲ្យដឹងថា តំណហេតុផលនេះចុះចប់ត្រង់ទីណា?

តាមដោយពិត អ្នកវិទ្យាសាស្រ្ត មិនសូវរវល់នឹងរកឲ្យឃើញហេតុដំបូងបំផុត និងចុងបំផុតទេ ។ ប្រាជ្ញារបស់យើង អាចចាក់ធ្លុះបានតែតាមទំនង នៃដំណើរប៉ិនប្រសប់ និងសេចក្តីព្យាយាមរបស់យើងប៉ុណ្ណោះ។ កាលបើប្រាជ្ញាខាងវិទ្យាសាស្រ្តបិទផ្លូវយើងយ៉ាងនេះ យើងក៏តោងរត់ទៅរក ជំនឿផ្តេសផ្តាសទៅវិញ ដូចជាអ្នកខ្លះដែលមិនគួររកឃើញថា មនុស្សកើតមានហេតុយ៉ាងណាៗ ក៏សន្មតថា មានព្រះអាទិទេព ព្រះឥសូរជាអ្នកបង្កើតមនុស្សលោកទៅវិញ។ ជំនឿបែបនេះបិទផ្លូវចំរើនខាងប្រាជ្ញារបស់យើងយ៉ាងជិតស្លុង ព្រោះយើងមិនអាចដេញដោលអោយឃើញថានរណាបង្កើតព្រះអាទិទេព និងព្រះឥសូរ ឬព្រះអាទិទេព និងព្រះឥសូរកើតឡើងអាស្រ័យនឹងអ្វីទេ។ ដំណើរប្រាជ្ញារបស់យើង ត្រូវខ្ទប់ជាប់ត្រឹមនេះឯង។

អ្នកប្រាជ្ញ យល់ដោយភ័ន្តច្រឡំថា ហេតុ និងផលនេះ ជាព្រឹត្តិការណ៍ផ្សេង ដាច់ដោយឡែកពីគ្នា ព្រឹត្តិការណ៍១ ជាអ្នកបង្កើតព្រឹត្តិការណ៍១ឡើង។ ប៉ុន្តែបើពិនិត្យដោយហ្មត់ចត់ទៅតាមលំអានបដិច្ចសមុប្បាទធម៌ ឃើញថា មិនអាចនឹងសន្និដ្ឋានថា ព្រឹត្តិការណ៍

ពីរយ៉ាងនោះ ដាច់ស្រឡះពីគ្នាបានទេ ព្រោះវាដូចកូនច្រវ៉ាក់ដែលថ្កក់ជាប់តៗគ្នា ពីកងមួយទៅកងមួយ នឹងញែកឲ្យដាច់ស្រឡះពីគ្នាពុំបានឡើយ ។ ក្នុងពិភពលោកនេះ ពុំមានព្រឹត្តិការណ៍ណាមួយដែលកើតឡើងដាច់តែឯងបានឡើយ ដូច្នោះ ហេតុ និងបច្ច័យក៏មិនត្រូវសន្និដ្ឋានថា កើតឡើងដាច់ៗតែឯងបានដែរ។

ដីឥដ្ឋ ជាហេតុឲ្យកើត កុម្ភ័ណ្ឌក៏ពិតមែន ប៉ុន្តែដីឥដ្ឋតែម្យ៉ាងប៉ុណ្ណោះនោះ មិនល្មមគ្រាន់នឹងបង្កើតជាក្អម ឬឆ្នាំងបានទេ ។ បើគ្មានទឹក គ្មានពុម្ព គ្មានស្មូនឆ្នាំង ទាំងគ្មានឆន្ទៈរបស់ស្មូនឆ្នាំផងនោះឆ្នាំង ក៏មិនអាចកើតឡើងបានឡើយ។ លក្ខណៈទាំងអស់នេះ សុទ្ធតែជាការខានមិនបានដើម្បីឲ្យកើតជាឆ្នាំង។ ប្រសិនបើខ្វះលក្ខណៈសូម្បីតែមួយ ឆ្នាំងនឹងមិនអាចកើតឡើងបាន។ ដោយហេតុនេះ តើយើងនឹងអាចពោលដោយត្រឹមត្រូវថា ដីឥដ្ឋជាហេតុឲ្យកើតឆ្នាំងដូចម្តេចកើត? តាមដោយពិតនោះ យើងគ្រាន់តែជ្រើសរើសយករបស់មួយលើកឡើង ឲ្យឈ្មោះថា ជាហេតុប៉ុណ្ណោះឯង។ ដីឥដ្ឋតែម្យ៉ាងពិតជាមិនមែនហេតុ ឲ្យកើតឆ្នាំងទេ ។ បើនឹងនិយាយ ឲ្យសមទំនងនោះ គប្បីថា "ឆ្នាំងកើតឡើង ដោយអាស្រ័យនឹងដីឥដ្ឋ" ទើបត្រឹមត្រូវតាមច្បាប់បដិច្ចសមុប្បាទ។

ព្រះសម្ពុទ្ធបរមគ្រូ ទ្រង់ពិចារណារកហេតុនៃព្យាធិ និងមរណៈ។ ព្រះអង្គពុំព្រមជឿតាមលទ្ធិផ្សេងៗក្នុងសម័យនោះ ដែលអាងថា សេចក្តីទុក្ខរបស់យើងរាល់គ្នា កើតមានឡើងព្រោះព្រះអាទិទេព ឬព្រះឥស្វរ ផ្តន្ទាទោសដល់យើងឡើយ ព្រោះមានទំនងខាងផ្លូវវិទ្យាសាស្ត្រ ក្នុងការរាវរកនេះដែរ ។ ព្រះបរមគ្រូ ទ្រង់ល្បង

តាមលំអាន នៃសេចក្តីទុក្ខ របស់សត្វលោក ដោយការស្រាវជ្រាវតាមគន្លងបដិច្ចសមុប្បាទ។ នៅពេលដែលទ្រង់ទើបបានត្រាស់ដឹងជាដំបូង គង់ដោយព្រះភ្នែនតែមួយ សោយវិមុត្តិសុខ (គឺសុខក្នុងផលសមាបត្តិ) ក្នុងរយៈកាល៧ថ្ងៃ ក្រោមម្លប់ព្រះមហាពោធិព្រឹក្សក្បែរនេរញ្ជរាក្នុងឧរុវេលាដែលឥឡូវនេះអ្នកឥណ្ឌាសន្មតហៅទីនោះថា ពុទ្ធគយា ព្រះអង្គទ្រង់រំពឹងឃើញច្បាស់ នូវបដិច្ចសមុប្បាទធម៌ដោយន័យថា៖

មរណៈ ព្យាធិជាដើមកើតមកពីអ្វី? សេចក្តីទុក្ខសោកកើតមានអាស្រ័យហេតុអ្វី? មានអ្វីជាបុព្វហេតុផ្ទាល់នៃសេចក្តីទុក្ខទាំងនេះ?

ឱ! ទុក្ខទាំងនេះកើតមានអាស្រ័យនឹងជាតិទេតើ ព្រោះយើងមានទុក្ខគ្រប់យ៉ាង ក្នុងពេលក្រោយដែលយើងបានកើតមក។

## យើងមានជាតិដោយអាស្រ័យហេតុអ្វី?

ជាតិ អាស្រ័យនឹងភព ។ គ្មានអ្វី ដែលមិនមកពីអ្វី នោះទេ ។ របស់មួយ តែងបណ្តាលមកពីរបស់មួយ ជាដរាប ព្រោះហេតុនេះ ប្រសិនបើគ្មានភពពីមុនមកទេ កំណើតជាមនុស្សក៏មិនអាចកើតមានដែរ។ មនុស្សភាព កើតឡើងឯងៗពុំបានទេ។ គួរជឿជាក់ថា មានភពពីមុនបែបណាមួយដោយពិត។

ក្នុងភាវៈជាមនុស្សនេះ មានលោភៈ ទោសៈ មោហៈ សេចក្តីសង្ឃឹម ការបានសម្រេច និងការថ្លោះធ្លោយជាដើម ។ ហេតុទាំងនោះ មិនមែនទើបនឹងមានមក ជាមួយនឹងកំណើតយើងនេះទេ គឺមានដើម មកអំពីភពណាមួយ ក្នុងកាលមុនជាប្រាកដ ។ ជីវិតរបស់

យើងសព្វថ្ងៃនេះ មិនមែនជាចរន្តថ្មីទេ គឺជាតំណាអំពីជីវិតដែលធ្លាប់មានក្នុងកាលមុនមកហើយ។

## ភពមាន ព្រោះអាស្រ័យអ្វី?

ភពមាន ព្រោះអាស្រ័យឧបាទាន ។ ជីវិតរបស់យើង ជាខ្សែច្រវ៉ាក់នៃសេចក្តីប្រកាន់ ពេញចិត្តខ្ជាប់ ដើម្បីឲ្យបាន នូវរបស់ដែលយើងត្រូវការ ដែលយើងស្វែងរក ទាំងដើម្បីឲ្យបានប្រកប សេចក្តីសុខស្រួលក្នុងពិភពលោកផងទៀត។ ឥរិយាបថទាំងបួន គឺ ការដើរ ឈរ អង្គុយ ដេក និងការបរិភោគ ផឹក ដោយហោចទៅ សូម្បីតែការកំរើកអវយវៈ បន្តិចបន្តួចនេះ សុទ្ធតែជាចំណី នៃឧបាទានទាំងអស់ បើទុកជាដូចម្តេច ក៏មានយ៉ាងទន់ខ្សោយដែរ ។ គឺដោយឧបាទានរបស់យើង និងការខំប្រឹងដើម្បីបំប៉នឧបាទានទាំងនេះហើយ ដែលភព គឺភាវៈជាសត្វលោក (ភាវៈរស់នៅ) របស់យើងអាស្រ័យ ហើយតាំងនៅបាន។

## ឧបាទានមាន ព្រោះអាស្រ័យអ្វី?

សេចក្តីប្រកាន់ពេញចិត្តខ្ជាប់ កើតមានឡើងព្រោះអាស្រ័យសេចក្តីប្រាថ្នា (គឺតណ្ហា) ។ ប្រសិនបើ ពុំមានសេចក្តីប្រាថ្នា ពុំមានចំណង់ទេ ធ្វើម្តេចនឹងមានសេចក្តីប្រកាន់ខ្ជាប់កើត?

បុរសដែលមានបំណង ចង់ឲ្យខ្លួនបានទៅជា ជយគ្គាហកបុគ្គល (អ្នកបានសម្រេចជ័យជំនះ) ក៏តែងមានចិត្តប្រកាន់ខ្ជាប់ នឹងគោលបំណងនោះ ហើយខំប្រឹង ខំតតាំង ប្រណាំងប្រជែង ដើម្បីឲ្យ

បានសម្រេចសមតាមបំណង។ ឧបាទានមានតណ្ហាជាគ្រឿងអាស្រ័យ

## តណ្ហាមានអ្វីជាបច្ច័យ?

តណ្ហា មានការទទួលអារម្មណ៍ ជាបច្ច័យ គឺកាលបើយើងបានទទួលអារម្មណ៍ជាទីគាប់ចិត្តហើយ យើងក៏ប៉ុនប៉ង ចង់រីករាយសប្បាយក្នុងការទទួលអារម្មណ៍នោះៗ។ ដោដ្ឋព្វារម្មណ៍ដ៏ល្អកល្អិនទន់ល្មើយ ឬរូបារម្មណ៍ជាទីគាប់ភ្នែក តែងបណ្តាលឲ្យមានតម្រេក (តណ្ហា) ដុះដាលឡើង។ ព្រោះហេតុនោះ ទើបលោកពោលថា តណ្ហាមានវេទនាជាបច្ច័យ។

## វេទនាមានអ្វីជាបច្ច័យ?

វេទនាមានការប៉ះពាល់ត្រូវ គឺផស្សៈជាបច្ច័យ។ សញ្ញារបស់យើង បានភពប្រសប់នឹងរបស់ខាងក្រៅពេលណា យើងក៏មានការទទួលអារម្មណ៍ពេលនោះ ព្រោះហេតុដូច្នោះ ទើបឃើញថា វេទនាមានផស្សៈជាបច្ច័យ។

## ផស្សៈមានអ្វីជាបច្ច័យ?

ការប៉ះពាល់ត្រូវ មានអាយតនៈខាងក្នុងទាំង៦ នឹងអារម្មណ៍ដែលទាក់ទងដោយអាយតនៈនោះៗជាបច្ច័យ។ ប្រសិនបើយើងពុំមានចក្ខុទាំងពីរទេ យើងក៏ពុំមានរូបភាពនឹងគយគន់មើលដែរ។ បើយ៉ាងនេះ តើម្តេចផស្សៈនឹងកើតមានបាន?ឃើញថាផស្សៈកើតមានព្រោះអាស្រ័យអាយតនៈខាងក្នុង និងអារម្មណ៍ខាងក្រៅ។

### អាយតនៈទាំងប្រាំមួយមានអ្វីជាបច្ច័យ?

អាយតនៈ ទាំង៦ កើតមាន ព្រោះអាស្រ័យ នាម និងរូប ។ អាយតនៈទាំង៦នេះជានាមឥតរូបរាងខ្លះ មានរូបរាងខ្លះ ទាំងអារម្មណ៍ ដែលជាគូនឹងអាយតនៈទាំង៦នេះ ក៏គ្រាន់តែជានាម ឥតរូបរាងខ្លះ មានរូបរាងខ្លះ ដូចគ្នា។ នាម និងរូបទាំងពីរយ៉ាងនេះ ជាបច្ច័យរបស់ អាយតនៈទាំងប្រាំមួយ។

### នាមនិងរូប មានអ្វីជាបច្ច័យ?

នាមនិងរូបមានវិញ្ញាណជាបច្ច័យ។ បើយើងពុំមានវិញ្ញាណ កំណត់សម្គាល់វត្ថុនោះៗទេ នាមក៏ពុំបានសេចក្ដីថាដូចម្ដេចឡើយ ជារបស់ទទេសុទ្ធសាធ។ នាម គឺឈ្មោះមនុស្សណាម្នាក់ មិនបាន សេចក្ដីដល់យើងថាដូចម្ដេចឡើយ ប្រសិនបើយើងមិនដឹងថាមនុស្ស នោះជាអ្វី អ្វីជាមនុស្សនោះ និងអាការៈពិសេសផ្សេងៗយ៉ាងណា។ ទាំងរូបសោត ក៏ឥតបានការណ៍ថាដូចម្ដេចដែរ ប្រសិនបើយើង ពុំ មានវិញ្ញាណកំណត់សម្គាល់ចំពោះរបស់នោះ។ រូបរាងផ្លែឈើដែល យើងមិនធ្លាប់បានឃើញ មិនធ្លាប់បានលិឍរភ្លក្សសោះនោះ រមែង មិនប្រាកដ ដល់យើងសោះឡើយ។ ព្រោះហេតុនោះ ទើបថានាម និងរូប មានវិញ្ញាណជាបច្ច័យ។

### វិញ្ញាណមានអ្វីជាបច្ច័យ?

វិញ្ញាណកើតឡើង ព្រោះអាស្រ័យ ការរួបរួមបង្កើតគំនិត (សង្ខារ)។ ខ្ញុំចាំបានថា ខ្ញុំមានសេកមួយឈ្មោះ ចិត្រពណ៌ រឿងនេះ ដូចម្ដេច? គឺបើខ្ញុំនឹកឡើងកាលណា ខ្ញុំក៏មានគំនិតផ្សេងៗចំពោះវា

ថា វាជាសេកសោម នៅនឹងស្លាបវាមានសម្បុរបៃតង ចំពុះវាក្រហម វាតែងស្រែក តែងនិយាយយ៉ាងនេះ។ល។ កាលបើខ្ញុំលះបង់គំនិតទាំងនេះមួយម្តងៗចេញហើយ ខ្ញុំក៏លែងនឹកនាដល់ចិត្រពណ៌ទាល់តែសោះ។ រឿងនេះ សអោយឃើញថា វិញ្ញាណមាននៅក្នុងការរួមគំនិត ហើយមានការរួបរួមគំនិតសង្ខារទាំងនេះឯងជាបច្ច័យ។

## សង្ខារមានអ្វីជាបច្ច័យ?

សង្ខារគឺការបង្កើតគំនិតផ្តេសផ្តាសនេះ មានសេចក្តីល្ងង់ខ្លៅ គឺអវិជ្ជាជាបច្ច័យ។ សេចក្តីល្ងង់ខ្លៅនេះ គឺការសម្គាល់របស់ទាំងពួងថា ទៀងទាត់ ឥតប្រែប្រួល ។ បើតាមដោយពិតខាងផ្លូវព្រះអភិធម្ម ក្នុងរយៈកាលពីរដែលជាប់បន្តគ្នា ពុំមានវត្ថុអ្វីមួយ ដែលអាចឋិតនៅដដែលទេ។ របស់គ្រប់យ៉ាង សុទ្ធតែមានការល្ងួតលាស់ ចំរើនតាមទំនងខ្លួនទាំងអស់។

គំនិតរបស់ខ្ញុំទាំងប៉ុន្មាន ដែលកើតមានឡើងចំពោះរូប ចិត្រពណ៌សេកខ្ញុំ គឺមកពីខ្ញុំ បានរួបរួមជាមួយនឹងរូបវា ទាំងអស់ ។ ប៉ុន្តែតាមដោយពិត វាពុំមែនជាសេកដដែល ដូចកាលខ្ញុំ ទើបនឹងបានវាមកចិញ្ចឹមទេ។ ចុះព្រោះហេតុអ្វី បានជាខ្ញុំមកផ្តុំគំនិតទៅលើរូបវាថាជាសេកដដែលទៅវិញ។ការរួបរួមគំនិតគឺសង្ខារនេះកើតមាន ព្រោះអាស្រ័យសេចក្តីងងឹត ល្ងង់ខ្លៅ ពោលគឺមានអវិជ្ជា ជាបច្ច័យដោយពិត ព្រោះគ្មានអ្វីទៀងទាត់ឋិតថេរសោះឡើយ។

របស់ទាំងអស់ក្នុងពិភពលោកនេះ មិនអាចតាំងនៅ ឋិតថេរចីរកាលបានទេ ប្រព្រឹត្តទៅបានត្រឹមតែមួយពេលមួយខណៈប៉ុណ្ណោះ

ឯង។ លោកណាជ្រាបច្បាស់យ៉ាងនេះរមែងបានសម្រេចនូវញេយ្យញាណដ៏ឧត្តម លែងយល់ថារបស់ណាមួយ អាចឋិតថេរនៅដដែលដូចពីកាលមុននោះឡើយ ។ លោកលែងលុះ ក្នុងអំណាច សេចក្ដីល្ងង់ខ្លៅ ដែលបង្កបង្កើតគំនិតខុស គឺសង្ខារ តទៅទៀតដោយពិត។

កាលបើសង្ខារមិនមាន វិញ្ញាណក៏មិនមានដែរ។
កាលបើវិញ្ញាណមិនមាន នាមនិងរូបក៏មិនមានដែរ។
កាលបើនាមនិងរូបមិនមាន អាយតនៈទាំង៦ក៏មិនមានដែរ។
កាលបើអាយតនៈទាំង៦មិនមាន ផស្សៈក៏មិនមានដែរ។
កាលបើផស្សៈមិនមាន វេទនាក៏មិនមានដែរ។
កាលបើវេទនាមិនមាន តណ្ហាក៏មិនមានដែរ។
កាលបើតណ្ហាមិនមាន ឧបាទានក៏មិនមានដែរ។
កាលបើឧបាទានមិនមាន ភពក៏មិនមានដែរ។
កាលបើភពមិនមាន ជាតិក៏មិនមានដែរ។
កាលបើជាតិមិនមាន សេចក្ដីចាស់ ស្លាប់ សោក ខ្សឹកខ្សួល លំបាកកាយ លំបាកចិត្ត ចង្អៀតចង្អល់ចិត្តទាំងប៉ុន្មាន ក៏សឹងតែរលត់ទៅទាំងអស់។កងទុក្ខទាំងអស់នេះរលត់ទៅយ៉ាងនេះឯង។

ព្រះមានព្រះភាគ ទ្រង់បានជ្រាបច្បាស់យ៉ាងនេះហើយ ទើបបន្លឺឧទានគាថា ក្នុងវេលានោះ យ៉ាងនេះថា៖

យទា ហវេ បាតុភវន្តិ ធម្មា
អាតាបិនោ ឈាយតោ ព្រាហ្មណស្ស
អថស្ស កង្ខា វបយន្តិ សព្វា
យតោ បជានាតិ សហេតុធម្មំ។

យទា ហវេ បាតុភវន្តិ ធម្មា ។ល។
យតោ ខយំ បច្ចយានំ អវេទិ។
យទា ហវេ បាតុភវន្តិ ធម្មា ។ល។
វិធូបយំ តិដ្ឋតិ មារសេនំ
សុរិយោវ ឱភាសយមន្តលិក្ខេ។

ធម៌ទាំងឡាយ រមែងប្រាកដ ដល់ខីណាសវព្រាហ្មណ៍ អ្នកមានព្យាយាមញុំាងកិលេសឲ្យក្ដៅ អ្នកដុតបង់បាននូវកិលេសកាលណា សេចក្ដីសង្ស័យទាំងឡាយទាំងពួង របស់ខីណាសវព្រាហ្មណ៍នោះ ក៏សឹងតែរម្ងាប់អស់ទៅក្នុងកាលនោះ ព្រោះថា ខីណាសវព្រាហ្មណ៍នោះបានដឹងច្បាស់នូវធម៌ព្រមទាំងហេតុ ព្រោះថា ខីណាសវព្រាហ្មណ៍នោះ បានដឹងច្បាស់ នូវព្រះនិព្វាន ជាទីអស់ទៅ នៃបច្ច័យ ខីណាសវព្រាហ្មណ៍នោះ រមែងកំចាត់បង់នូវមារព្រមទាំងសេនាមារ ហើយស្ថិតនៅ បីដូចព្រះអាទិត្យរះឡើង ធ្វើអាកាសឲ្យរុងរឿងដោយរស្មីរបស់ខ្លួន កំចាត់នូវងងឹត ស្ថិតនៅដូច្នោះឯង។

ក្នុងពេលដែលព្រះអង្គ បានត្រាស់ដឹងហើយភ្លាមនេះ ទ្រង់បានបន្លឺនូវព្រះឧទានវាចា ដែលហៅថា បឋមពុទ្ធវចនៈ បន្ទុះបង្អាប់តណ្ហាថា៖

អនេកជាតិ សំសារំ សន្ធាវិស្សំ អនិព្វិសំ
គហការំ គវេសន្តោ ទុក្ខា ជាតិ បុនប្បុនំ
គហការក ទិដ្ឋោសិ បុន គេហំ ន កាហសិ
សព្វា តេ ផាសុកា ភគ្គា គហកូដំ វិសង្ខតំ
វិសង្ខារគតំ ចិត្តំ តណ្ហានំ ខយមជ្ឈគា

ប្រែ កាលតថាគតមិនទាន់បានសម្រេចប្រាជ្ញាសព្វញ្ញុតញ្ញាណនៅឡើយ តថាគត ស្វែងរកជាងផ្ទះ (គឺតណ្ហា) មិនទាន់ប្រទះ តថាគត ក៏ត្រាច់រង្គាត់ទៅមក ក្នុងវដ្តសង្សារ អស់ជាតិជាអនេក ការយោនយកក្នុងកំណើតទាំងពួង ក៏ជាទុក្ខរឿយៗឥតស្រាកស្រាន្ត។

នៃជាងផ្ទះ! ឥឡូវ តថាគតឃើញអ្នកឯងហើយ អ្នកឯងនឹងធ្វើផ្ទះគឺអត្តភាពរបស់តថាគត តទៅទៀតមិនបានទេ ព្រោះឆ្អឹងជំនីរទាំងអស់របស់អ្នកឯង (គឺកិលេសដ៏សេសទាំងប៉ុន្មាន) តថាគតបានកាច់បំបាក់ អស់រលីងហើយ គ្មានសល់ទេ ដំបូលផ្ទះ (គឺអវិជ្ជា) តថាគត បានរុះរើចោលអស់ហើយ ចិត្តរបស់តថាគត បានដល់នូវនិព្វាន ប្រាសចាកសង្ខារហើយ តថាគត ដល់នូវសេចក្តី អស់ទៅនៃតណ្ហាទាំងឡាយហើយ!

**ចប់ ដោយសង្ខេប។**

ព្រះគ្រូសង្ឃសត្ថា ប៉ុណ្យ សុម្ភាជ



# ៩. អនាមតធម៌

យម្ហិ សច្ចញ្ច ធម្មោ ច អហឹសា សញ្ញមោ ទមោ
ឯតទរិយា សេវន្តិ ឯតំ លោកេ អនាមតំ។

ធម៌៥យ៉ាងគឺ សច្ចៈ១, ធម្មៈ១, អហឹសា១, សញ្ញមៈ១, ទមៈ១, មានក្នុងបុគ្គលណា អរិយៈទាំងឡាយ តែងសេពគប់ នូវបុគ្គលនុ៎ះ គុណជាតិទាំង៥មានសច្ចៈជាដើមនុ៎ះហៅថាអនាមតធម៌ក្នុងលោក។

ក៏ពាក្យថា អនាមតធម៌ ក្នុងផ្ទៃពុទ្ធភាសិតខាងលើនេះ មានមកក្នុងឧបសាឡ្ហកជាតក ទុកនិបាត សត្ថវគ្គវណ្ណា ប្រែថា "ធម៌មិនស្លាប់"គឺធម៌ដែលមិនចេះស្លាប់ក្នុងលោក ប៉ុន្តែសូមកុំចូលចិត្តថា ធម៌នេះជាផ្នស់សម្រាប់ទល់ ឬជប់ជីវិតរបស់មនុស្សសត្វក្នុងលោក ឲ្យរស់នៅ អស់កប្បកល្បទ្បើយ ព្រោះថា មនុស្ស សត្វទាំងអស់ក្នុងលោក សុទ្ធតែមានជរា ព្យាធិ មរណៈ (ចាស់ ឈឺ ស្លាប់) ជាប់មកជាមួយនឹងកំណើតជាធម្មតា ឯធម៌ដែលមិននៅក្នុងអំណាច ជរា ព្យាធិ មរណៈ នោះឯង ហៅថា អនាមតធម៌ ៥យ៉ាង គឺៈ

១. សច្ចៈ សេចក្តីពិត
២. ធម្មៈ ធម៌
៣. អហឹសា ការមិនបៀតបៀន
៤. សញ្ញមៈ ការសង្រួម
៥. ទមៈ ការទូន្មាន។

**អធិប្បាយ**

១. សច្ចៈ សេចក្តីពិត គឺគុណជាត ដែលមានក្នុងសប្បុរស ឬញាណ (ការដឹង) របស់ពិត ក្នុងចំណែកខាងដើម ដែលមានសច្ចៈ៤

ជាទីតាំង គឺការដឹងថាសេចក្តីទុក្ខ មានជាតិទុក្ខជាដើមដែលជារបស់ពិត ហៅថា ទុក្ខសច្ចៈ១ តណ្ហាមានកាមតណ្ហាជាដើមជាហេតុដែលនាំឲ្យកើតសេចក្តីទុក្ខនោះៗ ជារបស់ពិត ហៅថា សមុទយសច្ចៈ១ សេចក្តីរលត់ទុក្ខ ព្រមទាំងហេតុ ដែលនាំឲ្យកើតសេចក្តីទុក្ខនោះៗ ជារបស់ពិត ហៅថា និរោធសច្ចៈ១ ផ្លូវ ឬឧបាយ ដែលនាំឲ្យរលត់សេចក្តីទុក្ខនោះៗ ជារបស់ពិត ហៅថា មគ្គសច្ចៈ១។ ទាំង៤នេះ ជារបស់មានពិតមិនចេះស្លាប់ក្នុងលោកយ៉ាងនេះទើបឈ្មោះថា អនាមតធម៌ដោយប្រការដូច្នេះឯង។

២. ធម្មៈ ធម៌ បានខាងលោកុត្តរធម៌ គឺធម៌ ដែលឆ្លងចាកលោក (ទាំង៣ កាមលោក, រូបលោក, អរូបលោក) ឬធម៌ដែលឆ្លងចាកឧបាទានក្ខន្ធទាំង៥ មានរូបូបាទានក្ខន្ធជាដើម។ លោកុត្តរធម៌នោះ មាន៩ប្រការ គឺមគ្គ៤ ផល៤ និព្វាន១។ ធម៌មានមគ្គ៤ជាដើមនេះជាធម៌មិនចេះស្លាប់ក្នុងលោក ទើបឈ្មោះថា អនាមតធម៌ដោយប្រការដូច្នេះឯង។

៣. អហឹសា ការមិនបៀតបៀន បានខាងការមិនធ្វើទុក្ខ ធ្វើបាបដល់សត្វដទៃ ក្នុងទីនេះ លោកសំដៅយកមេត្តាចិត្ត គឺចិត្តដែលគិតប្រាថ្នារកសេចក្តីល្អដល់គ្នានឹងគ្នា បើពោលឲ្យងាយ ក៏គឺសេចក្តីប្រាថ្នាឲ្យគេបានសុខនោះឯង។ អហឹសា ការមិនបៀតបៀននេះឯងជាគុណជាតិ នាំអោយកើតសេចក្តីរាប់រកគ្នា មិនអោយមានពៀរដល់គ្នានឹងគ្នា ទាំងអាចតផ្សារសង្គម ឬគ្រួសារនីមួយៗ អោយមានសាមគ្គីស្មោះសររកគ្នា ជាគុណជាតិ មិនចេះស្លាប់ដោយពិត ទើបឈ្មោះថា អនាមតធម៌ដោយប្រការដូច្នេះឯង។

៤. សញ្ញម: ការសង្រួម បានខាងការប្រយ័ត្នរវាំងខ្លួនឲ្យរួច ចាកទោស ដែលបណ្ឌិតគប្បីតិះដៀល។ សញ្ញមៈក្នុងទីនេះ សំដៅយក សីលសំវរ: (ការសង្រួមក្នុងសីល) ការសង្រួមនេះជាគុណជាតិ មិនចេះស្លាប់ក្នុងលោក ទើបឈ្មោះថា អនាមតធម៌ ដោយប្រការដូច្នេះឯង។

៥. ទម: ការទូន្មាន បានខាងការហាត់ពត់ចិត្ត ឬខ្លួនឲ្យរួច ចាកសង្កិលេសធម៌គឺ រាគ: ទោស: មោហ:។ ក្នុងទីនេះសំដៅយក ការទូន្មានឥន្ទ្រិយទាំង៦ មានចក្ខុន្ទ្រិយជាដើម។ ទមៈនេះ ជាគុណធម៌ ធ្វើបុគ្គលអោយមានកាយវាចាចិត្តល្អសមរម្យ គួរជាទីរាប់រកនៃប្រជាជនទូទៅ ទាំងជាគុណធម៌ មិនចេះស្លាប់ក្នុងលោកដោយពិត ហេតុនោះ ទើបឈ្មោះថា អនាមតធម៌ដោយប្រការដូច្នេះឯង។

ធម៌ទាំង៥ប្រការគឺ សច្ច:, ធម្ម:, អហឹសា, សញ្ញម:, ទម: មានបរិបូណ៌នៅក្នុងបុគ្គលណា អរិយៈទាំងឡាយ តែងសេពគប់នូវបុគ្គលនុ៎ះ។ គុណជាតមានសច្ច: ជាដើមនុ៎ះ ឈ្មោះថា អនាមតធម៌ គឺធម៌ មិនចេះចាស់ ឈឺ ស្លាប់ មានន័យ ដូចសេចក្ដីអធិប្បាយមក ដោយសង្ខេបនេះឯង។

**អនាមតធម៌ ចប់។**

ព្រះគ្រូមុនីសោភ័ន សេខ ឆាជ័

# ១០. សតិប្បដ្ឋាន៤យ៉ាង

## នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស។

សូមនមស្ការចំពោះព្រះអរហន្តសម្មាសម្ពុទ្ធ ដ៏មានព្រះភាគ អង្គនោះ (ព្រមទាំងព្រះសទ្ធម្មនិងព្រះអរិយសង្ឃដោយសេចក្ដីគោរព)។

លំដាប់នេះ សូមសំដែង សតិប្បដ្ឋាន ៤យ៉ាង ដែលមានក្នុងគម្ពីរទីឃនីកាយ ត្រង់មហាវគ្គដូចតទៅនេះ៖

សតិប្បដ្ឋាន ប្រែថា ការតាំងនៅនៃស្មារតី ឬជាការដំកល់នូវស្មារតី គឺថា ការឋិតនៅនៃស្មារតី។

**សតិប្បដ្ឋាន ៤ យ៉ាងនោះគឺ**

១ **កាយានុបស្សនាសតិប្បដ្ឋាន** ការតាំងនៅនៃស្មារតី ក្នុងការពិចារណារឿយៗនូវកាយ។

២ **វេទនានុបស្សនាសតិប្បដ្ឋាន** ការតាំងនៅនៃស្មារតី ក្នុងការពិចារណារឿយៗនូវវេទនា។

៣ **ចិត្តានុបស្សនាសតិប្បដ្ឋាន** ការតាំងនៅនៃស្មារតី ក្នុងការពិចារណារឿយៗនូវចិត្ត។

៤ **ធម្មានុបស្សនាសតិប្បដ្ឋាន** ការតាំងនៅនៃស្មារតី ក្នុងការពិចារណារឿយៗនូវធម៌ទាំងឡាយ។

**អធិប្បាយដោយសង្ខេប**

## ១. កាយានុបស្សនាសតិប្បដ្ឋាន

ពាក្យថា ការតាំងនៅនៃស្មារតី ក្នុងការពិចារណារឿយៗ នូវកាយនោះ ដូចសេចក្ដីរៀបរាប់តទៅនេះ៖

កាយក្នុងទីនេះសំដៅយកហេតុច្រើនយ៉ាងគឺខ្យល់អស្សាសៈ

បស្សាសៈ(ខ្យល់ដកដង្ហើមចេញ,ចូល)។ ការប្រុងស្មារតីកំណត់ខ្យល់ដកដង្ហើមចេញ,ចូល អោយដឹងច្បាស់ថា អាត្មាអញរម្ងាប់ នូវកាយសង្ខារ គឺខ្យល់ដកដង្ហើមចេញ,ចូល វែង,ខ្លី ហើយក៏ដកដង្ហើមចេញ, ចូល វែង,ខ្លី ដូច្នេះជាដើម ហៅថា កាយានុបស្សនាសតិប្បដ្ឋាន ឬហៅថា អានាបានស្សតិកម្មដ្ឋាន ដូច្នេះវិញ។

កាយសំដៅយកឥរិយាបថ ការប្រុងស្មារតីកំណត់អោយដឹងច្បាស់ថា អញដើរ ឈរ អង្គុយ ដេក ឬថា ការដំកល់កាយណា គឺឥរិយាបថយ៉ាងអាត្មាណាៗក៏ឲ្យដឹងច្បាស់នូវកាយនោះៗដែរ។ ការកំណត់ដឹងឥរិយាបថដូច្នេះ ហៅថា កាយានុបស្សនាសតិប្បដ្ឋាន។

កាយសំដៅយកកិច្ចទាំងពួង មានដើរឈានទៅមុខ និងដើរឈានថយក្រោយជាដើម។

ការធ្វើសេចក្ដីដឹងខ្លួនច្បាស់លាស់ ក្នុងការដើរឈានទៅមុខ និងឈានថយក្រោយ ឈរ អង្គុយ ដេក និយាយ ស្ងៀម ដូច្នេះជាដើម ហៅថាកាយានុបស្សនាសតិប្បដ្ឋាន។ កាយសំដៅយកអាការៈ ៣២ មានសក់ជាដើម។

សេចក្ដីថា ការពិចារណាកាយតាំងអំពីផ្ទៃជើងឡើងទៅលើ តាំងអំពីចុងសក់ចុះមកក្រោម មានស្បែកស្រោបជុំវិញ ពេញដោយអាការៈមិនស្អាត គួរខ្ពើមរអើមមានប្រការផ្សេងៗ អាការៈដែលមានក្នុងកាយនេះមាន សក់ រោម ក្រចក ធ្មេញ ជាដើម។ ការពិចារណាកាយឲ្យឃើញថា កាយមានអាការៈមិនស្អាត គួរខ្ពើមរអើម ដូច្នេះហៅថា កាយានុបស្សនាសតិប្បដ្ឋាន ឬហៅថា កាយគតាសតិកម្មដ្ឋាន ដូច្នេះវិញក៏បាន។

កាយសំដៅយក ធាតុ សេចក្តីថា ការពិចារណាកាយនេះ គឺគ្រាន់តែកំណត់ដឹងថា ជាធាតុទាំង៤ គឺដី ទឹក ភ្លើង ខ្យល់ ប៉ុណ្ណោះយ៉ាងនេះហៅថា កាយានុបស្សនាសតិប្បដ្ឋាន ឬហៅថា ធាតុវវត្ថានកម្មដ្ឋាន ដូច្នេះវិញក៏បាន។

កាយសំដៅយកអសុភ ដែលគេចោលក្នុងព្រៃស្មសាន មាន៩យ៉ាងគឺះ

១. អសុភកំពុងហើមប៉ោងឡើង

២. អសុភមានសត្វចឹកទំពាស៊ីជាអាហារ

៣. អសុភមានសាច់ឈាមសរសៃជាប់នឹងរាងឆ្អឹង

៤. អសុភមានឈាមសរសៃប្រឡាក់ជាប់នឹងរាងឆ្អឹង

៥. អសុភមានតែសរសៃជាប់ទៅនឹងរាងឆ្អឹង

៦. អសុភនៅតែឆ្អឹងចោលរាត់រាយ

៧. អសុភនៅតែឆ្អឹងមានសម្បុរសដូចស័ង្ខ

៨. អសុភនៅតែឆ្អឹងជាគំនរកន្លងទៅ១ឆ្នាំ

៩. អសុភនៅតែឆ្អឹងពុកផុយជាកំទេចល្អិតៗ។

ការពិចារណាមើលនូវអសុភអោយជាក់ច្បាស់ ហើយប្រៀបធៀបនឹងកាយរបស់ខ្លួនថា ដូចជាអសុភនោះដែរ យ៉ាងនេះ ហៅថាកាយានុបស្សនាសតិប្បដ្ឋាន ឬហៅថាអសុភកម្មដ្ឋានដូច្នេះក៏បាន។

**ចប់កាយានុបស្សនាសតិប្បដ្ឋាន**

## ២. វេទនានុបស្សនាសតិប្បដ្ឋាន

១. សុខវេទនា។ ២. ទុក្ខវេទនា។ ៣. អទុក្ខមសុខវេទនា។

សេចក្តីថា ការពិចារណា ឲ្យដឹងច្បាស់ នូវការទទួលសេចក្តី

សុខ ទុក្ខ មិនទុក្ខមិនសុខ គឺឧបេក្ខា ការពិចារណាឲ្យដឹងច្បាស់ នូវការទទួលសេចក្ដីសុខ ប្រកបដោយអាមិសៈ (សោមនស្សវេទនាអាស្រ័យដោយកាមគុណ ប្រព្រឹត្តទៅក្នុងទ្វារ៦)។ ការពិចារណាឲ្យដឹងច្បាស់នូវការទទួលសេចក្ដីសុខប្រាសចាកអាមិសៈ (សោមនស្សវេទនា អាស្រ័យនូវនេក្ខម្មៈ ប្រព្រឹត្តទៅក្នុងទ្វារ៦)។ ការពិចារណាឲ្យដឹងច្បាស់នូវការទទួលសេចក្ដីទុក្ខប្រកបដោយអាមិសៈ (ទោមនស្សវេទនាអាស្រ័យដោយកាមគុណប្រព្រឹត្តទៅក្នុងទ្វារ៦)។ការពិចារណាឲ្យដឹងច្បាស់នូវការទទួលសេចក្ដីទុក្ខប្រាសចាកអាមិសៈ (ទោមនស្សវេទនាអាស្រ័យដោយនេក្ខម្មៈ ប្រព្រឹត្តទៅក្នុងទ្វារ៦)។ ការពិចារណាឲ្យដឹងច្បាស់ នូវការទទួលវេទនា មិនមែនជាទុក្ខ មិនមែនជាសុខប្រកបដោយអាមិសៈ (ឧបេក្ខាវេទនាអាស្រ័យកាមគុណ៥ ប្រព្រឹត្តទៅក្នុងទ្វារ៦)។ ការពិចារណា អោយដឹងច្បាស់នូវការទទួលវេទនា មិនមែនជាទុក្ខ មិនមែនជាសុខ ប្រាសចាកអាមិសៈ (ឧបេក្ខាវេទនាអាស្រ័យនេក្ខម្មៈ ប្រព្រឹត្តទៅក្នុងទ្វារ៦)។ ការកំណត់ពិចារណា ឲ្យស្គាល់ច្បាស់នូវវេទនាយ៉ាងនេះហៅថាវេទនានុបស្សនាសតិប្បដ្ឋាន។

**ចប់វេទនានុបស្សនាសតិប្បដ្ឋាន។**

## ៣. ចិត្តានុបស្សនាសតិប្បដ្ឋាន

ការតាំងនៅនៃស្មារតីក្នុងការពិចារណារឿយៗនូវចិត្ត។ ពាក្យថា ទីតាំងនៃស្មារតីពិចារណារឿយៗនូវចិត្តនោះ សេចក្ដីថា ការដឹងច្បាស់នូវចិត្តប្រកបដោយ រាគៈ ទោសៈ មោហៈ ទាំងដឹងច្បាស់ថាចិត្តប្រាសចាក រាគៈ ទោសៈ មោហៈ ដឹងច្បាស់ នូវចិត្តរួញរា ចិត្តរាយមាយ ចិត្តដល់នូវសភាពជាធំ (រូបាវចរចិត្ត អរូបាវចរចិត្ត) ចិត្ត

មិនដល់នូវសភាពជាធំ (កាមាវចរចិត្ត ចិត្តជាសឧត្តរៈ នៅមានចិត្តដទៃលើសលប់ជាង)(កាមាវចរចិត្ត) ចិត្តជាអនុត្តរៈ ឥតមានចិត្តដទៃលើសលប់ជាង(រូបាវចរចិត្ត អរូបាវចរចិត្ត) ចិត្តតាំងនៅមាំ (ចិត្តដល់នូវឧបចារសមាធិ អប្បនាសមាធិ) ចិត្តមិនមែនតាំងនៅមាំ ចិត្តរួចស្រឡះ ចិត្តមិនទាន់រួចស្រឡះ។ ត្រង់ពាក្យថា ចិត្តរួចស្រឡះ គឺចិត្តប្រកបដោយវិមុត្តិ២យ៉ាង គឺតទង្គវិមុត្តិ វិក្ខម្ភនវិមុត្តិ។ អនុបស្សនា៧យ៉ាង មានអនិច្ចានុបស្សនា ជាដើម ហៅថា តទង្គវិមុត្ត (ការរួចស្រឡះដោយអង្គឈាននោះ) ព្រមទាំងរួចចាកនិច្ចសញ្ញា គឺសេចក្តីសំគាល់ថាទៀង។ សមាបត្តិ៨ ហៅថា វិក្ខម្ភនវិមុត្តិ (ការរួចស្រឡះដោយការសង្កត់សង្កិន) ព្រមទាំងរួចចាកអកុសលធម៌ មាននីវរណៈជាដើម ។ ការកំណត់ពិចារណា ដឹងច្បាស់នូវចិត្ត ដូច្នេះ ហៅថា ចិត្តានុបស្សនាសតិប្បដ្ឋាន។

**ចប់ ចិត្តានុបស្សនាសតិប្បដ្ឋាន**

## ៤. ធម្មានុបស្សនាសតិប្បដ្ឋាន

ការតាំងនៅ នៃស្មារតី ក្នុងការពិចារណារឿយៗ នូវធម៌ ។ ទីតាំងនៃស្មារតី ពិចារណារឿយៗនូវធម៌នោះ គឺការពិចារណាឲ្យដឹងច្បាស់នូវធម៌៥ពួក គឺនីវរណៈពួក១ ឧបាទានក្ខន្ធពួក១ អាយតនៈពួក១ ពោជ្ឈង្គៈពួក១ អរិយសច្ចពួក១។

**នីវរណៈ មាន៥យ៉ាងគឺ**

១. កាមច្ឆន្ទៈ សេចក្តីប្រាថ្នាស្រឡាញ់ពេញចិត្តក្នុងកាម។
២. ព្យាបាទៈការញ៉ាំងប្រយោជន៍និងសេចក្តីសុខអ្នកដទៃឲ្យវិនាស។
៣. ថីនមិទ្ធៈ ច្រអូសកាយ ចិត្ត គឺសេចក្តីខ្ជិល។

៤. ឧទ្ធច្ចកុក្កុច្ចៈ សេចក្ដីរាយមាយក្ដៅក្រហាយរង្កៀស។
៥. វិចិកិច្ឆា សេចក្ដីសង្ស័យ។

ខន្ធជាកំណើតរបស់ឧបាទាន(ការប្រកាន់)ឬខន្ធដែលប្រព្រឹត្ត ទៅក្នុងភូមិ៣ គឺកាមាវចរភូមិ១ រូបាវចរភូមិ១ អរូបាវចរភូមិ១ ហៅថា ឧបាទានក្ខន្ធ។

**ឧបាទានក្ខន្ធ មាន៥យ៉ាង គឺ**

១. រូបូបាទានក្ខន្ធ, ២. វេទនូបាទានក្ខន្ធ, ៣. សញ្ញូបាទានក្ខន្ធ, ៤. សង្ខារូបាទានក្ខន្ធ, ៥. វិញ្ញាណូបាទានក្ខន្ធ។

**អាយតនៈ**

អាយតនៈប្រែថា(ទីនៅ អណ្ដូង ទីប្រជុំ ទីកើត ជាហេតុ)បើចាត់តាម ទ្វារខាងក្នុងមាន៦យ៉ាង បើចាត់តាមអារម្មណ៍ខាងក្រៅមាន៦យ៉ាង។

អាយតនៈចាត់តាមទ្វារខាងក្នុង ៦យ៉ាងនោះគឺៈ
១. ភ្នែក, ២. ត្រចៀក, ៣. ច្រមុះ, ៤. អណ្ដាត, ៥. កាយ, ៦. ចិត្ត។

អាយតនៈចាត់តាមអារម្មណ៍ខាងក្រៅ ៦យ៉ាងនោះគឺៈ
១. រូប, ២. សំឡេង, ៣. ក្លិន, ៤. រស, ៥. សម្ផស្ស, ៦. ធម៌។ ឯធម៌ នោះ បានខាងចេតសិក៥២ សុខុមរូប ១៦ និព្វាន១ ត្រូវជា៦៩។

**ពោជ្ឈង្គៈ**

ពោជ្ឈង្គៈ ប្រែថា អង្គនៃធម្មជាតគ្រឿងត្រាស់ដឹង មាន៧យ៉ាងគឺៈ

១. សតិសម្ពោជ្ឈង្គៈ, ២. ធម្មវិចយសម្ពោជ្ឈង្គៈ, ៣. វិរិយ សម្ពោជ្ឈង្គៈ, ៤ បីតិសម្ពោជ្ឈង្គៈ, ៥. បស្សទ្ធិសម្ពោជ្ឈង្គៈ, ៦. សមាធិ សម្ពោជ្ឈង្គៈ, ៧. ឧបេក្ខាសម្ពោជ្ឈង្គៈ។

**អរិយសច្ច**

អរិយសច្ច ប្រែថា ធម្មជាតិពិតរបស់អរិយបុគ្គល មាន៤យ៉ាងគឺៈ

១. ទុក្ខអរិយសច្ច ធម្មជាតពិតរបស់អរិយៈ គឺសេចក្តីទុក្ខ។

២. ទុក្ខសមុទយអរិយសច្ច ធម្មជាតពិតរបស់អរិយៈ គឺតណ្ហាជាហេតុនាំឲ្យកើតសេចក្តីទុក្ខ។

៣. ទុក្ខនិរោធអរិយសច្ចធម្មជាតពិតរបស់អរិយៈគឺការរលត់ទុក្ខ

៤. ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច ធម្មជាតពិត របស់អរិយៈ គឺសេចក្តីប្រតិបត្តិញ៉ាំងសត្វឲ្យដល់នូវការរលត់ទុក្ខ។

ការពិចារណា នូវធម៌៥ពួក ដូចបានរៀបរាប់មកខាងលើនេះ អោយបានច្បាស់លាស់ ទុកក្នុងចិត្ត ហើយប្រតិបត្តិតាម យ៉ាងនេះ ហៅថា ធម្មានុបស្សនាសតិប្បដ្ឋាន។

ចប់ ធម្មានុបស្សនាសតិប្បដ្ឋាន។

## អានិសង្សនៃការចំរើនសតិប្បដ្ឋាន

បុគ្គលណាមួយ បានលះបង់ពួក ហើយចេញទៅសម្ងំទៅក្នុងទីដ៏ស្ងប់ស្ងាត់តែម្នាក់ឯង ហើយបានពិចារណា ឲ្យហ្មត់ចត់ ឬបានចំរើននូវសតិប្បដ្ឋានទាំង៤ឲ្យបានច្បាស់លាស់ តាមវិធីដែលបានរៀបរាប់មកហើយនោះ បុគ្គលនោះ រមែងចំរើនប្រាជ្ញាយ៉ាងមុតមាំផង ចំរើនស្មារតីដ៏រឹងប៉ឹងផង លះបង់តណ្ហានិងទិដ្ឋិផង មិនបានប្រកៀកប្រកាន់អ្វីបន្តិចបន្តួចក្នុងលោកផង ស្អាតបរិសុទ្ធខ្លួនផង លះបង់នូវសេចក្តីសោកចោលផង លះបង់នូវសេចក្តីខ្សឹកខ្សួលចោលផង លះបង់នូវទុក្ខ និងទោមនស្សចោលផង ដល់ទីបំផុតបានសម្រេចអរហត្ត ចូលកាន់និព្វានមិនខាន។

ចប់ សតិប្បដ្ឋាន។

ព្រះគ្រូសង្ឃសុមេធ ជន់ វ៉ាន់

# ១១. ធុរៈព្រះពុទ្ធសាសនា២យ៉ាង

មុននឹងអធិប្បាយ អំពីធុរៈព្រះពុទ្ធសាសនានេះ សូមរៀបរាប់អំពីជំនឿរបស់មនុស្ស ដែលមាននៅលើសាសនានីមួយៗ និងកំណើតនៃព្រះពុទ្ធសាសនា ដូចមានសេចក្ដីបរិយាយ ដោយសង្ខេបតទៅនេះ៖

ធម្មតា មនុស្សក្នុងលោក តាមតែសញ្ជាតិណាក៏ដោយ សុទ្ធតែមានជំនឿក្នុងអ្វីមួយ បើមិនច្រើនក៏តិច ដែលខ្លួនយល់ឃើញថាជាវត្ថុដ៏ស័ក្ដិសិទ្ធិ គួរពឹងពាក់ពំនាក់អាស្រ័យ គួរគោរពរាប់អាន ពុំសូវមាននៅទោលតែឯកឯង ឥតទីពឹងឡើយ។ វត្ថុដ៏ស័ក្ដិសិទ្ធិទាំងនោះគេច្រើននិយមយកសាសនា ឬលទ្ធិ ដែលជាបវេណី របស់បុព្វបុរសសម្រាប់ជាតិនីមួយៗតែងប្រព្រឹត្តកាន់ជាប់តៗគ្នាមក ទើបឈ្មោះថាសាសនា។ សាសនានោះមានផ្សេងៗគ្នា តាមមតិរបស់សាស្ដាចារ្យនីមួយៗបង្កើតអោយមានឡើង ដើម្បីនឹងឲ្យបរិស័ទ ចុះចូលជឿស្ដាប់គោរពរាប់អាន ដូចយើងបានឃើញ បានឮមកហើយ ដែលមានក្នុងលោកនេះ។ បណ្ដាសាសនាទាំងអស់ក្នុងលោក មានតែ ព្រះពុទ្ធសាសនាមួយទេ ដែលជាសាសនា មានសារៈសំខាន់ បណ្ដាច់ជាងសាសនាឯទៀតៗទាំងអស់ ព្រោះជាសាសនាអាចធ្វើឲ្យមនុស្សគ្រប់ឋានៈ ជាអ្នកប្រតិបត្តិតាម ឲ្យមានសន្តិភាព មេត្រីភាព និងសេរីភាពទូទៅក្នុងលោកទាំង៣។ មហាបុរសមួយរូប អ្នកមានវិចារណញ្ញាណដ៏ជ្រាលជ្រៅ បានរាវរកឃើញសេចក្ដីប្រតិបត្តិ ដែលមានខ្លឹមសារវិសេស អាចធ្វើមនុស្សសព្វគ្រប់ឋានៈ ឲ្យបានរួចផុតចាកភ្លើងទុក្ខភ្លើងកិលេស ហើយបានប្រកាសផ្សាយទុកដរាបមកដល់សព្វថ្ងៃនេះ ឯមហាបុរសនោះ គឺព្រះសម្មាសម្ពុទ្ធរបស់យើងហ្នឹងឯង។ ការដែល

ព្រះសម្មាសម្ពុទ្ធទ្រង់ស្វែងរកសេចក្ដីប្រតិបត្តិដែលមានខ្លឹមសារនោះ ពុំមែនទើបនឹងស្វែងរកក្នុងជាតិមួយជាទីបំផុតនេះទេ គឺទ្រង់ស្វែងរកអស់កាលជាច្រើនជាតិណាស់ ដូចមានប្រវត្តិដែលអ្នកប្រាជ្ញទាំងឡាយបានចារឹកទុកក្នុងគម្ពីរជាច្រើន មានគម្ពីរបឋមសម្ពោធិជាដើម ដែលមានសេចក្ដីដំណាលថា កាលដែលព្រះសម្ពុទ្ធជាបរមគ្រូរបស់យើង នៅក្នុងឋានៈជាពោធិសត្វ មាននាមថា សុមេធបណ្ឌិត បានបំពេញបារមីធម៌ទាំងឡាយ មានទានបារមីជាដើម អំណើះអំពីនោះមក សូម្បីព្រះអង្គសោយព្រះជាតិជាអ្វី ទោះបីជាតិជាមនុស្សក្ដី ជាតិជាអមនុស្សមានទេវតាជាដើមក្ដី ជាតិជាតិរច្ឆានក្ដី សុទ្ធតែទ្រង់បានបំពេញបារមីធម៌គ្រប់ៗជាតិ ដើម្បីស្វែងរកនូវមោក្ខធម៌តែម្យ៉ាង រហូតដល់បច្ឆិមជាតិ ( ជាតិជាខាងចុងបំផុត ) ដែលមាននាមថា សិទ្ធត្ថកុមារ គម្រប់កាលអស់បួនអសំខេយ្យ មួយសែនកប្ប នៅតែពុំទាន់ជួបប្រទះនឹងខ្លឹមរបស់សេចក្ដីប្រតិបត្តិ គឺមោក្ខធម៌ នៅឡើយ។ លុះព្រះបរមពោធិសត្វ ចេញទ្រង់ព្រះផ្នួស ស្វែងរកសព្វញ្ញុតញ្ញាណ ជាមោក្ខធម៌មិនយូរប៉ុន្មាន ក៏បានឃើញជាក់ច្បាស់នូវសព្វញ្ញុតញ្ញាណនោះ ដែលមានខ្លឹមសារ ដោយប្រាជ្ញាញាណរបស់ព្រះអង្គ ឥតមានទើសទាក់ឬកំបាំង នឹងអ្វីឡើយ ហាក់ដូចជា គេទ្រោលប្រទីបទៅក្នុងទីងងឹត ដែលយើងហៅថា ព្រះអង្គត្រាស់ដឹង ទ្រង់គង់លើរតនបល្ល័ង្ក ក្រោមដើមពោធិព្រឹក្សមាននាមថា ព្រះពុទ្ធ។ តពីនោះមក ព្រះពុទ្ធជាម្ចាស់ទ្រង់ទេសនា ប្រកាសផ្សាយសាសនធម៌ គឺពាក្យប្រៀនប្រដៅដ៏មានខ្លឹមសារ ដែលព្រះអង្គបានត្រាស់ដឹងនោះ ដល់សត្តនិករទូទៅក្នុងត្រៃលោក។

ពុទ្ធសាសនធម៌ ដែលមានសារៈ ដ៏សំខាន់បំផុតនោះ មាន៣ យ៉ាងជាគោលគឺ៖

១. **សព្វបាបស្ស អករណំ** ការមិនធ្វើបាបទាំងពួងដោយ កាយវាចាចិត្ត មានការមិនសំលាប់សត្វដោយខ្លួនឯង ឬប្រើអ្នកដទៃ ឲ្យសម្លាប់ជាដើម គោលធម៌ទី១នេះ សង្គ្រោះចូលក្នុងវិន័យបិដក។

២. **កុសលស្សូបសម្បទា** ការបំពេញកុសលអោយបរិបូណ៌ ដោយកាយ វាចា ចិត្ត មានការអោយទានជាដើម គោលធម៌ទី២នេះ សង្គ្រោះចូលក្នុងសុត្តន្តបិដក។

៣. **សចិត្តបរិយោទបនំ** ការញុំាងចិត្តរបស់ខ្លួនឲ្យផូរផង់ មាន ការជំរះចិត្ត អោយស្អាតបរិសុទ្ធ ចាកអកុសលធម៌ទាំងឡាយ មាន លោភៈ ឬរាគៈ ជាដើម គោលធម៌ ទី៣នេះ សង្គ្រោះចូលក្នុងអភិធម្ម បិដក។ រួមគោលទាំង៣ប្រការនេះ ហៅថា ព្រះពុទ្ធសាសនា។

ធុរៈក្នុង ព្រះពុទ្ធសាសនាមាន២យ៉ាងគឺ គន្ថធុរៈ១ វិបស្សនា ធុរៈ១។ ពុទ្ធវចនៈ គឺធម៌វិន័យរបស់ព្រះសម្មាសម្ពុទ្ធ ទ្រង់បានត្រាស់ ដឹង ហើយទ្រង់សំដែងប្រោស វេនេយ្យសត្វ អស់រយៈកាល ចំនួន ៤៥ វស្សា ក៏ទ្រង់ចូលបរិនិព្វានទៅ ទើបព្រះអរហន្តទាំងឡាយ ជា សង្គីតិកាចារ្យ បានជ្រើសរើស រៀបរៀង នូវពុទ្ធវចនៈទាំងនោះ ដោយសង្កាត់ ដោយក្រុមអោយដឹងថា នេះជាធម៌ នេះជាវិន័យ នេះ ពុទ្ធប្បញ្ញត្តិ នេះជាពុទ្ធានុញ្ញាតទើបចាត់ទៅជាបិដក៣គឺវិន័យបិដក, សុត្តន្តបិដក, អភិធម្មបិដក ចាត់ទៅជា និកាយ៥ គឺ ទីឃនិកាយ, មជ្ឈិមនិកាយ, សំយុត្តនិកាយ, អង្គុត្តរនិកាយ, ខុទ្ទកនិកាយ, ចាត់ ទៅជាអង្គ៩ គឺ សុត្តៈ, គេយ្យៈ, វេយ្យាករណៈ, គាថា, ឧទាន, ឥតិវុត្តកៈ,

ជាតកៈ, អព្ភូតធម្ម, វេទល្លៈ ចាត់ទៅជាធម្មក្ខន្ធ ៨៤.០០០ធម្មក្ខន្ធ។

ការតាំងព្យាយាមដ៏មុតមាំ ខំសិក្សា នូវពុទ្ធវចនៈទាំងនេះតាមកម្លាំងសតិបញ្ញា និងសមត្ថភាពរបស់ខ្លួន បានចេះស្ទាត់គ្រប់បិដកទាំង៣ក្តី ត្រឹមតែបិដក១ក្តី ឬត្រឹមតែនិកាយ១ក្តី ឬក៏ដោយហោចទៅត្រឹមតែពុទ្ធភាសិតបទណាមួយក្តី ហើយអាចបង្ហាត់បង្រៀនគេកើតអាចសំដែងណែនាំពន្យល់គេកើត ហើយមានសេចក្តីប្រតិបត្តិ ត្រឹមត្រង់តាមពុទ្ធវចនៈនោះៗ មិនឲ្យឃ្លៀងឃ្លាតផង ហៅថា គន្ធធុរៈ។

ការសិក្សារៀនសូត្រ ចេះចាំពុទ្ធវចនៈបទណាមួយ ឲ្យស្ទាត់ប្រាកដ ហើយបានប្រព្រឹត្ត ធ្វើខ្លួនឲ្យស្រាល គឺខាងគ្រហស្ថ គួរលះឃរាវាសកិច្ច (ការរវល់ក្នុងផ្ទះ) ចេញតាមពេលដែលគួរលះបាន បើបព្វជិតគួរលះកង្វល់ផ្សេងៗ មានការរវល់ក្នុងអាវាស ឬការគ្រប់គ្រងពួកក្រុមជាដើមចេញ តាមពេលដែលគួរលះបាន ហើយរកទី សេនាសនៈដ៏ស្ងប់ស្ងាត់ លើកអាវុធគឺបញ្ញា ពិចារណាឃើញច្បាស់នូវទោសរបស់សង្ខារធម៌ ទាំងខាងក្នុង ទាំងខាងក្រៅ ដែលជាសភាវៈ នាំឲ្យកើតឡើង ទាំងនាំឲ្យវិនាស សាបសូន្យទៅវិញ ចំពោះអត្តភាពរបស់ខ្លួន ឬចំពោះអត្តភាពរបស់មនុស្ស សត្វដទៃ សុទ្ធតែលុះនៅក្នុងអំណាចត្រៃលក្ខណ៍ដូចគ្នាទាំងអស់ ការនឹករំពឹង ពិចារណារឿយៗដរាបទាល់តែ ចិត្តនឿយណាយ ធុញទ្រាន់ ចំពោះសត្វ និងសង្ខារទាំងអស់ បើឧបនិស្ស័យមានមកពីបុព្វជាតិចាស់ក្លា ជាជំនួយផង ក៏បានលុះនូវគុណធម៌ជាន់ខ្ពស់មានសោតាបត្តិផលជាដើម បើពុំដូច្នោះទេ គង់នឹងបានជាឧបនិស្ស័យ ក្នុងបច្ចុប្បន្ន និងអនាគតជាតិទៀតពុំខាន សេចក្តីពណ៌នាមកដោយសង្ខេបប៉ុណ្ណោះហៅថា វិបស្សនាធុរៈ។

ធុរៈក្នុងព្រះពុទ្ធសាសនា ទាំងពីរយ៉ាងនេះ ត្រូវតែអាស្រ័យគ្នាទៅវិញទៅមក ឬក៏ត្រូវនៅទន្ទឹមគ្នាជានិច្ចនឹងខានពុំបាន ព្រោះថាការសិក្សារៀនសូត្រ ឲ្យបានចេះចាំពុទ្ធវចនៈនេះ ទុកជាមូលដ្ឋាននៃសេចក្ដីប្រតិបត្តិដោយពិត គឺថាមានតែការសិក្សា ឲ្យបានចេះដឹងជាមុនសិន ទុកជាច្បាប់សម្រាប់ពន្យល់ចង្អុលបង្ហាញបំភ្លឺផ្លូវប្រាប់សេចក្ដីប្រតិបត្តិ ឲ្យបានត្រឹមត្រង់ តាមពុទ្ធប្បញ្ញត្តិ និងពុទ្ធានុញ្ញាត ដែលជាហេតុនាំឲ្យបានសុខចំរើនពិតៗ។

ព្រោះហេតុនោះ បានជាអដ្ឋកថាចារ្យ លោកប្រៀបធៀប ជាសេចក្ដីបំភ្លឺ ឲ្យងាយយល់ថា ដូចជាអក្សរ ដែលគេឆ្លាក់ ភ្ជាប់នៅលើផ្ទាំងថ្ម ដើម្បីជាគ្រឿងសំគាល់ឲ្យដឹងនូវទីដែលមានឆ្នាំងកំណាប់ទ្រព្យដែលគេកប់ទុកដរាបណា អក្សរទាំងនោះមិនទាន់រលុបរលាយបាត់ទៅទេ ដរាបនោះ ឆ្នាំងកំណាប់ទ្រព្យនោះ ឈ្មោះថា មិនទាន់វិនាសបាត់ទៅឡើយ យ៉ាងណាមិញ ឯព្រះពុទ្ធសាសនានេះ ក៏យ៉ាងនោះដែរ គឺថា បើបរិយត្តិនៅមានភិក្ខុទ្រទ្រង់ សិក្សារៀនសូត្រ នៅឡើយ ឬ បរិយត្តិ មិនទាន់អន្តរធានទៅ ដោយហេតុណាមួយទេ ព្រះពុទ្ធសាសនា ក៏មិនទាន់អន្តរធាន សាបសូន្យទៅដែរ ព្រោះអាស្រ័យបរិយត្តិជាប្រមាណ គឺបរិយត្តិ ទុកជាឫសគល់របស់ព្រះពុទ្ធសាសនា។

ព្រោះហេតុនោះ សាធុជនទាំងឡាយគ្រប់ឋានៈ កាលបើបានពិចារណាឃើញច្បាស់ថា ពុទ្ធសាសនាដែលប្រាប់ប្រយោជន៍បច្ចុប្បន្នប្រយោជន៍បរលោក ប្រយោជន៍ព្រះនិព្វាន ពិតប្រាកដមែនហើយ ក៏ពេញអធ្យាស្រ័យ ចង់បានប្រយោជន៍ទាំង៣ ឬក៏ចង់បានប្រយោជន៍ណាមួយក៏ដោយ គួរតែខំសិក្សាពុទ្ធសាសនាឲ្យបានចេះចាំចូលចិត្ត

សេចក្តីជាមុនសិនព្រោះថាការនាំអោយបានសម្រេចប្រយោជន៍ទាំងនោះ ក៏មកតែអំពីការប្រតិបត្តិត្រូវ ការប្រតិបត្តិត្រូវក៏មកតែអំពីការចេះដឹង ការចេះដឹង ក៏មកតែអំពីការសិក្សាជាប្រធាន។ បើសាធុជនទាំងឡាយគ្រប់ឋានៈយល់ច្បាស់ថាពុទ្ធសាសនាមានសារៈដ៏សំខាន់អាចធ្វើអ្នកសិក្សា អ្នកប្រតិបត្តិតាម ឲ្យបានសម្រេចប្រយោជន៍ ដូចបានពណ៌នា មកហើយខាងលើនេះ ហើយមានឆន្ទៈ ចង់ធ្វើអោយពុទ្ធសាសនាបានថ្កុំថ្កើង រុងរឿង តាំងនៅជាស្ថាពរ អស់កាលជាអង្វែងតទៅដោយពុំមានកំណត់កាលថាប៉ុណ្ណេះប៉ុណ្ណោះបាននោះ លុះតែពុទ្ធសាសនិកជនទាំងឡាយគ្រប់ឋានៈ បានប្រតិបត្តិតាមធម៌៥យ៉ាងទើបពុទ្ធសាសនាអាចនឹងតាំងបានអស់កាលជានិរន្តរ៍តរៀងទៅ។

**ឯធម៌ទាំង៥យ៉ាងនោះគឺ**

១. សក្កច្ចំ ធម្មំ សុណន្តិ ពុទ្ធសាសនិកទាំងឡាយស្តាប់ធម៌ដោយគោរព។

២. សក្កច្ចំ ធម្មំ បរិយាបុណន្តិ រៀនធម៌ដោយគោរព។

៣. សក្កច្ចំ ធម្មំ ធារេន្តិ ទ្រទ្រង់ធម៌ដោយគោរព។

៤. សក្កច្ចំ ធតានំ ធម្មានំ អត្ថំ ឧបបរិក្ខន្តិ ពិចារណានូវសេចក្តីនៃធម៌ទាំងឡាយដែលខ្លួនចេះចាំដោយគោរព។

៥. សក្កច្ចំ អត្ថមញ្ញាយ ធម្មមញ្ញាយ ធម្មានុធម្មំ បដិបជ្ជន្តិ ដឹងអត្ថនិងធម៌ ហើយប្រតិបត្តិសមគួរដល់ធម៌ដោយគោរព។

ព្រះពុទ្ធសាសនា ដែលនឹងអាប់ឱនពោយរៀវអន់ថយ បាត់ពន្លឺរស្មីទៅវិញបន្តិចម្តងៗ ដរាបដល់រលត់សូន្យឈឹងទៅវិញ ក៏ព្រោះតែពុទ្ធបរិស័ទទាំងឡាយ មិនប្រតិបត្តិតាមធម៌ ៥យ៉ាងដែរគឺៈ

១. ន សក្កច្ចំ ធម្មំ សុណន្តិ ពុទ្ធសាសនិកទាំងឡាយមិនស្តាប់ធម៌ដោយគោរព។

២. ន សក្កច្ចំ ធម្មំ បរិយាបុណន្តិ មិនរៀនធម៌ដោយគោរព។

៣. ន សក្កច្ចំ ធម្មំ ធារេន្តិ មិនទ្រទ្រង់ធម៌ដោយគោរព។

៤. ន សក្កច្ចំ ធតានំ ធម្មានំ អត្ថំ ឧបបរិក្ខន្តិ មិនពិចារណាសេចក្តីនៃធម៌ទាំងឡាយដែលខ្លួនចេះចាំដោយគោរព។

៥. ន សក្កច្ចំ អត្ថមញ្ញាយ ធម្មមញ្ញាយ ធម្មានុធម្មំ បដិបជ្ជន្តិ ដឹងអត្ថនិងធម៌ហើយមិនប្រតិបត្តិដោយគោរពតាមសមគួរដល់ធម៌។

**សេចក្តីបរិយាយអំពីធុរៈពុទ្ធសាសនា២យ៉ាង ចប់ដោយសង្ខេប។**

ព្រះគ្រូធម្មបណ្ឌិត គង់ ស៊ឹម



ឯកសារៈ

ពីមណ្ឌលវប្បធម៌ខ្មែរនៅស្វីស ព្រះភិក្ខុ ធម្មសិរី សែមចន្ទធីរ៍

